ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩**
**សវនាការលើកទី៦៩**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន
លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍
*(Judge Silvia Carwright)*
លោក យ៉ា សុខន
លោក ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc Lavegne)*
លោក ធូ មណី
លោក យូរ ឧត្តរា
លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី
លោក ឌុច ផារី
កញ្ញា ណាតាចា វ៉ីស៊ែល រីស៊ើ
*(Ms. Natacha Wexels-Riser)*
លោក ម៉ាតូ គ្រីស្ពារ *(Mr. Matteo Crippa)*
កញ្ញា អាឡាញ ប្រ៊ិត *(Aline BRIOT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង
លោក វិល្លៀម ស្មីត *(Mr. William Smith)*

លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent DE WILDE D'ESTMAEL)*

លោក ពេជ្រ សម្បត្តិ

លោក ប៉ាក ច័ន្ទលីណូ

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

កញ្ញា ម៉ុច សុវណ្ណារី

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Christine MARTINEAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ឧបសម្ព័ន្ធ
# សាក្សី

## លោក ហ៊ុន ស្មៀន

សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ........ទំព័រ ៣
សួរដោយ លោក សេង ប៊ុនឃាង ផ្តើមពី........ទំព័រ ៩
សួរដោយ លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល ផ្តើមពី........ទំព័រ ១០
សួរដោយ លោក ការ សាវុត្ថ ផ្តើមពី........ទំព័រ ១២
សួរដោយ លោក ហ្វ្រង់ស្វ័រ រូ ផ្តើមពី........ទំព័រ ១៤

## លោក ម៉េង ពាន់

សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ........ទំព័រ ១៦
សួរដោយ លោក សេង ប៊ុនឃាង ផ្តើមពី........ទំព័រ ២៣
សួរដោយ លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល ផ្តើមពី........ទំព័រ ២៤
សួរដោយ លោក ការ សាវុត្ថ ផ្តើមពី........ទំព័រ ២៨
សួរដោយ លោក ហ្វ្រង់ស្វ័រ រូ ផ្តើមពី........ទំព័រ ៣០

## ជនជាប់ចោទ កាំង ហ្គេកអាវ ហៅ ឌុច

សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ........ទំព័រ ៣៣
សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៌ ផ្តើមពី ........ទំព័រ ៤៦
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ........ទំព័រ ៦៧

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក វាំងសង់ ដឺវ៉ាយដ៏ ដេស្មាឯល | បារាំង |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោកស្រី គ្រីស្ទីន ម៉ាទីណូ | បារាំង |
| លោក អាឡាំង វែនណឺ | អង់គ្លេស |
| លោក ហ៊ុន ស្មៀន | ខ្មែរ |
| លោក ប៉េង ពាន់ | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលមកកាន់បន្ទប់សវនាការ)*

[០៩:០៥:២៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។

សវនាការថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើការសវនាការស្តាប់នូវសក្ខីកម្មរបស់សាក្សី បញ្ជាក់អំពីអត្តចរិតជនជាប់ចោទ ដែលធ្វើមិនទាន់កាលពីម្សិលមិញចំនួនពីររូប ហើយនិងពេលវេលាដែលនៅសេសសល់អង្គជំនុំជម្រះនឹងបន្តការតាំងសំណួរជាក់លាក់ អំពីអត្តចរិតចំពោះជនជាប់ចោទ ។

មុននឹងចាប់ផ្តើមដំណើរការ ក្រឡាបញ្ជីសវនាការឡើងរាយការណ៍ អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលត្រូវអញ្ជើញចូលរួម នៅក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន ។ ភាគីដែលត្រូវចូលរួមនៅក្នុងដំណើរការនីតិវិធីសវនាការ នៅក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន លើកលែងតែមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ និងក្រុមបួន អវត្តមាន ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះ D5 និង D6 មានវត្តមានរង់ចាំការកោះហៅពីអង្គជំនុំជម្រះ ។

**ប្រធានអង្គជំនុំ៖**

មុននឹងបន្តកិច្ចដំណើរការនីតិវិធីស្តាប់នូវសក្ខីកម្មរបស់សាក្សី អង្គជំនុំជម្រះសូមសួរទៅមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ អំពីកាលបរិច្ឆេទដែលយើងគ្រោងនឹងកំណត់ធ្វើសវនាការស្តាប់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ដោយផ្ទាល់មាត់របស់ភាគី ដោយហេតុថាកាលពីថ្ងៃ២៧ ខែសីហា ឆ្នាំ២០០៩ អង្គជំនុំជម្រះបានចេញសេចក្តីណែនាំ ស្តីពីនីតិវិធីពាក់ព័ន្ធនឹងការទាមទារ និងការដាក់សេចក្តីសន្និដ្ឋានលាយលក្ខណ៍អក្សរបញ្ចប់ការដេញដោល ហើយនិងកំណត់សវនាការក្នុងការស្តាប់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ដោយផ្ទាល់មាត់របស់ភាគី ចាប់ធ្វើនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ។ ប៉ុន្តែ អង្គជំនុំជម្រះបានទទួលនូវសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឲ្យមានការពន្យារពេលកាលបរិច្ឆេទក្នុងការធ្វើសេចក្តីសន្និដ្ឋាន ដោយផ្ទាល់មាត់បញ្ចប់ការពិភាក្សាដេញដោល ទៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ វិញ ។

តើមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមមួយ មានយោបល់យ៉ាងណាដែរពាក់ព័ន្ធជាមួយនឹងការសុំពន្យារពេលរបស់សហព្រះរាជអាជ្ញានេះ?

[០៩:០៩:០០]

**លោក អាឡាំង វែនណឺ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម! សូមអរគុណជាបឋម ដែលថាយើងបានទទួលកាលបរិច្ឆេទដូចដែលបាន ខ្ញុំបានបញ្ជាក់ពីរបីសប្ដាហ៍មកហើយ គឺយើងមានចាប់អារម្មណ៍សំខាន់ជាពិសេស យើងមានការភ្ញាក់ផ្អើលអំពីសំណើរបស់សហព្រះរាជអាជ្ញា ការស្នើសុំនេះ គឺថាអាចនឹងប៉ះពាល់ទៅដល់ចំណុចបត់បែនជាច្រើន។ ប៉ុន្តែ យើងមិនប្រកាន់គោលជំហរអ្វីពីរឿងនេះទេ គឺអាស្រ័យលើអង្គជំនុំជម្រះសម្រេច ។ ប៉ុន្តែ យើងត្រូវការសេចក្ដីសម្រេចលើបញ្ហានោះ ថាតើអង្គជំនុំជម្រះសម្រេចយកកាលបរិច្ឆេទណាមួយយើងនឹងគោរពទៅតាមកាលបរិច្ឆេទនោះ ហើយដែលដើម្បីឲ្យយើងអាចត្រលប់មកវិញទាន់ពេល ដូច្នេះបញ្ហានេះគឺនៅក្នុងសិទ្ធិរបស់អង្គជំនុំជម្រះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ចុះមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបីវិញ តើមានយោបល់យ៉ាងណាដែរ អំពីការសុំពន្យារពេលកំណត់សវនាការ ធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដោយផ្ទាល់មាត់ ដែលស្នើសុំដោយសហព្រះរាជអាជ្ញានេះ?

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម ។

ការកែប្រែកាលបរិច្ឆេទនេះ មិនមានកាប៉ះពាល់អ្វីមិនល្អដល់យើងខ្ញុំទេ ដូចមេធាវី អាឡាំង វែនណឺ បានជម្រាបអង្គជំនុំជម្រះអ៊ីចឹង ។ ទោះជាកាលកំណត់សម្រេចចុងក្រោយយ៉ាងដូចម្ដេច យើងនឹងគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ចុះមេធាវីការពារក្ដីវិញ តើលោកមានយោបល់យ៉ាងណាដែរ អំពីការសំណើសុំកែប្រែនូវកាលបរិច្ឆេទក្នុងការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ដោយផ្ទាល់មាត់ ដែលស្នើឡើងដោយសហព្រះរាជអាជ្ញានេះ?

[០៩:១១:៣០]

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន! ចំពោះសំណើរបស់សហព្រះរាជអាជ្ញា ដែលបានសុំពន្យារពេលសវនាការដោយផ្ទាល់មាត់ពីថ្ងៃទី២៣ ខែវិច្ឆិកា ទៅថ្ងៃទី៣០ ខែវិច្ឆិកា នោះ មេធាវីការពារក្តីមិនមានអ្វីដែលយល់ទាស់ទេ ពីព្រោះថា នេះជាការពន្យារវាកុំឲ្យតែការពង្រួញមកវិញ ដែលយើងក្រែងលោថា ធ្វើសេចក្តីសន្និដ្ឋាន ឬក៏ធ្វើអីៗមិនទាន់ បើជាការពន្យារវាមិនជាមានបញ្ហាអីទេ ។ ដូច្នេះហើយខ្ញុំចាំតែគោរពតាមលោកប្រធានសម្រេចទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណនូវមតិយោបល់របស់មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ក្រុមពីរ ហើយនិងមេធាវីការពារក្តី អ៎! ក្រុមបី ក្រុមមួយ និងមេធាវីការពារក្តី ។

ខ្ញុំសូមជម្រាបដល់ភាគី និងសាធារណជនសាជាថ្មីម្តងទៀតថា នៅថ្ងៃនេះបន្ទាប់ពីអង្គជំនុំជម្រះស្តាប់នូវសក្ខីកម្មរបស់សាក្សីចំនួនពីររូប ដែលគាត់នឹងមកធ្វើសក្ខីកម្មបង្ហាញបញ្ជាក់អំពីអត្តចរិតរបស់ជនជាប់ចោទ បន្ទាប់មកអង្គជំនុំជម្រះនឹងបន្តកិច្ចដំណើរការសវនាការក្នុងការសួរដល់ជនជាប់ចោទ អំពីអត្តចរិតរបស់គាត់ ។

មន្រ្តីតុលាការអញ្ជើញសាក្សីឈ្មោះ ហ៊ុន ស្មៀន ចូលមកកាន់សាលសវនាការ ។

*(លោក ហ៊ុន ស្មៀន ចូលមកក្នុងបន្ទប់សវនាការ)*

[០៩:១៥:៣០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយ ប្រធានអង្គជំនុំ៖**

អរុណសួស្តីសាក្សី ។

**ស៖** លោកមានឈ្មោះ ហ៊ុន ស្មៀន អ៊ីចឹងពិតមែនដែរឬទេ?

**ឆ៖** បានត្រឹមត្រូវ ។

**ស៖** លោក ហ៊ុន ស្មៀន តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ខ្ញុំមានមានអាយុ ៦០ឆ្នាំ ។

**ស៖** លោក ហ៊ុន ស្មៀន តើសព្វថ្ងៃនេះលោមានទីលំនៅទីកន្លែងណា ហើយលោកប្រកបមុខរបររកស៊ីធ្វើអ្វីដែរ?

**ឆ៖** បាទ, ខ្ញុំរស់នៅភូមិស្ទឹង ឃុំរលួស ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។ សព្វថ្ងៃខ្ញុំជានិវត្តន៍ជន ។

**ស៖** លោក ហ៊ុន ស្មៀន តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការ កាលពីម្សិលមិញ គឺបានរាយការណ៍ថា លោកមិនមានចំណងជាញាតិលោហិត ញាតិពន្ធ ឬក៏សហព័ទ្ធ ជាមួយនឹងភាគីណាមួយនៃរឿងក្តីនេះទេ ហើយបានបញ្ជាក់ផងដែរថា លោកបានស្បថរួចហើយ តើរបាយការណ៍នេះជាការពិតដែរឬទេ?

**ឆ៖** បាទ, របាយការណ៍នេះជាការពិត ។

**ស៖** ឥឡូវនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចដល់លោក ក្នុងនាមលោកជាសាក្សី លោក ហ៊ុន ស្មៀនក្នុងនាមលោកជាសាក្សី លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬអំណះអំណាងណាមួយ ដែលច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពទៅលើខ្លួនឯង ហើយនិងទន្ទឹមនឹងនេះ លោកមាន-- ក្នុងនាមជាសាក្សី លោកមានករណីយកិច្ចនិយាយតែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញដោយផ្ទាល់ ។ លោក ហ៊ុន ស្មៀន តើលោកធ្លាប់បានស្គាល់ជនជាប់ចោទឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែរឬទេ?

[០៩:១៨:០០]

**ឆ៖** បាទ, សូមជម្រាបប្រសាសន៍! ខ្ញុំបាទមិនដែលស្គាល់ទេ កាំង ហ្កេកអ៊ាវ ខ្ញុំស្គាល់តែ ហង់ ពិន ។

**ស៖** លោកអាចមើលមុខគាត់ ជនជាប់ចោទ ហើយសំណួរសួរថា តើហង់ ពិន ដែលលោកបានស្គាល់នោះ ហើយនិងជនជាប់ចោទនៅក្នុងសាលាសវនាការនេះ ជាមនុស្សតែម្នាក់ ឬក៏ជាមនុស្សផ្សេងពីគ្នា?

**ឆ៖** បាទ, មនុស្សនេះតែម្នាក់គត់ ។

**ស៖** ជនជាប់ចោទអង្គុយចុះ ។

តើលោកបានស្គាល់គាត់ហ្នឹងនៅក្នុងកាលៈទេសៈណាដែរ នៅទីកន្លែងណា? ហើយនៅពេលណា?

**ឆ៖** ខ្ញុំសូមជម្រាបប្រសាសន៍! ខ្ញុំស្គាល់លោក ហង់ ពិន នេះ គឺនៅឆ្នាំ១៩៩៦ ហើយខែតុលា ហើយខ្ញុំស្គាល់នេះក៏ដោយសារតែកាលនៅឆ្នាំនោះ គឺខ្ញុំជានាយកសាលាអនុវិទ្យាល័យស្វាយចេក ដោយ

ខ្វះគ្រូ ក៏ខ្ញុំបានសុំខាងអប់រំស្រុកហ្នឹង អញ្ជើញមកបម្រើការងារនៅសាលារបស់យើងខ្ញុំ ។

**ស៖** លោកបានអញ្ជើញជនជាប់ចោទ ដែលលោកអះអាងថា កាលណោះឈ្មោះ ហង់ ពិន ទៅធ្វើការជាគ្រូ ។ តើកាលណោះ គាត់ធ្វើគ្រូបង្រៀនមុខវិជ្ជាអ្វីដែរ? នៅសាលាដែលលោកធ្វើជានាយកនោះ ហើយកាលដែលគាត់ទៅបង្រៀននៅទីនោះអស់រយៈពេលប្រហែលប៉ុន្មានដែរ?

**ឆ៖** សូមជម្រាបប្រសាសន៍! កាលដែលគាត់ចូលទៅធ្វើការនៅអនុវិទ្យាល័យនេះ គឺគាត់បានសុំឲ្យគាត់បង្រៀននៅភាសាបារាំង ហើយគាត់បានចូលធ្វើការ គឺក្នុងឆ្នាំសិក្សា២០០៦-២០០៧ ដោយគាត់ចូលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៦ គាត់ធ្វើការនេះរហូតដល់ចុងខែពីរ រហូតដល់ដើមខែបី ក៏ខ្ញុំចាំមិនបានដែរពីព្រោះពុំមានឯកសារគ្រប់គ្រាន់សម្រាប់នឹងឆ្លើយ ។ គាត់ក៏បានបោះបង់ការងារហ្នឹងពីការងារសាលាហ្នឹងចេញផុតមក ។

**ស៖** ២០០៦-២០០៧ ឬក៏ ១៩៨៦-១៩៨៧ ពីព្រោះលោកនិយាយដំបូងឡើយ គឺខែ១០ ឆ្នាំ១៩៨៦ ហើយឥឡូវនេះមានពាក្យខ្លះ គឺមាន២០០៦-២០០៧ ហើយពាក្យខ្លះ ១៩៨៦-៨៧ តើកាលប្បវត្តិមួយណាដែលច្បាស់លាស់?

[០៩:២១:៥៧]

**ឆ៖** សូមទោស! គាត់មកធ្វើការ គឺក្នុងខែ១០ ថ្ងៃ២៨ ខែតុលា ឆ្នាំ១៩៨៦ ហើយគាត់មកធ្វើការនេះគឺសុំឲ្យគាត់បង្រៀននូវភាសាបារាំង ហើយក្នុងរយៈពេលនៅក្នុងខែពីរ ឬមួយក៏ដើមខែបី ខ្ញុំចាំមិនច្បាស់១៩៨៧នេះ គាត់បានបោះបង់ពីការងារក្នុងសាលានេះទៅវិញ ។ សូមជម្រាបប្រសាសន៍ប៉ុណ្ណឹង ។

**ស៖** លោក ហ៊ុន ស្មៀន ចូរលោករៀបរាប់ដល់អង្គសវនាការ អំពីអត្តចរិតរបស់ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលកាលណោះលោកស្គាល់ថា ហង់ ពិន ដែលលោកធ្លាប់បានដឹង បានកត់ស្គាល់នៅក្នុងអំឡុងពេលដែលគាត់ និងលោកបានធ្វើការងារជាមួយគ្នា ក្នុងនាមលោកជានាយកអនុវិទ្យាល័យ ហើយគាត់ជាគ្រូបង្រៀន ។ តើលោកបានដឹង និងកត់សម្គាល់នូវអត្តចរិតរបស់គាត់យ៉ាងណាខ្លះ? សូមអញ្ជើញ ។

**ឆ៖** សូមជម្រាបប្រសាសន៍! លោក ហង់ ពិន កាលគាត់នៅបម្រើការនៅអនុវទ្យាល័យហ្នឹង គឺគាត់មានអត្តចរិតស្លូតបូតទេ ហើយគាត់ក៏មិនសូវជានិយាយស្ដីអ្វីដែរ ហើយគាត់ហ្នឹងចូលចិត្តមើលសៀវភៅ ហើយនៅតែឯងៗ ។ ហើយនៅពេលដែលគាត់មកសាលា ចួនកាលឃើញគាត់ជិះម៉ូតូ ហើយចួនកាលឃើញគាត់ដើរ ហើយមិនប្រក្រតីទេ ពីព្រោះនៅសាលា ហើយនិងផ្ទះគាត់ដែលស្នាក់នៅហ្នឹង

ប្រហែលជាបួនប្រាំរយម៉ែត្រ ហើយគាត់ក៏មិនសូវជាចូលនិយាយលេងសើចអីជាមួយអ្នកដទៃជាមួយគ្រូ ជាមួយបុគ្គលិកដូចគ្នា ពីព្រោះកាលណាគាត់អស់ម៉ោង គឺគាត់ហ្នឹងចូល ច្រើនតែអង្គុយមើលសៀវភៅ ដោយឡែកតែឯង ។ ហើយនៅក្នុងការបង្រៀនទៀតសោត ក៏ឃើញថាគាត់ជាគ្រូចាស់ ហើយគាត់ក៏មានចំណេះដឹងជ្រៅជ្រះខាងផ្នែកភាសាបារាំង ប៉ុន្តែនៅក្នុងឯកទេសដើម ក៏ខ្ញុំមិនដឹងថា គាត់ជាឯកទេសអីដែរ ប៉ុន្តែដល់ឃើញចាស់ ច្បាស់ជាចេះភាសាបារាំងហើយ ក៏ខ្ញុំឲ្យ ទន្ទឹមនឹងនោះ គឺដោយសារសាលាហ្នឹងខ្វះភាសាបារាំង ក៏ឲ្យបង្រៀនភាសាបារាំងហ្នឹងទៅ ។ សូមជម្រាបប្រសាសន៍ប៉ុណ្ណឹង ។

**ស៖** លោកដឹងពិតប្រាកដទេថា កាលពីលោកសុំជនជាប់ចោទ កាលណោះឈ្មោះ ហង់ ពិន ហ្នឹងជាគ្រូទៅហ្នឹង ថាតើគាត់នៅក្នុងក្របខ័ណ្ឌនៃសាលាណា?

**ឆ៖** ជម្រាបប្រសាន៍ អឺ! កាលដែលខ្ញុំសុំហ្នឹង កាលហ្នឹងលោក ហង់ ពិន ហ្នឹង គាត់ធ្វើការនៅអប់រំស្រុកស្វាយចេក ។

**ស៖** លោកដឹងដែរទេថាតើគាត់ចូលធ្វើគ្រូបង្រៀនក្នុងក្របខ័ណ្ឌអប់រំស្រុកស្វាយចេកហ្នឹង ចាប់ពីពេលណាមក?

[០៩:២៦:៣០]

**ឆ៖** ជម្រាបប្រសាសន៍ អឺ! ខ្ញុំមិនដឹងថាពីអង្កាល់ទេ ប៉ុន្តែនៅមុនឆ្នាំ១៩៩៦ នេះ គឺឃើញគាត់នៅធ្វើការនៅការិយាល័យអប់រំស្រុក ។ ខ្ញុំឃើញអ៊ីចឹងដោយសារបុគ្គលិករបស់ខ្ញុំ ដែលបង្ហាត់ភាសាបារាំងហ្នឹងស្លាប់ទៅ ក៏ឃើញគាត់ទៅសុំគាត់ សុំអប់រំស្រុកហ្នឹង សុំគាត់ហ្នឹងឲ្យមកជួយបង្រៀននៅសាលាខ្ញុំ ។

**ស៖** កាលណោះ គាត់បង្រៀនភាសាបារាំងហ្នឹង បង្រៀននៅថ្នាក់ទីប៉ុន្មានខ្លះដែរ?

**ឆ៖** ជម្រាបប្រសាសន៍! គាត់បង្រៀននៅថ្នាក់ទី៨ ហើយនិងថ្នាក់ទី៩ ។

**ស៖** លោកបាននិយាយអម្បាញ់មិញថា គាត់ចូលចិត្តនៅតែម្នាក់ឯង មានលក្ខណៈដាច់ដោយឡែកពីគ្រូដទៃ ហើយនិងចូលចិត្តមើលសៀវភៅ មិននិយាយច្រើន ។ សំណួរសួរថា លក្ខណៈដែលលោកកត់សម្គាល់ ចូលចិត្តនៅដាច់ដោយឡែកតែម្នាក់ឯងហ្នឹងវាជាអត្តចរិតធម្មជាតិរបស់គាត់ កំណើតរបស់គាត់ ឬក៏គាត់មានការ ធ្វើការធ្វើដូច្នេះ ដោយសារមូលហេតុមានការលាក់លៀមនូវអំពីរបស់គាត់ណាមួយ?

**ឆ៖** បាទ, ខ្ញុំក៏មិនដឹងដែលរឿងហ្នឹង ។

**ស៖** ចុះអំពីការប្រាស្រ័យទាក់ទងជាមួយនឹងមជ្ឈដ្ឋានសិស្ស ក៏ដូចជាមជ្ឈដ្ឋានគ្រូផ្សេងទៀត និងបុគ្គលិកនៃសាលាអនុវិទ្យាល័យ ដែលលោកជានាយកនោះ ថាតើគាត់មានការប្រាស្រ័យទាក់ទងយ៉ាងម៉េចដែរ?

**ឆ៖** ជម្រាបប្រសាសន៍! ក្នុងការទាក់ទងហ្នឹង គឺយើងទាក់ទងតាមធម្មតា ដូចឃើញមិត្តភក្តិធម្មតាអ្នកដែលរួមអាជីពដូចគ្នា ឃើញមានតែការនិយាយសួរសុខទុក្ខធម្មតាអ៊ីចឹង ។

**ស៖** គាត់មានដែលសម្តែងនូវអាកប្បកិរិយា ឬក៏ពាក្យពេចន៍ណាដែលមិនសមរម្យនាំឲ្យការប៉ះពាល់ទៅលើសតិអារម្មណ៍គ្រូ ឬក៏សិស្សដែលគាត់បង្រៀនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍! ដូចមិនដែលមានទេ បាទ ។

**ស៖** កាលដែលគាត់ទៅបង្រៀននៅអនុវិទ្យាល័យនោះ តើកូន គ្រួសាររបស់គាត់ហ្នឹង គាត់យកទៅនៅទីនោះជាមួយដែរឬទេ?

[០៩:៣០:០០]

**ឆ៖** បាទ, សូមប្រសាសន៍! គាត់ទៅធ្វើការនៅទីនោះ គឺមានតែកូនទេ ដែលយកទៅជាមួយ ។

**ស៖** លោកនិយាយអម្បាញ់មិញនេះថា ដល់អំឡុងពេលដែលទៅបង្រៀននៅទីនោះហាក់ដូចជាពេលវេលាមិនវែងប៉ុន្មានទេ គឺត្រឹមថ្ងៃទី២៨ ខែ១០ បានន័យថា ត្រឹមតែ-- ដូចជាខែ១១, ១២ ខែ១ ខែ២ ឬក៏ខែ៣ បានតែបួន ឬក៏ប្រាំខែប៉ុណ្ណោះ ហើយក៏គាត់បានបោះបង់ការងារ១ ហ្នឹង មានន័យថាម៉េចទៅ? ថាគាត់ឈប់ធ្វើគ្រូនៅទីនោះ ហើយគាត់ចាកចេញទៅកន្លែង? ឬក៏គាត់បោះបង់ការងារជាបណ្តោះអាសន្នហើយគាត់វិលត្រលប់ទៅទទួលការងារវិញ ដោយមានមូលហេតុផ្សេងរបស់គាត់?

**ឆ៖** សូមជម្រាបប្រសាសន៍! ក្នុងអំឡុងខែ២ ចុងខែ២ ដើមខែ៣ ហ្នឹង មិនដឹងថ្ងៃណាពិតប្រាកដ ហើយគាត់បានបាត់មុខពីក្នុងសាលាហ្នឹង ។ ស្រាប់តែដល់ក្រោយទៀតមក ឮដំណឹងថាគាត់នឹងបានទៅធ្វើការនៅឯសំឡូត ហើយខ្ញុំក៏មិនបានជាគិតគូរឲ្យវែងឆ្ងាយ ពីព្រោះចំណាត់តាំងនេះ ក៏គ្មានឃើញមកដល់ខ្ញុំដែរ គឺឃើញមានស្អីទេ មានតែឮតែដំណឹងតែប៉ុណ្ណឹង ។ សូមជម្រាបប្រសាសន៍ប៉ុណ្ណឹង ។

**ស៖** អ៊ីចឹង បានន័យថា លោកអត់ដឹងព័ត៌មានទាំងអស់ ។ អ្វីទាំងអស់អំពីការបោះបង់ការងារនេះ មិនដឹងថា គាត់បោះបង់ការងារនៅទីនោះ ហើយគាត់ទៅទទួលការងារថ្មីនៅសំឡូត ឬក៏គាត់ត្រូវបានផ្ទេរភារកិច្ច ផ្ទេរការងាររបស់គាត់ពីទីនោះ ទៅធ្វើការងារនៅសំឡូតទេ ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ, ពិតមែន បាទ ។

**ស៖** ចុះមជ្ឈដ្ឋានផ្សេងទៀតក្នុងការប្រាស្រ័យទាក់ទង គឺក្រៅពីសិស្ស ក្រៅពីគ្រូនៅក្នុងអនុវិទ្យាល័យដែលគាត់ធ្វើការជាមួយនឹងលោក តើលោកមានការកំណត់សម្គាល់នូវការដែលគាត់ធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងសហគមន៍នៃទីកន្លែងលំដ្ឋានដែលគាត់រស់នៅ យ៉ាងម៉េចដែរ?

[០៩:៣៣:០២]

**ឆ៖** បាទ, សូមជម្រាបប្រសាសន៍! ក្នុងការរស់នៅរបស់គាត់ហ្នឹង រយៈពេលខ្លី ហើយខ្ញុំក៏មិនបានក្តាប់ឲ្យបាននឹងន ។ ហើយម្យ៉ាងទៀត គឺការរស់នៅក្នុងសហគមន៍របស់គាត់ហ្នឹង ហើយបានឆ្ងាយពីកន្លែងដែលខ្ញុំរស់នៅ ហើយខ្ញុំក្តាប់អត់បាន ។

**ស៖** ចុះខាងផ្នែកជំនឿសាសនាវិញ កាលពីអំឡុងពេលគាត់ទៅបង្រៀននៅអនុវិទ្យាល័យដែលមានលោកជានាយកនោះ ក្នុងអំឡុងពេលបួន ឬក៏ប្រាំខែនោះ តើលោកកត់សម្គាល់ថា កាលនោះគាត់មានជំនឿសាសនាខាង យ៉ាងម៉េចដែរ?

**ឆ៖** បាទ, សូមជម្រាបប្រសាសន៍! តាមដែលខ្ញុំឃើញ ហើយខ្ញុំដឹង គាត់នឹងមានជំនឿសាសនាខាងគ្រិស្តសាសនា ។

**ស៖** កាលដែលគាត់បានបោះបង់ការងារពីសាលា ថាតើគាត់បានជម្រាបប្រាប់ដល់លោកនាយកដែរឬទេ? ឬក៏ប្រាប់ដល់មន្ទីរអប់រំស្រុកដែរឬទេ អំពីកាលដែលគាត់បោះបង់ការងារជាគ្រូបង្រៀនរបស់គាត់ កាលនោះ?

**ឆ៖** សូមជម្រាបប្រសាសន៍! ក្នុងការបោះបង់នេះ គឺខាងការិយាល័យ ខាងមន្ទីរ ខ្ញុំមិនបានដឹងទេ គឺដឹងតែខាងខ្ញុំនេះ គឺអត់មានដឹងដំណឹងអីទេ ។ សូមជម្រាបអ៊ីចឹង ស្រាប់តែបាត់ខ្លួនតែម្តងទៅ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះដែរឬទេ?

បើមិនមានទេ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីតាំងសំណួរដល់សាក្សីរូបនេះ ប្រសិនបើមាន ។ ហើយសូមជម្រាបថា តំណាងសហព្រះរាជអាជ្ញាមានពេលវេលាដប់នាទី ក្នុងការតាំងសំណួរនេះ ។ សូមអញ្ជើញ ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយ លោក សេង ប៊ុនឃាង៖**

បាទ, អរគុណលោកប្រធាន ។

**សៈ** សួស្តី លោក ហ៊ុន ស្មៀន តើលោកដឹងទេថាការបំពេញមុខងាររបស់ ឌុច នោះយ៉ាងម៉េចដែរ? គាត់ជាមនុស្សព្យាយាម ហ្មត់ចត់ ហើយតែងតែធ្វើការងារដែលថាលើសផែនការទៀត អ៊ីចឹងមែនទេ?

[០៩:៣៦:១៥]

**ឆៈ** ជម្រាបប្រសាសន៍! កាលនៅពីដើមខែ-- ដើមៗបវេសនកាលពីរបីខែដំបូងហ្នឹង គឺក្នុងការបំពេញការងាររបស់គាត់ល្អណាស់ ។ ហើយរហូតដល់យើងខ្ញុំដែលជាអ្នកគ្រប់គ្រងហ្នឹង រហូតដល់មានការច្រើន ហើយភ្លេចវៃជួងហ្នឹង គាត់មាននាឡិការខ្លួនគាត់ដល់ជួង គាត់ចូលទៅកន្លែងធ្វើការហ្នឹងតែម្តង កន្លែងសិស្សហ្នឹងតែម្តង ។ បាទ, អាហ្នឹង បានន័យថា គាត់យកចិត្តទុកដាក់ក្នុងការងាររបស់គាត់ហ្នឹងល្អណាស់ ។

**សៈ** បាទ, អរគុណ ។ តើលោកធ្លាប់ដែលឮ ឌុច ផ្ទាល់មាត់និយាយប្រាប់លោកថា គាត់ជាអតីតប្រធានស-២១ ហើយជាមនុស្សដែលជិតស្និទ្ធបំផុតជាមួយ សុន សេន អីហ្នឹងណ៎ា ។ ហើយមូលហេតុដែលគាត់មកបង្រៀនទីកន្លែងសាលារបស់លោកហ្នឹង គឺដើម្បីគេចពីអាជ្ញាធរដែលដេញតាមចាប់នោះ ។ តើលោកដែលឮសម្តីនេះទេ?

**ឆៈ** ជម្រាបប្រសាសន៍! មិនដែលឮទេ បាទ ។

**សៈ** បាទ, អរគុណ ។ តើលោកដែលដឹងទេថា ឌុច នោះមានទំនាក់ទំនងអ្វីខ្លះជាមួយថ្នាក់ដឹកនាំខ្មែរក្រហមនោះ លោកដឹងទេ?

**ឆៈ** មិនដែលដឹងទេ ។

**សៈ** ហើយតើលោកមានដឹងទេថាថ្នាក់ដឹកនាំខ្មែរក្រហម ឬក៏ទាហានខ្មែរក្រហមហ្នឹង តាមស្វែងរកគាត់អីហ្នឹង តើលោកមានដឹងបញ្ហានេះទេ?

**ឆៈ** បាទ, ជម្រាបប្រសាសន៍! មិនបានដឹងទាំងអស់ ។

**សៈ** នៅពេលដែល ឌុច បង្រៀននៅអនុវិទ្យាល័យស្វាយចេក ។ នៅពេលនោះ ប្រសិនជាមានគេប្រាប់លោកថា ឌុច ជាមេឃាតករនៅមន្ទីរស-២១ អ៊ីចឹង តើលោកជឿទេពេលនុ៎ង?

[០៩:៣៨:៣៦]

**ឆៈ** ជម្រាបប្រសាសន៍! បើសិនណាជាដឹងថាអ៊ីចឹង គឺខ្ញុំក៏នៅមិនជឿដែរ តាមសកម្មភាពរបស់គាត់ ។

**ស៖** អ៊ីចឹងលោកគិតថាគាត់ហ្នឹងបានសម្តែងតួបានយ៉ាងល្អអ៊ីចឹងមែនទេ? ដែលបញ្ជាក់ថាគាត់ជាមនុស្សស្លូតត្រង់នោះ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍! តាមសកម្មភាពរបស់គាត់ គឺដូចជាមនុស្សល្អត្រឹមត្រូវ ។

**លោក សេង ប៊ុនឃាង៖**

បាទ លោកប្រធាន ខ្ញុំអស់សំណួរហើយ ជាបន្តឲ្យសហការីអន្តរជាតិបន្តសំណួរ បាទ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ ។

**សួរដោយលោក វាំងសង់ ដឺវាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំសូមសួរសំណួរ លោកសាក្សី ខ្ញុំចង់ដឹងថាតើក្នុងអំឡុងពេលដែលគាត់បានបង្រៀននៅសាលារបស់លោក ថាតើមានពាក្យចចាមអារ៉ាមណាមួយ ទាក់ទងទៅនឹងប្រវត្តិអតីតរបស់ ហាង់ ពិន ដែរឬទេ ដែលហៅថា ឌុច ឈ្មោះ ឌុច នោះ? គឺប្រវត្តិទាក់ទងទៅនឹងរបបខ្មែរក្រហមដែលគាត់បានបម្រើ ថាតើគ្រូទាំងឡាយទទួលព័ត៌មានអំពីប្រវត្តិអតីតកាលរបស់គាត់ដែរឬទេ? ហើយគេមាននិយាយនៅក្នុងសាលាដែរឬទេ? ហើយថាតើលោកបានអារម្មណ៍ទៅលើព័ត៌មានការលេចឮ អ៊ីចឹងដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍! ហើយសំណួរនេះ ក៏ខ្ញុំសូមជម្រាបដែរ ថាខ្ញុំមិនដែលឮ ហើយមិនដែលដឹងដែរ ។

**ស៖** នៅពេលដែលគាត់បង្រៀននៅទីនោះ រយៈពេលខ្លី លោកអាចពិនិត្យឃើញនូវចំណុចមួយចំនួន លោកបានសង្កេតឃើញគាត់នៅតែម្នាក់ឯង ហើយខ្ញុំចង់សួរអំពីអត្តចរិតរបស់គាត់ ។ ថាតើគាត់ស្ថិតនៅក្នុងស្ថានភាពគាត់យ៉ាងម៉េចដែរ? ឬក៏គាត់មានលក្ខណៈម៉ត់ចត់? ឬក៏មានការបាក់ទឹកចិត្តដែរឬទេ នៅពេលដែលលោកសង្កេតទៅលើអត្តចិរតរបស់គាត់នោះ?

**ឆ៖** បាទ, សូមជម្រាបប្រសាសន៍! ក្នុងពេលដែលគាត់បម្រើការនេះក៏ខ្ញុំមិនបានជាចាប់ភ្លឹកដែរពីព្រោះរឿងអ៊ីចេះ រឿងថាគាត់កំពុងទទួលនូវរងគ្រោះពីលើកៗមុន ដែលថាមានចោរប្លន់ ហើយបានបាញ់សម្លាប់ប្រពន្ធហ្នឹង ហើយគាត់បានភៀសមកនៅស្វាយចេកហ្នឹង ហើយបានរហូតមកបម្រើការងារនោះ ខ្ញុំឃើញថាក្រែងលោគាត់មានទុក្ខ ដោយសារតែប្រពន្ធស្លាប់ ។ ហើយឃើញសកម្មភាពគាត់បែបនោះ ក៏ខ្ញុំមិននឹកឃើញថាជាអ្នកដែលធ្វើការនៅឯណោះ អត់ដឹងទេ ។ ហើយដែលគាត់នៅម្នាក់ៗឯងក្រែងលោគាត់ថានឹកឃើញទៅដល់ប្រពន្ធ នឹកឃើញដល់ការលំបាកវេទនា ផ្លាស់ពីនោះ រហូតមកដល់ទី

នេះ ហើយឃើញគាត់នៅម្នាក់អ៊ីចឹងទៅ ក៏ខ្ញុំមិនបានជាសង្ស័យថាអត្តចរិតរបស់គាត់ហ្នឹងវាបែបនេះ បែបនោះ ក៏អត់ដឹងទេ ។ បាទ, សូមជម្រាបតែប៉ុណ្ណឹង ។

[០៩:៤២:៤៨]

**ស៖** ដូច្នេះ ទាំងអស់នោះគឺជាការសន្និដ្ឋានរបស់លោក ដោយសារតែគាត់ជាបុគ្គលិករបស់លោក ប៉ុន្តែថាតើជនជាប់ចោទខ្លួនឯងនោះ ដែលនិយាយអំពីការស្លាប់របស់ប្រពន្ធគាត់ដែរឬទេ? ហើយគាត់អាចគាត់ដែលធ្លាប់បង្ហាញអារម្មណ៍អំពីការស្លាប់ប្រពន្ធរបស់គាត់ចំពោះលោកដែរឬទេ? ឬក៏គាត់លាក់កំបាំងនូវអារម្មណ៍ទាំងអស់នោះ?

**ឆ៖** បាទ, អារឿងការស្លាប់ប្រពន្ធហ្នឹង គឺខ្ញុំបានដឹងតាំងពីគាត់ធ្វើការនៅកន្លែងមុនរបស់ខ្ញុំ ដឹងហើយដល់ពេលគាត់មកធ្វើការនៅកន្លែងនេះ ក៏ខ្ញុំនឹកឃើញថារឿងកើតទុក្ខ ទទួលរងការទុក្ខសោករបស់គាត់ហ្នឹង ហើយអ៊ីចឹងបានជាខ្ញុំមិនបានជាចាប់អារម្មណ៍អ៊ីចឹង ។ បាទ, សូមជម្រាបអ៊ីចឹង ។

**ស៖** ថាតើជនជាប់ចោទបានប្រាប់ដែរឬទេ? ឬក៏ប្រាប់មិត្តរួមការងារគាត់ដែរឬទេ? ថាតើគាត់ធ្វើការងារអ្វីនៅក្នុងរបបខ្មែរក្រហម ប៉ុន្តែថាជនជាប់ចោទនោះ គាត់ធ្លាប់និយាយអំពីប្រវត្តិសកម្មភាពរបស់គាត់ក្នុងអំឡុងពេលខ្មែរក្រហមដែរឬទេ? ហើយថាតើគ្រួសារគាត់នៅឯណា? ហើយគាត់ទីណានៅក្នុងរបបខ្មែរក្រហមហ្នឹង? តើគាត់ធ្លាប់ដែលប្រាប់លោកដែរទេ?

**ឆ៖** មិនដែលឮប្រាប់ទេ ។ បាទ, សូមជម្រាបអ៊ីចឹង ។

**ស៖** ខ្ញុំមានសំណួរពីរចុងក្រោយលោកប្រធាន ។ ថាទាក់ទងទៅនឹងការបង្រៀនរបស់គាត់ ថាតើលោកចាត់ទុកការងារជាគ្រូរបស់គាត់យ៉ាងម៉េច? គាត់មានគុណសម្បត្តិយ៉ាងម៉េចនៅក្នុងការបង្រៀនរបស់គាត់ ថាតើគាត់មានអំណាចគ្រប់គ្រង ឬក៏តឹងតែងចំពោះសិស្សដែរឬទេ? ហើយថាតើគាត់ទទួលបានការគោរពស្រលាញ់ពីសិស្សរបស់គាត់ដែរឬទេ ក្នុងនាមជាលោកជានាយកដែលពិចារណានិងពិនិត្យទៅលើការងាររបស់គាត់នោះ?

**ឆ៖** បាទ, សូមជម្រាបប្រសាសន៍! ក្នុងការបង្រៀនរបស់គាត់ហ្នឹងឃើញថាល្អមែនទែន រហូតដល់សិស្សរបស់គាត់ហ្នឹង ហៅគាត់ថាគ្រូតាៗទៅហើយ អាហ្នឹងបានន័យថា គាត់ហ្នឹងបានបំពេញការងារហ្នឹងបានល្អមែនទែនបាទ ។ សូមជម្រាបអ៊ីចឹង ។

**ស៖** ខ្ញុំសូមនិយាយត្រលប់ទៅសំណួរមួយវិញ នៅពេលដែលលោកបានដឹងថា ហង់ ពិន ជាឌុច ដែលគាត់ទទួលខុសត្រូវចំពោះសកម្មភាពឧក្រិដ្ឋកម្មមួយចំនួន ថាបន្ទាប់ពីលោកបានដឹងហ្នឹងថាតើ

លោកមានអារម្មណ៍យ៉ាងម៉េចចំពោះការដែលគាត់មិនបានប្រាប់លោកអំពីបញ្ហាទាំងអស់ហ្នឹង? ហើយលោកយល់យ៉ាងម៉េចដែរ ចំពោះបុគ្គលដែលគាត់ទទួលខុសត្រូវយ៉ាងច្រើន ចំពោះស្ត្រីក្មេងៗទាំងឡាយដែលគាត់បានប្រព្រឹត្តហ្នឹង ថាតើលោកមានអារម្មណ៍យ៉ាងម៉េចដែរ ក្រោយពេលដែលលោកបានដឹង ឬក៏លោកសង្កេតឃើញថា សកម្មភាពទាំងឡាយដែលលោកបានឃើញគាត់នោះវានៅតែធម្មតាទេ?

បន្ទាប់ពីនោះមក នៅពេលដែលលោកបានដឹងអំពីបញ្ហាថា គាត់ជាអ្នកធ្លាប់ប្រព្រឹត្តឧក្រិដ្ឋកម្មអ៊ីចឹង តើលោកមានការភ័យខ្លាច ឬក៏មានការភ្ញាក់ផ្អើលដែរឬទេ? ហើយថាតើលោកគិតថាគាត់នឹងអាចធ្វើអ្វីខ្លះនៅពេលដែលលោកស្គាល់គាត់ហ្នឹង ក្នុងនាមគាត់ធ្លាប់មានប្រវត្តិអ៊ីចឹង?

[០៩:៤៧:១៧]

**ឆ៖** បាទ, តាមសកម្មភាពរបស់គាត់ដែលបម្រើការនៅកន្លែងខ្ញុំ ហើយនិងដឹងអំពីឧក្រិដ្ឋកម្មរបស់គាត់នៅនេះ ខ្ញុំរហូតដល់សព្វថ្ងៃខ្ញុំនឹកឃើញថា ហាក់ដូចជាគាត់ហ្នឹងតាមសកម្មភាពគាត់នៅឯងសាលាហ្នឹងហាក់ដូចជាមិនៗធ្វើសកម្មភាពដល់ប៉ុណ្ណឹងសោះបាទ ។ ប៉ុន្តែ យើងខ្ញុំហ្នឹងចាត់ទុកគាត់ថា ជាអ្នកដែលបើឃើញសកម្មភាពរបស់គាត់នៅសាលា ចាត់ទុកដូចជាអ្នកដែលទទួលមុខងារជាគ្រូបង្រៀននោះត្រឹមត្រូវមែនទែន ។ សូមជម្រាបអ៊ីចឹង ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំពុំមានសំណួរបន្ថែមទៀត ដើម្បីសួរទៅកាន់សាក្សីនេះទេ ។

សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត អង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះ ប្រសិនបើមាន ហើយមេធាវីការពារក្តីដប់នាទីក្នុងការសួរនេះ ។ សូមអញ្ជើញ ។

**ការតាំងសំណួរដោយមេធាវីការពារក្តី**

**សួរដោយលោក ការ សាវុត្ថ៖**

**ស៖** សូមអរគុណលោកប្រធាននិងសូមគោរពចៅក្រមជាតិនិងអន្តរជាតិ ។ លោក ហ៊ុន ស្មៀន ខ្ញុំសូមអនុញ្ញាតសួរលោកថាកាលពេលលោក ហង់ ពិន នៅជាបុគ្គលិករបស់លោក នៅអនុវិទ្យាល័យស្វាយចេក តើលោកពេញចិត្តនឹងគ្រង់ការងាររបស់លោក ហង់ ពិន ឬទេ?

**ឆ៖** បាទ, សូមជម្រាបប្រសាសន៍! បើយើងមើលតាមសកម្មភាពការងាររបស់គាត់ គឺយើងចាត់ទុកថា ជាការងារល្អបំផុតហើយនៅក្នុងសាលារបស់ខ្ញុំបាទ ។ សូមជម្រាបអ៊ីចឹង ។

**ស៖** សូមអរគុណ ។ អ៊ីចឹងលោកពេញចិត្តនឹងការងារ គ្រប់ការងារទាំងអស់របស់គាត់ទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍! ពេញចិត្តបាទ ។

**ស៖** សូមអរគុណ ។ អ៊ីចឹងតាមលោកដឹង តើសន្តានចិត្តរបស់លោក ហាង់ ពិន យ៉ាងណាដែរ ដែលនៅជាបុគ្គលិករបស់លោក? សូមលោកបញ្ជាក់អំពីសន្តានចិត្តរបស់លោក ហាង់ ពិន ។

[០៩:៥០:០៩]

**ឆ៖** នៅពេលដែលគាត់ធ្វើការនៅទីនោះ គឺសន្តានចិត្តគឺល្អណាស់ ហើយការរាប់អានក៏ដូចជាការប្រាស្រ័យទាក់ទងជាមួយនឹងបុគ្គលិក ជាមួយនឹងអ្នកគ្រប់គ្រង ជាមួយនឹងសិស្ស ឃើញថា គ្មានការល្អក់កករជាមួយគ្នាទៅវិញទៅមកទេបាទ ។

**ស៖** សូមអរគុណ។ អ៊ីចុះលោកមានប្រសាសន៍ពីដើមមកថា គាត់ច្រើនតែនៅម្នាក់ឯង ។ អ៊ីចឹងតើលោកដែលឮបុគ្គលិករបស់លោក ឬក៏សាស្ត្រាចារ្យដូចគ្នា ដែលក្រោមឱវាទរបស់លោក ឬក៏សិស្សអ៊ីចឹងទៅ មានអ្នកណាដែលធ្លាប់រិះគន់គាត់ ថាគាត់ឆ្មើងឆ្មៃ គាត់នៅតែម្នាក់ឯង មិននិយាយចូលគេចូលឯងអ៊ីចឹងដែរ តើមានទេ? សូមលោកជួយបញ្ជាក់ ។

**ឆ៖** អត់មាន និយាយអីទេ បាទ ។

**ស៖** សូមអរគុណ ។ អ៊ីចឹងតើបុគ្គលិកទាំងអស់ ជាសាស្ត្រាចារ្យទាំងអស់នៅក្រោមឱវាទលោកហ្នឹង តើគេស្រឡាញ់រាប់អានគាត់គ្រប់គ្នាដែរ ឬក៏យ៉ាងម៉េច? សូមលោកជួយបញ្ជាក់ ។

**ឆ៖** បាទ, សូមជម្រាបប្រសាសន៍! គឺម្នាក់ៗហ្នឹងដូចតែគ្នាទេ គឺរាប់អានគាត់រហូតបាទ ។

**ស៖** សូមអរគុណលោក ។ ខ្ញុំចង់ដឹងថា ពេលគ្រូៗជួបគ្នាធម្មតាទេ គឺថាគ្រូៗជួបគ្នាវាតែងមានពេលខ្លះតែនិយាយពីនេះពីនោះ ក៏ប៉ុន្តែខ្ញុំចង់ដឹងថា ពេលគ្រូជួបគ្នាហ្នឹងនិយាយពីរឿងនយោបាយ ។ តើលោកដែលធ្លាប់ឮលោក ហាង់ ពិន ហ្នឹង ធ្លាប់និយាយថា ម៉េចដែរ បើគេនិយាយពីរឿងនយោបាយ?

សូមលោកជួយបញ្ជាក់ ។

[០៩:៥២:០២]

**ឆ៖** សូមជម្រាបប្រសាសន៍! ចួនកាលអាចមានការនិយាយ ហាក់ដូចជាការនិយាយកំប្លែងហាក់ដូចជាការពិតក៏បាន ។ នៅពេលដែលបុគ្គលិកដែលជួបជុំគ្នាហើយ ក៏មានការជជែកវែកញែកពី

រឿងនេះរឿងនោះ ចួនកាលវាអាចចូលទៅក្នុងនយោបាយខ្លះអីខ្លះអីចឹងទៅ។ ក៏ប៉ុន្តែដល់តែពេលនិយាយទៅគឺ បុគ្គលិកនិយាយទៅគឺគាត់ស្តាប់បាន ហើយក៏បានកំហោក ឬមួយប្រើសំឡេងធំហ្នឹងដាក់ទៅបុគ្គលិកដែលនិយាយហ្នឹងថា វាមិនត្រឹមត្រូវទេ ។ បាទ, វាមិនត្រឹមត្រូវទេ បាទគាត់ថាតែប៉ុណ្ណឹង ។

សូមជម្រាបប៉ុណ្ណឹង ។

**ស៖** សូមអរគុណ ។ អំមិញលោកបានជម្រាបអង្គសវនាការថា មានចោរប្លន់គ្រួសាររបស់គាត់ ចោរប្លន់គាត់ ចោរប្លន់លោក ហង់ ពិន ហ្នឹង ។ តើលោកបានដឹងទេ ចោរនុ៎ងវាចោរប្លន់ពិត ឬក៏វាចោរបង្កើតឡើងដោយ ប៉ុល ពត ឬក្រុមខ្មែរក្រហម ដើម្បីតាមស្តាប់គ្រួសារគាត់? បើលោកដឹងសូមលោកជួយបញ្ជាក់ ។ សូមអរគុណ ។

**ឆ៖** បាទ, ក្នុងអារឿងចោរប្លន់នេះ ខ្ញុំអត់បានដឹងដែរ ។ ប្រហែលជាអាចសាក្សីក្រោយ ប្រហែលជាអាចដឹង បាទ, គាត់នឹងជម្រាបបានច្បាស់ពីរឿងចូលប្លន់ហ្នឹងបាទ ។ សូមជម្រាបប្រសាសន៍អីចឹង ។

**លោក ការ សាវុត្ថ៖**

សូមអរគុណលោក ហ៊ុន ស្មៀន ដែលបានខំជួយបញ្ជាក់អំពីអត្តចរិត របស់ជនជាប់ចោទប្រាប់ខ្ញុំនិងអង្គសវនាការ ។

សូមគោរពលោកប្រធាន ខ្ញុំអស់សំណួរហើយ ។ ប្រសិនបើលោកមេធាវីអន្តរជាតិគាត់-- ការពារអន្តរជាតិគាត់មានសំណួរសូមលោកប្រធានអនុញ្ញាត ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារក្តីអន្តរជាតិ ។

**សួរដោយលោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណ ។ អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រមទីគោរព ។

**ស៖** សូមសួស្តីលោកសាក្សី ។ លោកបាននិយាយស្ទើរតែគ្រប់ចំណុចហើយទៅនឹងសំណួរទាំងឡាយដែលបានសួរទៅកាន់លោក ។ ខ្ញុំមានសំណួរ ឲ្យលោកបញ្ជាក់មួយពីរតែប៉ុណ្ណោះ ។

នៅពេលណាដែលលោកបានដឹងអំពីការចាប់ខ្លួន ឌុច នោះ? នៅពេលណាដែរ? តើនៅពេលណាដែលលោកបានដឹងអំពីការចាប់ខ្លួន ឌុច ហ្នឹង?

**ឆ៖** សូមជម្រាបប្រសាសន៍! ខ្ញុំបានស្តាប់តាមវ៉ាដ្យូ ហើយនិងតាមទូរទស្សន៍ ឃើញតាមទូរទស្សន៍ ហើយក្នុងការដែលចាប់ខ្លួនលោក ហង់ ពិន ហ្នឹងឮថា ហៅ ឌុច កាំង ហ្គេកអ៊ាវ អីណា

អ៊ីចឹង ។ ស្រាប់តែដល់ឃើញមុខ ឃើញរូប ឃើញក្នុងទូរទស្សន៍ហ្នឹងណា អូ! ហើយនេះ ហង់ ពិន ដែរ តើ! អាហ្នឹងប្រហែលជាក្នុងឆ្នាំ-- ចុងឆ្នាំ១៩៨៧ ។ បាទ, សូមជម្រាបអ៊ីចឹង ។

**ស៖** ប្រហែលតែលោកច្រឡំថ្ងៃហើយ គឺប្រហែលជាក្នុងឆ្នាំ៩៩ ទេ ខ្ញុំសូមរំឭក គឺលោកបានមើលទូរទស្សន៍ដែលលោកបានដឹងថា អតីតដែលគាត់ជាគ្រូនោះ ហើយធ្លាប់ធ្វើការនៅក្រោមលោកនោះត្រូវបានគេចាប់ខ្លួន តើអ៊ីចឹងដែរឬទេ តាមទូរទស្សន៍ តាមអីងហ្នឹង?

**ឆ៖** បាទ, សូមជម្រាបប្រសាសន៍! គឺខ្ញុំច្រឡំថាឆ្នាំ ហើយខ្ញុំឃើញដែរ ក៏ប៉ុន្តែមិនបានជាចាំនៅឆ្នាំឲ្យបានច្បាស់លាស់ទេ ។ បាទ, សូមជម្រាបអ៊ីចឹង ។

**ស៖** ដូច្នេះ លោកបានឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាអម្បាញ់មិញថា លោកមានការលំបាកក្នុងការយល់ប្រហែលជាមានបញ្ហាក្នុងឧបករណ៍បកប្រែ ឬយ៉ាងម៉េច? ខ្ញុំសូមនិយាយឡើងវិញ លោកបានឆ្លើយជូនសហព្រះរាជអាជ្ញាថា លោកពិបាកក្នុងការស្វែងយល់ ថាតើ ឌុច ហ្នឹងអាចជាប្រធានស-២១ នៅក្នុងអតីតយ៉ាងដូចម្ដេច? ដោយសារតែតាមអត្តចរិតរបស់គាត់នោះ ដោយសារតែលោកបានដឹងអំពីអត្តចរិតរបស់គាត់ក្នុងនាមជាគ្រូ ។ លោកមានការពិបាកណាស់ក្នុងការយល់ថា គាត់ធ្លាប់ជាប្រធានស-២១ តើអ៊ីចឹងទេ?

**ឆ៖** សូមម្ដងទៀត ស្ដាប់អត់បានទេបាទ ។

**ស៖** សូមអភ័យទោស ។ ខ្ញុំចង់សួរថា លោកបានឆ្លើយទៅកាន់តំណាងសហព្រះរាជអាជ្ញាថា លោកមានការភ្ញាក់ផ្អើលណាស់នៅពេលដែលលោកបានដឹង អំពីដំណឹងទាក់ទងទៅនឹងជនជាប់ចោទរូបនេះ ហើយលោកមានការពិបាកក្នុងការយល់ថាតើ ឌុច ហ្នឹង ធ្លាប់ជាប្រធានមន្ទីរស-២១ យ៉ាងម៉េចនៅអតីតកាល? លោកមានការភ្ញាក់ផ្អើលណាស់ លោកមិនសូវជឿទេ ដោយសារតែលោកសង្កេតឃើញថាគាត់ជាគ្រូមួយដ៏ល្អ ហើយលោកពិបាកក្នុងទទួលយក ហើយក្នុងការជឿដូច្នោះណាស់។ តើពិតដែរឬទេ?

[០៩:៥៨:០៥]

**ឆ៖** សូមជម្រាបប្រសាសន៍! បើតាមសកម្មភាពរបស់គាត់ដែលនៅកន្លែងធ្វើការកន្លែងខ្ញុំ ហើយនិងការងាររបស់គាត់នៅមន្ទីរឃុំឃាំងឯនេះ គឺខ្ញុំនឹកឃើញថា គាត់មិនមែនជាមនុស្សរហូតដល់ប៉ុណ្ណឹងទេបាទ ។ បើសកម្មភាពរបស់គាត់ហ្នឹងវាផ្ទុយគ្នាឆ្ងាយណាស់ បើតាមសកម្មភាពហ្នឹង ហើយមិនមែនជាមនុស្សឃោរឃៅ ហើយមិនមែនមនុស្សកោងកាចដើរផឹកស៊ីឡូឡាអីអត់ទេ អត់មានទេបាទ ។ ស្ទើរតែ

មិនជឿថា គាត់ជាមនុស្សអ៊ីចឹងទៅវិញបាទ ។ អរគុណ ។

**ស៖** ហើយនេះហើយជាមូលហេតុដែលលោកបានអញ្ជើញមកថ្ងៃនេះ មកចំពោះមុខអង្គជំនុំជម្រះដើម្បីពន្យល់ជូនតុលាការថា លោកបានស្គាល់ ឌុច ក្នុងខណៈគាត់ជាគ្រូដ៏ល្អម្នាក់ ។ នេះហើយជាគោល-បំណងដែលលោកមកជម្រាបតុលាការថ្ងៃនេះ ។ គឺគាត់ជាគ្រូដ៏ល្អម្នាក់ ដែលធ្វើការងារបានយ៉ាងល្អតាមដែលលោកពិនិត្យឃើញ ។ តើមែនឬទេ?

**ឆ៖** បាទ, វាត្រឹមត្រូវណាស់ហើយបាទ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកសាក្សីខ្ញុំអរគុណ ដែលលោកបានធ្វើដំណើរពីចម្ងាយមកតុលាការនេះ ហើយដើម្បីនឹងផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ ។ លោកប្រធានខ្ញុំមិនសំណួរអ្វីទៀតទេ ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអរគុណលោក ហ៊ុន ស្មៀន ដែលលោកបានអញ្ជើញមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងតាមការកោះហៅ ហើយដំណើរការនៃការស្តាប់សក្ខីកម្មរបស់លោកអំពីអត្ត-ចរិតរបស់ជនជាប់ចោទ ឃើញថា ដល់ទីបញ្ចប់ហើយ ។ ដូច្នេះលោកអាចទៅចូលរួមស្តាប់នៅទីកន្លែងសម្រាប់សាធារណជនក៏បាន ឬក៏លោកត្រលប់ទៅលំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកចង់ទៅបានហើយ ។

មន្ត្រីតុលាការសម្របសម្រួលឲ្យគាត់បានត្រលប់ទៅវិញ ដោយមានធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ហើយនិងឲ្យអញ្ជើញលោកសាក្សីមួយទៀត ប៉េង ពាន់ ចូលមកកាន់សាលសវនាការ ។

*(លោក ប៉េង ពាន់ ចូលក្នុងបន្ទប់សវនាការ)*

[១០:០៤:០៣]

**តាំងសំណួរដោយ ប្រធានអង្គជំនុំ**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីសាក្សី! តើលោកឈ្មោះ ប៉េង ពាន់ អ៊ីចឹង ពិតមែនដែរឬទេ?

**ឆ៖** បាទ, មែន ។

**ស៖** លោក ប៉េង ពាន់ តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ៥៧ បាទ ។

**ស៖** តើទីលំនៅរបស់លោកសព្វថ្ងៃនៅឯណា? ហើយលោកប្រកបរបររកស៊ីធ្វើអ្វីដែរ?

**ឆ៖** បាទ, នៅក្នុងភូមិផ្គាំ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ហើយមុខរបរខ្ញុំជាគ្រូបង្រៀន ។

**ស៖** លោក ប៉េង ពាន់ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការពីម្សិលមិញ គឺបានធ្វើរបាយការណ៍ថា លោកមិនមានចំណងជាញាតិលោហិត ឬក៏ញាតិពន្ធ ឬក៏សហព័ទ្ធជាមួយនឹងភាគីណាមួយទេនៃរឿងក្ដីនេះ ហើយថាលោកបានស្បថរួចហើយមុននឹងចូលមកកាន់សាលសវនាការនេះ តើជាការពិតដែរឬទេ?

**ឆ៖** បាទ, ការពិត ។

**ស៖** ឥឡូវនេះយើងប្រាប់អំពីសិទ្ធិនិងករណីយកិច្ចដល់លោកក្នុងនាមលោកជាសាក្សី ។ លោក ប៉េង ពាន់ ក្នុងនាមលោកជាសាក្សី លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬក៏អំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពទៅលើខ្លួនលោក ។ ហើយទន្ទឹមនឹងនេះក្នុងនាមលោកជាសាក្សីមានករណីនិយាយតែការណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ ដោយផ្ទាល់ ។

លោក ប៉េង ពាន់ តើលោកស្គាល់ជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែរឬទេ?

[១០:០៦:១២]

**ឆ៖** បាទ, មិនដែលស្គាល់ទេ ខ្ញុំស្គាល់តែ-- អត់ដែលស្គាល់ទេ ស្គាល់តែ ហង់ ពិន ហ្នឹង ឈ្មោះ ហង់ ពិន ដែលគាត់នៅធ្វើគ្រូជាមួយខ្ញុំនឹង ។

**ស៖** អញ្ជើញជនជាប់ចោទក្រោកឈរ លោកសាក្សី លោកពិនិត្យអ្នកដែលក្រោកឈរនេះមើលថាតើមនុស្សនេះ ឬដែលលោកនិយាយថាឈ្មោះ ហង់ ពិន នោះ?

**ឆ៖** បាទ, គាត់ហ្នឹងហើយបាទ ។

**ស៖** ជនជាប់ចោទអង្គុយចុះ ។ តើលោកស្គាល់គាត់នៅក្នុង នៅទីកន្លែងណា? ហើយនៅក្នុងអំឡុងពេលណាដែរ? ហើយនៅក្នុងការងារ ឬក៏ទំនាក់ទំនងយ៉ាងម៉េចដែលនាំឲ្យលោកបានស្គាល់ជាមួយនឹងគាត់?

**ឆ៖** បាទ, ដែលស្គាល់គាត់ គឺគាត់បានមកសុំ គាត់បម្រុងធ្វើ-- ចូលៗគ្រូបង្រៀន គឺស្គាល់ត្រឹមតែគាត់ចូលធ្វើគ្រូនឹងឯង ។

**ស៖** កាលនោះគាត់សុំចូលធ្វើគ្រូហ្នឹង សុំគ្រូនៅសាលាណា? ហើយសាលានោះនៅកន្លែងណា? ហើយក្នុងអំឡុងពេលណាកាលពីសុំចូលធ្វើគ្រូនោះ?

**ឆ៖** បាទ, គាត់សុំចូល កាលនោះខ្ញុំ ដោយសារសាលាវាកើតថ្មី កើតអនុវិទ្យាល័យថ្មី ហើយខ្ញុំជាមនុស្សដែលនៅក្នុងមូលដ្ឋាន គេឲ្យទៅនៅគ្រប់គ្រងជាបណ្ដោះអាសន្ន ហើយក៏សាលាខ្វះគ្រូផង គាត់ក៏បានដាក់ពាក្យមក ហើយយើងក៏បានជ្រើសរើសគាត់នៅឆ្នាំ យកគាត់ទទួលនៅឆ្នាំ៩៣-៩៤ ហ្នឹងបាទឆ្នាំ៩៣-៩៤ ។

**ស៖** នៅសាលាអនុវិទ្យាល័យគេហៅឈ្មោះអីដែរ អនុវិទ្យាល័យនុ៎ង? ហើយនៅទីកន្លែងណា? ទីតាំងវានៅក្នុងភូមិសាស្ត្រភូមិ ឃុំ ស្រុក ណាដែរ?

[១០:០៨:៤០]

**ឆ៖** ឈ្មោះអនុវិទ្យាល័យផ្កាំ ហើយនៅទីតាំងនៅក្នុងភូមិផ្កាំដែរ ប៉ុន្តែនៅខាងជើងភូមិ នៅជាប់នឹងខាងជើងភូមិ ហើយនៅក្នុងទឹកដីភូមិផ្កាំ ឃុំផ្កាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យហ្នឹងដែរ ។

**ស៖** លោករកនឹកឡើងវិញមើល៍ បញ្ជាក់ច្បាស់លាស់អំពីកាលវេលាដែលគាត់បានមកចូលធ្វើគ្រូនៅ-- សុំចូលធ្វើគ្រូនៅអនុវិទ្យាល័យផ្កាំហ្នឹង ។ តើគាត់ធ្វើគ្រូនៅអនុវិទ្យាល័យផ្កាំហ្នឹងរយៈពេលប៉ុន្មានខែ ប៉ុន្មានឆ្នាំ? ហើយចាប់ផ្ដើមជាក់លាក់ហ្នឹង ចូលមកធ្វើគ្រូហ្នឹងពេលៗណា? ហើយរហូតដល់ពេលណាបានគាត់ចាកចេញពីអនុវិទ្យាល័យផ្កាំទៅធ្វើការនៅកន្លែងផ្សេង?

**ឆ៖** បាទ, គាត់ចូលមកធ្វើការជាមួយខ្ញុំ ដូចខ្ញុំបានជម្រាបជាមុនហើយនៅចុង២០០៣-២០០៤ ហ្នឹង ហើយគាត់រហូតដល់ឆ្នាំ២០០៥ នែ៎ ១៩៩៥ ហ្នឹងគាត់ក៏ត្រូវផ្លាស់ទៅនៅកន្លែងការិយាល័យអមស្រុក ។

**ស៖** បញ្ជាក់អំពីវេលាម្ដងទៀត ថាតើ ២០០៣, ២០០៤, ២០០៥ ឬក៏ ១៩៩៣, ១៩៩៤, ១៩៩៥ ព្រោះអានេះជារយៈពេលមួយដែលអាចមានបញ្ហាត្រូវពិភាក្សាដេញដោលនេះ ដោយសារមានការព្រឹត្តហេតុទាំងឡាយពាក់ព័ន្ធជាមួយនឹងទិដ្ឋភាពទាំងអស់នេះ វាអាចមានឥទ្ធិពលអំពីពេលវេលានេះ ឥទ្ធិពលដល់ការសាក្សីសួរអំពីទិដ្ឋភាពនៃអត្តចរិតរបស់ជនជាប់ចោទដែរ ។ អ៊ីចឹង សូមបង្ហាញអំពីពេលវេលានោះឲ្យបានច្បាស់ ។

**ឆ៖** បាទ, សូមទោសផ្ទែ លោកមេធាវីអំមិញខ្ញុំថា ២០០០ តាមពិតវា ១៩៩៣ និង-- ១៩៩៣-១៩៩៤ គាត់បានចូលខ្ញុំ ហើយរហូតដល់ឆ្នាំ១៩៩៥ គាត់ទៅនៅកន្លែងការិយាល័យអប់រំស្រុក ។

**ស៖** លោក ប៉េង ពាន់ ចូរលោកនិយាយរៀបរាប់ប្រាប់ដល់អង្គសវនាការអំពីអត្តចរិតរបស់ជនជាប់ចោទឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលលោកបានស្គាល់ថាឈ្មោះ ហង់ ពិន ដែលលោកធ្លាប់បានដឹង បានកត់សម្គាល់នៅក្នុងអំឡុងពេលដែលលោក និងគាត់បានធ្វើការជាមួយគ្នានៅអនុវិទ្យាល័យផ្កាំ ។

**ឆ៖** បាទ, សូមជម្រាបប្រសាសន៍លោកមេធាវី! គឺអត្តចរិតរបស់គាត់ ដែលគាត់បានមកធ្វើការជាមួយគ្នាហ្នឹង បើយើងគិតទៅអត្តចរិតរបស់គ្រូ គាត់ធម្មតាដូចគ្រូធម្មតាដែរ ហើយប៉ុន្តែគ្រាន់តែការងាររបស់គាត់ គឺម៉ឺងម៉ាត់ ។

**ស៖** លោកបានកត់សម្គាល់ឃើញអត្តចរិតរបស់គាត់យ៉ាងម៉េចទៀត? គាត់កាច? សាហាវ? ឃោរឃៅ? ស្លូតបូត? រម្យទម? រាបសា ឬក៏យ៉ាងម៉េច? ហើយការប្រាស្រ័យទាក់ទងជាមួយនឹងសិស្សជាមួយនឹងគ្រូដទៃទៀត ក៏ជាសហគមន៍ដែលគាត់រស់នៅទីនោះ តើលោកកត់សម្គាល់ឃើញយ៉ាងម៉េចខ្លះ?

[១០:១៣:១៤]

**ឆ៖** បាទ, បើពិនិត្យទៅលើដែលគាត់បានធ្វើការនៅអនុវិទ្យាល័យផ្កាំងហ្នឹង ដែលគាត់បង្រៀនក្មេង មើលទៅអត់មានឃើញថា កាចអីផង គាត់បង្រៀនតាមធម្មតា បាទធម្មតា ។ ហើយការរាក់ទាក់រាប់អានរវាងគ្រូ និងគ្រូក៏ធម្មតាដែរ-- ។ រកការងារធម្មតា ។

**ស៖** គាត់ចូលមកបង្រៀននៅអនុវិទ្យាល័យផ្កាំហ្នឹង គាត់បង្រៀនមុខវិជ្ជាអ្វីដែរ?

**ឆ៖** បាទ, ដោយសាលានោះ វាខ្វះគ្រូ គាត់ជំនាញគាត់ អាមុខវិជ្ជារូប និងគីមី ។

**ស៖** គាត់បង្រៀនសិស្សថ្នាក់ទីប៉ុន្មាន?

**ឆ៖** បាទ, សាលាហ្នឹងទើបនឹងបើកថ្មីផង វាអត់មានសិស្សថ្នាក់ខ្ពស់ទេ ដែលសិស្សហ្នឹងមានត្រឹមថ្នាក់ទីប្រាំមួយ ទីប្រាំពីរ និងទីប្រាំបី-- ។ អ៊ីចឹងកាលរៀន-- ដែលឲ្យគាត់បង្រៀន គឺថ្នាក់ទីប្រាំពីរ និងថ្នាក់ប្រាំបីហើយ ។

**ស៖** គាត់មកបង្រៀននៅសាលាអនុវិទ្យាល័យផ្កាំហ្នឹង គាត់ចូលក្នុងក្របខ័ណ្ឌនៃបុគ្គលិករបស់រដ្ឋដែរឬទេ? ហើយបើជាក្របខ័ណ្ឌនៅក្នុងក្របខ័ណ្ឌនៅអង្គភាពណា?

**ឆ៖** បាទ, សូមជម្រាបប្រសាសន៍! ថាកាលដែលនៅធ្វើការហ្នឹង នៅនៅឡើយទេ មិនទាន់មានក្របខ័ណ្ឌទេ-- គឺជាគ្រូដែលបម្រើការគ្មានក្របខ័ណ្ឌ អត់មានប្រាក់ខែផងគាត់ កាលហ្នឹង ។

**ស៖** អ៊ីចឹងបានន័យថា កាលនោះ គឺការចូលមកធ្វើការងារហ្នឹង គឺធ្វើដោយស្ម័គ្រចិត្តអ៊ីចឹងមែនទេ? ហើយតើមានរបបឧបត្ថមយ៉ាងម៉េចដែរ?

[១០:១៥:៤២]

**ឆ៖** បាទ, គាត់ចូលធ្វើការដោយការស្ម័គ្រចិត្ត ហើយបញ្ហារបបអីសាលាអត់មានដែរ គ្រាន់តែលើកទឹកចិត្តគាត់ថា យើងនឹងខិតខំបញ្ចូលឈ្មោះទៅតាមខ្សែរយៈបណ្ដោយនៅក្នុងតំបន់ថ្មពួក ព្រោះតំបន់យើងហ្នឹងគេកាត់ចូលក្នុងតំបន់ថ្មពួក ដែលជាតំបន់ត្រីភាគី គ្រប់គ្រងដោយតំបន់រំដោះ គេហៅតំបន់រំដោះនៅទីនោះ-- អត់ទាន់មានថវិកាឧបត្ថម្ភអត់មានអីទាំងអស់ ។

**ស៖** កាលដែលគាត់មកធ្វើជាគ្រូជាស្ម័គ្រចិត្តនៅអនុវិទ្យាល័យផ្គាំកាលនោះ តើលំនៅដ្ឋានរបស់គាត់ហ្នឹង មានចម្ងាយឆ្ងាយពីសាលារៀនដែរឬទេ ឬក៏នៅជិតសាលារៀនអនុវិទ្យាល័យផ្គាំ?

**ឆ៖** បាទ, ទំនោរថាមកគិតក្រោយពេលដែលគេបានចូលធ្វើ គាត់បានសង់នៅជិតសាលាហ្នឹងដែល ចម្ងាយប្រហែលជាមួយរយម៉ែត្រ-- មួយរយម៉ែត្រពីសាលារៀន ។

**ស៖** លោកដឹងពីប្រភព ឬក៏ពីប្រវត្តិរបស់គាត់ទេ ថាតើគាត់មកពីប្រភពណា ដែលគាត់បានមានចំណេះដឹង ហើយបានស្ម័គ្រមកជួយបង្រៀននៅអនុវិទ្យាល័យផ្គាំនោះ?

**ឆ៖** បាទ, ត្រង់ចំណុចនេះ ខ្ញុំមិនដឹងទេ ដោយសារដែលគាត់បានធ្វើក្នុងឆ្នាំនោះដោយសារនៅមាតុភូមិរបស់ពលរដ្ឋ ដែលនៅតាមជំរំ នៅតាមព្រំប្រទល់ថៃ កម្ពុជា-ថៃ ហ្នឹង គេបានវិលចូលត្រលប់មកដល់នៅស្រុកភូមិមក ។ អ៊ីចឹង ខ្ញុំអត់ក្ដាប់ប្រវត្តិគាត់បានទេ អស់ស្គាល់គាត់ផង ដល់ពេលហ្នឹង ។

**ស៖** លោកផ្ទាល់ជាអ្នកនាំគាត់ចូល ឬក៏សម្របសម្រួលដើម្បីឲ្យគាត់បានចូលមកបង្ហាត់បង្រៀនសិស្សនៅអនុវិទ្យាល័យផ្គាំ ឬក៏បុគ្គលផ្សេងទេ ដែលជាអ្នកបានដឹងព័ត៌មាន ឬក៏ទទួលសំណូមពរពីគាត់ដើម្បីឲ្យអនុញ្ញាតឲ្យគាត់មកចូលបង្រៀនជាស្ម័គ្រចិត្តជាលើកដំបូង ហើយនិងជួយសម្របសម្រួលដើម្បីបង្កលទ្ធភាពក្នុងការរៀបចំស្នើសុំក្របខ័ណ្ឌជូនដល់គាត់?

[១០:១៨:៣៤]

**ឆ៖** បាទ, តាមដែលនេះ គឺដែលដឹងៗពីគាត់ ដែលគាត់ជាគ្រូចាស់នោះតាមរយៈលោក ឡុត ង៉ាត ។ លោក ឡុត ង៉ាត គាត់នាំមក នាំមកជួបខ្ញុំទៅ ហើយខ្ញុំក៏បានសំណេះសំណាលសួរគាត់ទៅ គាត់

ថាជាគ្រូចាស់សម័យសង្គមរាស្ត្រនិយម ។ អ៊ីចឹងដល់ពេល ស្របពេលដែលយើងខ្វះទៅក៏ទទួលគាត់តែម្តង ។ ស្នើទៅលើប្រាប់ឲ្យទទួលគាត់ជួយធ្វើការតែម្តង ដាក់ពាក្យ ដាក់អីទៅ ។

**ស៖** ហើយគាត់បម្រើការងារពី ដែលលោកនិយាយថាជាការស្ម័គ្រចិត្តដំបូងឡើយហ្នឹង តើគាត់ធ្វើការងារបង្ហាត់បង្រៀននៅអនុវិទ្យាល័យផ្គាំហ្នឹងអស់រយៈពេលប៉ុន្មានដែរ ទើបផ្តាក់ក្របខ័ណ្ឌបញ្ចូលឈ្មោះគាត់ទៅជាក្របខ័ណ្ឌបុគ្គលិករដ្ឋ?

**ឆ៖** តាមពិតយូរដែរគ្រូ ក្របខ័ណ្ឌ តាមហ្នឹងផ្តាក់នៅឆ្នាំ៩៥ ចុងឆ្នាំ៩៥៧-- ចុង៩៥ ដែលផ្តាក់ក្របខ័ណ្ឌជូនគាត់នោះ តាមបណ្តោយថ្នាក់ក្រសួងយើងទៅ ។

**ស៖** នៅក្នុងអំឡុងពេលដែលគាត់មកជួយបង្ហាត់បង្រៀនសិស្ស នៅអនុវិទ្យាល័យផ្គាំដោយស្ម័គ្រចិត្តហ្នឹង តើការងាររបស់គាត់ហ្នឹងយ៉ាងម៉េចដែរ? ទៀតទាត់ទេ ព្យាយាមល្អប្រសើរទេ ឬក៏គ្រាន់តែមកហ្នឹងជាការគម្រប់កិច្ច ដើម្បីឲ្យមានគុណតម្លៃសម្រាប់លោក ឬក៏ការិយាល័យអប់រំវាយតម្លៃ ដើម្បីស្នើសុំបញ្ចូលក្របខ័ណ្ឌជាគ្រូបង្រៀន ជាបុគ្គលិករបស់រដ្ឋទេ?

**ឆ៖** បាទ, ជាទូទៅគាត់ខស្បាហ៍មកធ្វើការជារៀងរាល់ ក្នុងករណីណាដែលគាត់មានវិបត្តិខ្លួនគាត់ ឬក៏ក្រុមគ្រួសារគាត់ គាត់មានច្បាប់ខ្លះដែរ ។

**ស៖** លោកមានលំនៅដ្ឋាននៅជិតគាត់ដែរឬទេ ឬក៏នៅឆ្ងាយពីគាត់?

**ឆ៖** បាទ, ផ្ទះខ្ញុំមក-- មកផ្ទះខ្ញុំមកដល់សាលារៀនប្រហែលជាប្រាំបីរយគីឡូ នែ៎! សូមទោសប្រហែលជាប្រាំបីរយម៉ែត្រជាង តាមប៉ាន់ ។

[១០:២១:៣៥]

**ស៖** នៅក្នុងអំឡុងពេលធ្វើគ្រូបង្រៀនហ្នឹង ហេតុផលយ៉ាងម៉េចទៅបានជាគាត់ផ្លាស់ពីការធ្វើការងារនៅក្នុងវិទ្យាល័យ-- អនុវិទ្យាល័យផ្គាំមកនៅការិយាល័យអប់រំស្រុកវិញ? វាមានហេតុផលយ៉ាងម៉េចទៅ ដោយសារគាត់ឡើងឋានន្តរស័ក្តិ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ, ហេតុផលនៅហ្នឹងវាអ៊ីចេះលោកគ្រូ ហេតុផលពេលហ្នឹង ដោយសារគាត់មានវិបត្តិនៅក្រុមគ្រួសាររបស់គាត់ ពេលហ្នឹងចោរប្រដាប់អាវុធប្លន់គាត់ ប្លន់គាត់ទៅ ធ្វើឲ្យប្រពន្ធគាត់ហ្នឹងស្លាប់ៗនៅពេលគាត់ចោរប្លន់ហ្នឹង ហើយខ្លួនគាត់ក៏រងរបួសៗទៅ ក៏យើងយកគាត់ទៅសម្រាកពេទ្យ ។

ក្រោយពេលដែលជាពីពេទ្យមក ក៏គាត់ក៏សុំថាធ្វើម៉េចជួយគាត់ដើម្បីឲ្យបាន ខ្លាចមានវិបត្តិលើកក្រោយទៀតអ៊ីចឹងគ្រូ ។ ហើយយើងក៏បានសំណើទៅដល់ការិយាល័យអប់រំស្រុក ។ អ៊ីចឹងថា បើគាត់

ភ័យខ្លាចអ៊ីចឹងក៏យកមកទុកនេះសិន ។ អ៊ីចឹងក៏យកគាត់ទៅនុ៎ង ឆ្នាំ៩៥ ហ្នឹងឯងបាទ ១៩៩៥ ឡើងមក អប់រំស្រុក ។

**ស៖** ហើយបន្ទាប់ពីការចាកចេញពីអនុវិទ្យាល័យផ្កាំ លែងបង្រៀននៅទីនោះ ហើយមកធ្វើការងារនៅការិយាល័យអប់រំស្រុកហ្នឹង តើលោកដឹងថា តើគាត់នៅធ្វើការិយាល័យអប់រំស្រុកហ្នឹងអស់រយៈពេលប៉ុន្មាន? ហើយបន្ទាប់មក គាត់ទៅធ្វើការងារនៅកន្លែងណាទៀត? លោកដឹងដែរឬទេ?

**ឆ៖** ក្រោយពីគាត់មកដល់ការិយល័យស្រុក ខ្ញុំអត់ដឹងទេគ្រូ ដល់ហ្នឹងនៅទៅលើតួនាទីរបស់ការិយាល័យស្រុក គាត់ប្រើអីៗ ខ្ញុំអត់ដឹងទេ ។ ព្រោះឃើញគាត់នៅតែហ្នឹងការិយាល័យ មិនដឹងគាត់ទៅខាងផ្នែកអី ខ្ញុំអត់បានតាមដានត្រង់ហ្នឹងបាទ ។

**ស៖** លោកមានបានទទួលដំណឹងថា គាត់បានបោះបង់ការងារជាគ្រូនៅទីនោះ ហើយចាកចេញពីទីនោះទៅកន្លែងផ្សេងបាត់ដែរឬទេ?

**ឆ៖** មិនដឹងគ្រូ អត់ដឹង ។ អត់ដឹងដោយសារខ្ញុំនៅឆ្ងាយដែរ ពីទីរួមស្រុក គិតទៅសាមសិបគីឡូពីខ្ញុំ ពីទីរួមស្រុកទៅដល់កន្លែងខ្ញុំនេះ ។

**ស៖** និយាយពីរឿងព្រឹត្តិការណ៍នៃការប្លន់សម្លាប់ដោយក្រុមជនប្រដាប់អាវុធមួយក្រុម ដែលចូលប្លន់សម្លាប់ប្រពន្ធរបស់គាត់ ហើយគាត់ទទួលរងរបួសហ្នឹង លោកដឹងថានៅក្នុងថ្ងៃខែឆ្នាំណាដែរឬទេ?

[១០:២៤:៤៣]

**ឆ៖** ចាំមិនបានទេ គ្រូ អត់ចាំបាន ប៉ុនដឹងថា ៩៥ហ្នឹងឯង ក្នុង៩៥ហ្នឹងឯង ។

**ស៖** ក្នុងមានជាសហការីធ្វើជាមួយគ្នា តើលោកមានចំណាប់អារម្មណ៍ ឬក៏មានព័ត៌មានយ៉ាងដូចម្តេចជុំវិញនៃអំពើប្លន់ប្រដាប់អាវុធចំពោះគ្រួសាររបស់គាត់ រហូតដល់បាញ់សម្លាប់ភរិយារបស់គាត់នោះ? ចាក់អ្វើ! ចាក់សម្លាប់ភរិយារបស់គាត់នោះ តើលោកដឹងអំពីបញ្ហាជុំវិញនូវអំពើសម្លាប់ប្រពន្ធរបស់គាត់ហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** បាទ, ខ្ញុំអត់អាចដឹងបានដែរ ព្រោះប៉ះតំបន់ហ្នឹងវាជាតំបន់មួយអសន្តិសុខគ្រូ ព្រោះកន្លែងហ្នឹងវាមិនមែនតែប្លន់តែគាត់ទៅ វាញឹកញាប់ដែលនៅក្នុងពេលនុ៎ង មានអ្នកភូមិមានអីហ្វូរហែបាទ ។ នៅក្នុងឃុំនោះ វាពិបាកណាស់ ព្រោះជាតំបន់ដែលប្រទាញប្រទង់គ្រូ អសន្តិសុខបាទ ខ្លាំងមែនទែននៅក្នុងទឹកដីឃុំរបស់ខ្ញុំនៅពេលហ្នឹងបាទ ។ អ៊ីចឹងខ្ញុំមិនអាចឆ្លើយបាន ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះបានទៀតដែរឬទេ?

ជាបន្តទៅនេះ អង្គជំនុំជម្រះប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីតាំងសំណួរដល់សាក្សីរូបនេះ ហើយមានពេលវេលាដប់នាទី ហើយសូមរំឭកតំណាងសហព្រះរាជអាជ្ញាថា ចៀសវាងក្នុងការសួរនូវសំណួរបែបឧបមាណវិធី ឬក៏សំណួរច្រំដែរ ឬក៏សំណួរនាំឲ្យចម្លើយសាក្សីផ្តល់ចម្លើយតាមបែបសន្និដ្ឋាន ។ សូមអញ្ជើញ ។

**តាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង ប៊ុនឃាង៖**

បាទ, សូមអរគុណ លោកប្រធាន ។

**ស៖** សួស្តី លោក ប៉េង ពាន់ តើលោកជាមួយនឹងជនជាប់ចោទមានការរាប់អានគ្នាជិតស្និទ្ធដែរទេ?

**ឆ៖** បាទ, ក្រោយពេលដែលគាត់ធ្វើការរួមគ្នា ថាជិតស្និទ្ធក៏ថាបាន មិនជិតស្និទ្ធក៏ថាបាន ព្រោះធម្មតារវាងសហការី និងអ្នកគ្រប់គ្រងនៅពេលនោះ វាចេះតែមានការទំនាក់ទំនងគ្នា ។

**ស៖** ចុះពេលដែលគាត់ចូលធ្វើការនៅសាលារបស់លោកហ្នឹង តើលោកមានតម្រូវឲ្យគាត់ធ្វើប្រវត្តិរូបអីទេ ហើយថាបើសិនជាមានក្នុងនៅប្រវត្តិរូបនោះមានអ្វីដែលគួរឲ្យកត់សម្គាល់ដែរទេ?

**ឆ៖** បាទ, ក្នុងប្រវត្តិរូបហ្នឹងគាត់អត់មានសរសេរអីផង គាត់សរសេរតែគាត់ជាអតីតគ្រូសម័យសង្គមរាស្ត្រនិយម ។

**ស៖** អរគុណ។ តើលោកដឹងទេថា គាត់ហ្នឹងធ្លាប់មានទំនាក់ទំនង-- នៅពេលដែលបង្រៀននុ៎ងគាត់មានទំនាក់ទំនងជាមួយនឹងថ្នាក់ដឹកនាំខ្មែរក្រហម ឬក៏មន្ត្រីខ្មែរក្រហមណាដែរទេ ពេលនុ៎ង?

**ឆ៖** អត់ដឹង អត់ដែលឃើញគាត់ផង មកធ្វើការមិនដែលឃើញគាត់ទាក់ទងផង អត់ដឹងផង ។

**ស៖** អរគុណ ។ លោកអត់ដែលឃើញទេ អ៊ីចឹងតើលោកដែលដឹងទេថា មានគេស្វែងរកគាត់អ៊ីចឹងទេ? ដូចជាកម្មាភិបាលខ្មែរក្រហម ឬក៏ទាហានខ្មែរក្រហមតាមស្វែងរកខ្លួនគាត់ តើមានទេ?

**ឆ៖** អត់ដឹង ។

**ស៖** តើនៅពេលណាដែលលោកបានដឹងថា ឌុច ដែលជាជនជាប់ចោទនេះ គឺជាប្រធានមន្ទីរស-២១ លោកអាចជម្រាបបានទេ?

**ឆ៖** បាទ, ដឹងបានតែត្រឹមដែលគេចាប់ខ្លួនគាត់បាន ឮគេផ្សាយតាមវាំង្យុ ដឹងត្រឹមហ្នឹងឯង ។

**ស៖** នៅពេលដែលលោកបានដឹងអ៊ីចឹង តើលោកមានការខកចិត្ត ឬក៏ចិត្តគិតយ៉ាងណាដែលចំពោះដំណឹងនេះ?

[១០:២៩:៣៣]

**ឆ៖** បាទ, ក្រោយពេលដែលយើងបានដឹងក៏យើងចាប់អារម្មណ៍ដែរគ្រូ គ្រាន់តែមានការភ្ញាក់ផ្អើលប៉ុណ្ណឹង មិននឹកស្មានប៉ុណ្ណឹងឯង ។

**លោក សេង ប៊ុនឃាង៖**

បាទ, អរគុណ លោកប្រធានខ្ញុំអស់សំណួរហើយ ជាបន្តសូមឲ្យសហការីអន្តរជាតិបន្ត ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**សួរដោយលោក វាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន ។ សូមជម្រាបសួរលោកសាក្សី ។

**ស៖** លោកសាក្សីយើងមិនដឹងអ្វីច្រើនទេ អំពីអតីតកាលរបស់លោក ពីព្រោះថានៅក្នុងឯកសារទាក់ទងរបស់លោកនេះ យើងមិនឃើញមានអ្វីទេ គឺមានតែព័ត៌មានដែលមេធាវីការពារបានដាក់ជូន ។ អ៊ីចឹងហើយខ្ញុំនឹងសួរពីរឿងអតីតកាលរបស់លោក ហើយជាបឋមលោកសាក្សីលោកដឹង លោកស្គាល់សាក្សីឈ្មោះ ជូ វិន ហើយនិង ស្មៀន ផងដែរ ។

**ឆ៖** អ្នកទាំងពីរនាក់ហ្នឹងខ្ញុំស្គាល់ ព្រោះគាត់ជាអតីតគ្រូបង្រៀនដូចគ្នា តាំងពីសម័យធ្វើគ្រូសម័យរដ្ឋកម្ពុជា ។ ខ្ញុំស្គាល់យូរហើយ បាទ ។

**ស៖** តើលោកអាចប្រាប់ខ្ញុំបានទេ តើអ្នកទាំងពីរនាក់នោះ គាត់ធ្វើការនៅកន្លែងណាដែលនៅពេលដែលលោកជាគ្រូ ឬក៏ជានាយកនៅអនុវិទ្យាល័យផ្តាំនោះ?

**ឆ៖** បាទ, នែ៎ ខ្ញុំសូមជម្រាបប្រសាសន៍! លោក ជូ វិន គាត់ជាអនុប្រធានការិយាល័យអប់រំស្រុក ពីមុនអំមិញអប់រំស្រុកថ្មពួក ។ ដល់ក្រោយមកគេកាត់ស្រុកហ្នឹង ជានេះទៅ សព្វថ្ងៃឡើងអនុវិទ្យាល័យ នែ៎! អនុការិយាល័យអប់រំស្រុកស្វាយចេក ប៉ុន្តែលោក ហ៊ុន ស្មៀន គាត់នៅអនុវិទ្យាល័យស្វាយចេក ជានាយកសាលាស្វាយចេក ។

**ស៖** លោក តើទាក់ទងទៅនឹងលោក ហ៊ុន ស្មៀន តើលោកមានព័ត៌មានអ្វីដែរ ដែលអាចប្រាប់បាននោះ?

**ឆ៖** បាទ, ខ្ញុំមិនអាចប្រាប់ទេ លោកប្រធាន ប៉ុន្តែគិតខ្ញុំស្គាល់គាត់ដែរ ប៉ុន្តែធ្វើការឆ្ងាយពីគ្នាដែរ ។ គាត់នៅអនុវិទ្យាល័យស្វាយចេកមិនដឹង ពីមុនអំមិញខ្ញុំនៅជាគ្រូ នាយកសាលាបឋមទេ ហើយក្រោយទើបនឹងកើតអនុវិទ្យាល័យផ្កាទេ ដែលគេជ្រើសរើសជាបណ្ដោះអាសន្ន ទៅនៅបានមកបានស្គាល់ គាត់ ។ ប៉ុន្តែ រឿងប្រវត្តិគាត់ខ្ញុំអត់ដឹងទេ ។ សូមជម្រាបប៉ុណ្ណឹង ។

**ស៖** សូមអរគុណ ។ តើលោកអាចប្រាប់អង្គជំនុំជម្រះបានទេ តើលោកបានជួបអ្នកទាំងពីរហ្នឹងទេក្នុងពេលថ្មីៗនេះ? ហើយជួបក្នុងកាលៈទេសៈណាដែលថាលោកឈ្មោះ ជូ វិន ហើយនិង ហ៊ុន ស្មៀន នេះ?

[១០:៣៣:២១]

**ឆ៖** ជួបនៅពេលមកទីនេះ ឬក៏ជួបនៅឯកន្លែងធ្វើការ? សូមបញ្ជាក់ម្ដងទៀតបាទ ។

**ស៖** ខ្ញុំសូមសួរលោកឲ្យឆ្លើយថា ពេលណាដែលលោកបានជួបពួកគាត់ ឬក៏ជួបថ្មីៗនេះពីរបីថ្ងៃមុន ឬក៏ពីរបីអាទិត្យមុន? តើលោកមានឱកាសដើម្បីជជែកជាមួយនឹងពួកគាត់ថា ដើម្បីនឹងមកផ្ដល់សក្ខីកម្មនៅទីនេះដែរឬទេ?

**ឆ៖** ការជួបគ្នាដល់ត្រឹមមកហ្នឹង មិនដែលបានជួបគ្នាផង មកនៅត្រឹមតែ ដល់ពេលក្រុមការងារពីនេះទៅហៅ ក៏យើងមកតាមការណាត់មកបាទៗ ។ បើដូចលោក ជូ វិន អ៎! នែ បើដូច ជូ វិន ខ្ញុំនៅធ្វើការនៅការិយាល័យជុំគ្នាអាហ្នឹង រាល់ថ្ងៃបានជួបគ្នារាល់ថ្ងៃ ។ បើ បងស្មៀន គាត់មិនដែលបានជួបគាត់ទេ បាទ ។

**ស៖** សូមអរគុណលោកសាក្សី ។ តើលោកអាចរៀបរាប់ប្រាប់យើងបានដែរឬទេ អ្វីដែលលោកធ្វើក្នុងចន្លោះឆ្នាំ១៩៩៥ ហើយនិងចន្លោះឆ្នាំ១៩៧៥-៧៩ ក្នុងរបបខ្មែរក្រហម តើលោកបានធ្វើអ្វី? តើកន្លែងណាដែលលោកទៅធ្វើការងារ? តើលោកបានធ្វើការងារអ្វីខ្លះជាយោធា ឬក៏អ្វីខ្លះក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** នៅក្នុងរបប ប៉ុល ពត នោះខ្ញុំជាកសិករ ជាអ្នកចល័តលើកដីធម្មតា លើកដី ធ្វើស្រែ ។

**ស៖** នៅក្នុងឆ្នាំ១៩៩៤ តើលោកចាំទេគឺថា នៅក្នុងសាលារបស់លោកនៅស្វាយចេកនោះ ត្រូវបានគេបញ្ជូនគ្រូមួយចំនួន ដែលចូលរួមក្នុងវគ្គសុក្រិត្យការ ដើម្បីពង្រឹងចំណេះគ្រូ តើលោកបានដឹងទេ?

**ឆ៖** សូមសួរម្តងទៀតបាទ ។

**ស៖** នៅក្នុងឆ្នាំ១៩៩៤ គ្រូមួយចំនួនដែលជាគ្រូរួមសាលារបស់លោក ឬក៏អ្នកគ្រប់គ្រងសាលារបស់លោកនៅក្នុងអនុវិទ្យាល័យស្វាយចេក តើពួកគាត់នោះបានមកភ្នំពេញ ដើម្បីមកចូលរួមក្នុងវគ្គបំប៉នគ្រូបង្រៀនដែរទេ?

**ឆ៖** បាទ, នៅក្នុងសាលាខ្ញុំ សាលានៅស្រុកស្វាយចេកខ្ញុំហ្នឹង ការបំប៉នមានមកភ្នំពេញ អត់មានទេ អត់មានមកភ្នំពេញផង ។ លោកគ្រូតែទាំងអស់ អត់មានមកបង្រៀននៅភ្នំពេញផង ។

**ស៖** សូមអរគុណ ដើម្បីឱ្យច្បាស់ទាក់ទងទៅនឹងលោក ហាង់ ពិន អត្តចរិតរបស់គាត់ តើនៅពេលនាមួយ តើលោកឮគ្រូផ្សេងៗ ឬក៏អ្នកនៅក្នុងតំបន់នោះ និយាយអំពីគាត់ទេថាគាត់ជា អាចជាមនុស្សជាអតីតកម្មាភិបាលខ្មែរក្រហម ហើយអាចនឹងបានដើរតួក្នុងការប្រព្រឹត្តបទឧក្រិដ្ឋក្នុងចន្លោះឆ្នាំ ១៩៧៥ ដល់១៩៧៩ ដែរឬទេ?

[១០:៣៨:១៦]

**ឆ៖** បាទ, តាមខ្ញុំដឹង ប្រជាជននៅហ្នឹងមិនខុសពីខ្ញុំទេ វាអត់ដឹងទេពីមុននោះ ដែលគាត់ដឹងៗតែត្រឹមតែគាត់ចាប់ខ្លួនគាត់បាននោះ គេផ្សាយជាសាធារណៈ ក៏ចាប់ផ្តើមដឹងបណ្តោយ ។ ពីមុនអត់ដឹងសោះបាទពីមុន ។

**ស៖** តាមមតិគំនិតរបស់លោក ថាតើពេលដែលគាត់ធ្វើការប៉ុន្មានឆ្នាំ ជាមួយលោកនោះការប្រព្រឹត្តរបស់គាត់ កាយវិការរបស់គាត់ធម្មតា តើគាត់ជាមនុស្សដែលមានការសប្បាយរីករាយចូលចិត្តនិយាយកំប្លែងនៅក្នុងអ្នកធ្វើការជាមួយគ្នាដែរឬទេ?

**ឆ៖** បាទ, តាមជាក់ស្តែងដែលខ្ញុំបាននៅធ្វើការជាមួយគាត់នោះ ត្រង់គាត់និយាយលេងដូចមិនសូវដែលមានការនិយាយផងគាត់ ។ គាត់សុភាពធម្មតា ដូចគាត់អ៊ីចឹង ឃើញគាត់អ៊ីចឹង ត្រង់គាត់និយាយលេងសើចហ្នឹង កម្រមាន បាទ ។

**ស៖** តើលោកអាចនិយាយបានទេថា នៅពេលនោះគាត់ចង់ធ្វើឱ្យអ្នកផ្សេងមានការពេញចិត្តនឹងគាត់ ហើយនិងគាត់ចង់ធ្វើឱ្យសិស្សពេញចិត្តគាត់ ហើយចង់ឱ្យបុគ្គលិកសិក្សាចូលចិត្តគាត់ ឬក៏គាត់ចង់ផ្គាប់ចិត្តអ្នកទាំងអស់នោះ ដើម្បីឱ្យគាត់ចូលរួមរស់ក្នុងការងារស្រួលបួលជាមួយពួកគេបាននោះ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ហ្វេង់ស្វ័រ រូ ។

[១០:៤០:២៣]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន សូមលោកវំឭករួចហើយថា មិនឲ្យសួរសំណួរដល់សាក្សី អំពីការសន្និដ្ឋានរបស់សាក្សីថាតើគាត់សន្និដ្ឋាន ថាតើអាកប្បកិរិយារបស់ជនជាប់ចោទ ដើម្បីផ្កាប់ចិត្តអ្នកដទៃនោះអានេះជាសំណួរដើម្បីឲ្យសាក្សី ធ្វើសេចក្ដីសន្និដ្ឋាន ។ ដូច្នេះ សូមលោកប្រធានមេត្តារំឭកសហព្រះរាជអាជ្ញា កុំឲ្យគាត់សួរសំណួរនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ការកត់សម្គាល់របស់មេធាវីការពារក្ដី ជាការត្រឹមត្រូវ ហើយសំណួរនេះជនជាប់ចោទ-- អ៎ន៎េ សាក្សីមិនបាច់ឆ្លើយទេ ។ ហើយតំណាងសហព្រះរាជអាជ្ញាដូរសំណួរ ហើយពេលវេលាដូចជាអស់

ហើយសម្រាប់សហព្រះរាជអាជ្ញា ។

**សួរដោយលោក វាំងសង់ ដឺវ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ខ្ញុំមានសំណួរចុងក្រោយមួយ សហសេរិកខ្ញុំបានសួរទៅលោកពីមុនថា តើលោកយល់ដូចម្ដេចនៅពេលដែលលោកដឹងថា លោក ហង់ ពិន ដែលលោកតែងសរសើរ ហើយនិងយល់ទទួលស្គាល់ពីគុណសម្បត្តិរបស់គាត់ ប៉ុន្តែក្រោយមកលោកដឹងថា ឌុច ជាអ្នកធ្លាប់បានប្រព្រឹត្ត ទទួលនូវបទឧក្រិដ្ឋមួយចំនួនក្នុងអតីតកាល ។ តើលោកមានអារម្មណ៍ថា លោកត្រូវបានលោក ហង់ ពិន ហ្នឹងក្បត់ចិត្តលោកដែរឬទេ នៅពេលដែលលោកបានដឹងថា លោក ហង់ ពិន ហ្នឹងលោកស្គាល់ជាមនុស្សមួយដែលថាលោកសរសើរទទួលស្គាល់គាត់? តើលោកមានចិត្តដូចម្ដេចនៅពេលដែលលោកគិតត្រលប់ទៅក្រោយដែលលោកបានធ្វើការជាមួយគាត់ ហើយលោកស្គាល់អំពីអាកប្បកិរិយា និងអត្តចរិតរបស់គាត់នោះ?

**ឆ៖** ដូចខ្ញុំជម្រាបប្រសាសន៍នៅមុនហើយថា កាលដែលគាត់នៅធ្វើការជាមួយខ្ញុំ ឃើញថាការងារគាត់នោះ វាគួរឲ្យកត់សម្គាល់បាទ ហើយជាយកការបាន ។ គាត់ទំនាក់ទំនងគ្នាអីមិនកោងកាចមិនអីទេ គាត់ធ្វើហ្នឹង បានដល់យើងដឹងថា គាត់ជាមេដឹកមួយដ៏ខ្ពស់នៅក្នុងរបបហ្នឹង ខ្ញុំក៏ចាប់ផ្ដើមមានអារម្មណ៍តក់ស្លុតដែរ ដល់ពេលដឹងអ៊ីចឹងតក់ស្លុតខ្លួនឯងបាទ តែប៉ុណ្ណឹង ។

**ស៖** តើលោកក្រោយពីបានដឹងហ្នឹងហើយ តើលោកសុបិនអាក្រក់ដែរឬទេនៅពេលដែលលោកជួបមនុស្សម្នាក់ដែលលោកទុកចិត្តគាត់ ដោយដឹងថា គាត់ធ្វើការងារល្អ ប៉ុន្តែក្រោយមកដឹងថា គាត់ជាអ្នកប្រព្រឹត្តនូវបទឧក្រិដ្ឋមួយចំនួន នៅក្នុងរបបខ្មែរក្រហមនោះ?

**ឆ៖** ទាក់ទងនឹងជំនឿ បាទ ។ អ៊ីចឹង ចេះតែមានអារម្មណ៍ដែរ ប៉ុន្តែអានេះដែរពេលអ៊ីចឹង ដល់ពេលមកដូចមានថ្ងៃនេះផងទៅ ខ្ញុំចេះតែមានអារម្មណ៍ថា ពីបញ្ហារបបមួយហ្នឹងដែលគេប្រជាពលរដ្ឋទូទាំងកម្ពុជាដែលគេស្អប់ខ្ពើម នៅពេលដែលបានជួបគាត់អ៊ីចឹងចេះតែមានអារម្មណ៍ភ័យដែរ ព្រោះភ័យអារឿងបញ្ហាសុវត្ថិភាពខ្លួនឯងផ្ទាល់ហ្នឹង ដែលមកអង្គុយថ្ងៃនេះ ព្រោះនៅតំបន់យើងនោះជាតំបន់ ពិតមែនតែសព្វថ្ងៃវាមានសុវត្ថិភាពបរិបូណ៍មែន ប៉ុន្តែយើងចេះតែនៅខ្លាចមជ្ឈដ្ឋានទូទៅគេរិះគន់ខ្លះដែរបាទបញ្ហាហ្នឹង ។

**ប្រធានអង្គជំនុំ៖**

អស់ពេលហើយលោកតំណាងសហព្រះរាជអាជ្ញា បង្កើនពេលបន្ថែមក៏អស់ហើយដែរ ។

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកសួរទៀតទេ ហើយឥឡូវនេះក៏អស់នូវ *ឌីវីឌី* សម្រាប់ថតសំឡេង និងរូបភាពផង អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំពីរនាទី ចាប់ពីពេលនេះរហូតដល់ម៉ោងដប់មួយគត់ សូមអញ្ជើញចូលវិញ ដើម្បីបន្តដំណើរការនីតិវិធីសវនាការ ។

ហើយមន្ត្រីតុលាការសម្របសម្រួល ផ្តល់កន្លែងសម្រាកសមរម្យដល់សាក្សីរូបនេះ ហើយឲ្យអញ្ជើញគាត់មកកាន់សាលសវនាការឲ្យបានមុនម៉ោងដប់មួយ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១០:៤៥នាទី ដល់ម៉ោង ១១:០៦នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើការនីតិវិធីសវនាការ ហើយជាកិច្ចបន្តនេះ អង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសអាចសួរសំណួរដល់សាក្សីរូបនេះប្រសិនបើជាមាន ។ សូមអញ្ជើញ ។

**តាំងសំណួរដោយមេធាវីការពារក្តី**

**សួរដោយលោក ការ សាវុត្ថ៖**

**ស៖** សូមអរគុណនិងសូមគោរពលោកប្រធាន ។ ជម្រាបសួរលោក ប៉េង ពាន់ ខ្ញុំសូមឲ្យលោកបញ្ជាក់ជូនអង្គសវនាការ ថាតើមុខរបរ ក្រៅពីមុខរបរគ្រូបង្រៀននៅសាលាផ្កាំ លោក ហង់ ពិន ហ្នឹង

មានមុខរបរអ្វីផ្សេងទៀតក្នុងគ្រួសាររបស់លោក ពីព្រោះថា ដូចលោកបានជម្រាបប្រាប់អង្គសវនាការ ហើយថា គាត់ជាគ្រូស្ម័គ្រចិត្ត ហើយជំនាន់នោះ៨៣ ទៅ៨៥ហ្នឹង មិនទាន់មានលុយកាក់អីផ្គត់ផ្គង់ឧបត្ថម្ភដល់គ្រូទេ ។ អ៊ីចឹង កាលគាត់ទៅបង្រៀននេះ អត់មានប្រាក់ខែ ប្រាក់ថ្ងៃអីទេ អ៊ីចឹងខ្ញុំចង់ដឹងថា តើក្រៅពីមុខរបរគ្រូបង្រៀនហ្នឹង តើលោក ហង់ ពិន ដែលជាបុគ្គលិករបស់លោកហ្នឹង មានមុខរបរអីផ្សេងក្រៅទៀតទេ?

[១១:០៨:០៥]

**ឆ៖** បាទ, សូមជម្រាបប្រសាសន៍! លោកមេធាវី ហើយមុខរបរគាត់ហ្នឹង ដែលខ្ញុំឃើញជាក់ស្តែងខ្ញុំឃើញគាត់ធ្វើស្រែ ធ្វើស្រែផង ហើយនិងឃើញគាត់លក់ដូរបន្តិចបន្តួចនៅក្នុងផ្ទះតែប៉ុណ្ណឹងទេ ។

**ស៖** សូមអរគុណលោក ។ ទីពីរ លោកបានជម្រាបប្រាប់អង្គសវនាការថា ជំនាន់នោះនៅក្នុងតំបន់របស់លោកហ្នឹង វាច្រើនតែមានចោរប្លន់អ៊ីចឹង ។ អ៊ីចឹង ខ្ញុំចង់ដឹងថា ចោរប្លន់នៅដែលជាញឹកញាប់ហ្នឹង តើមានសម្លាប់អ៊ីចឹងដែរ ឬក៏អត់ទេ? ឲ្យតែប្លន់ គេដឹងតែពីចាក់សម្លាប់អ៊ីចឹងយ៉ាងម៉េច? សូមលោកបញ្ជាក់មើល៍?

**ឆ៖** បាទ, ប្លន់ដែលមានមុនៗមក ហើយចួនកាលមិនបានជាសម្លាប់ទេ គ្រាន់តែធ្វើទារុណកម្មលោក ធ្វើទារុណកម្មខ្លះ ធ្វើទារុណកម្ម ។ ប៉ុន្តែ ដល់ឃើញគាត់ហ្នឹងក៏ចាក់សម្លាប់ មិនដឹងជាយ៉ាងម៉េចដែរ ។

**ស៖** ដែលខ្ញុំសួរលោកនេះ ខ្ញុំចង់ដឹងថា វាប្លន់ពីមុនៗមក វាគ្រាន់តែ ធម្មតាទេចោរប្លន់ វាត្រូវតែរ៉ៃ រ៉ៃហើយវាយក វាអត់មានសម្លាប់ទេ ។ តែបែរមកដល់តាឌុចនេះ លោក ហង់ ពិន នេះ វាបែរជាចាក់សម្លាប់ប្រពន្ធផង រកសម្លាប់គាត់ទៀត ប៉ុន្តែវាគាត់សំណាងល្អ អត់ស្លាប់ ។ អ៊ីចឹងខ្ញុំ ក្រែងលោលោកដឹង លោកដឹងថាម៉េច ដឹងថាអាចោរប្លន់ហ្នឹង វាមិនមែនប្លន់ធម្មតា ដូចគេ ដូចឯងនោះទេ ក្រែងលោពួកខ្មែរក្រហម ឬក៏ពួកប៉ុល ពត អីតាមសម្លាប់គាត់ ខ្ញុំចង់ដឹងអ៊ីចឹងទេ លោកអាចជម្រាបអង្គសវនាការបានទេ?

[១១:១០:១៥]

**ឆ៖** បាទ, ខ្ញុំមិនអាចជម្រាបបានទេ លោក បាទ មិនអាច ។

**ស៖** សូមអរគុណ ។ អ៊ីចឹងតាមលោកដឹង ចាប់ពីឆ្នាំ១៩៨៣រហូតដល់៨៥ យូរដែរ លោក ហង់ ពិន ហ្នឹងជាបុគ្គលិក ជាគ្រូបម្រើការនៅក្រោមការគ្រប់គ្រងរបស់លោក អ៊ីចឹងខ្ញុំចង់ដឹងថា តើទឹកចិត្ត

របស់គាត់ចំពោះសិស្ស ចំពោះគ្រូដូចគ្នាយ៉ាងម៉េច ចំពោះប្រជាជនអីក៏ដោយ បើលោកដឹង យ៉ាងម៉េច? ហើយទាំងគ្រូ ទាំងសិស្ស ទាំងប្រជាជនដែលនៅម្តុំនោះ តើមានការទឹកចិត្តគេនោះ ចំពោះគាត់ ចំពោះលោក ហង់ ពិន ហ្នឹងយ៉ាងម៉េចដែរ? បើលោកដឹង សូមលោកជួយបញ្ជាក់ ។ សូមអរគុណ ។

**ឆ៖** បាទ, ខ្ញុំសូមជម្រាបបញ្ជាក់ចុះលោកគ្រូ ខ្ញុំមិនដល់ប្រជាជនទេ ខ្ញុំនិយាយតែរឿងគ្រូ និងសិស្ស ព្រោះសិស្សដែលគាត់បានបង្រៀន ឃើញថាសិស្សហ្នឹងស្រឡាញ់គាត់ច្រើន រហូតដល់សិស្សទាំងអស់ហ្នឹងហៅគាត់ថា គ្រូតា១ អ៊ីចឹង ។ ទាំងគ្រូយើងហ្នឹងដូចដែរ ក្រោយពេលដែលគ្រូយើងមួយចំនួនខ្លះដែរ ដែលគាត់នៅអាភាពស្រពិចស្រពិលនៅលើកិច្ចការបង្រៀនរបស់ក្មេង គាត់ក៏បានផ្តល់អនុសាសន៍ អ៊ីចឹងឃើញថា គ្រូទាំងអស់ហ្នឹងមានទំនាក់ទំនងល្អជាមួយគាត់ដែរ ។ សូមជម្រាបប៉ុណ្ណេះ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកដែលលោកបានជួយបញ្ជាក់ប្រាប់អង្គសវនាការ ហើយយើងខ្ញុំអស់សំណួរហើយលោកប្រធាន ។ ហើយសូមលោកប្រធានប្រគល់នាទីនេះ ជូនលោកមេធាវីការពារអន្តរជាតិដើម្បីសួរបន្ត ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារក្តីអន្តរជាតិ ។

**សួរដោយលោក ហ្វ្រង់ស្វ័រ រូ៖**

**ស៖** សូមអរគុណលោកប្រធាន ។

អរុណសួស្តីលោកសាក្សី ។ ខ្ញុំនឹងមិនសូមឲ្យលោកឆ្លើយនៅអ្វីដែលលោករៀបរាប់ហើយនោះទេ ប៉ុន្តែខ្ញុំបានដឹង ហើយនិងយល់ លោកបានគិតថា ហង់ ពិន ធ្វើការងារយ៉ាងល្អនៅក្នុងសាលា ហើយលោកមានទំនាក់ទំនងល្អជាមួយនឹងគាត់ ។ តើលោកបាននិយាយអ៊ីចឹងដែរឬទេ?

[១១:១៣:០៤]

**ឆ៖** បាទ, មុនហ្នឹងខ្ញុំនិយាយដែរ និយាយថា គាត់ធ្វើការល្អ ខ្ញុំមានទំនាក់ទំនងដ៏ល្អនឹងគាត់ដែរ។

**ស៖** នៅពេលដែលលោកឆ្លើយសំណួររបស់ខាងសហព្រះរាជអាជ្ញា លោកបានឆ្លើយថា ក្នុងពេលដែលគេចាប់ខ្លួនគាត់ហ្នឹង គឺលោក ឌុច ហ្នឹង គឺលោកមានការភ្ញាក់ផ្អើលណាស់នៅពេលដែលលោកបានដឹងថា លោក ហង់ ពិន នោះជាអតីតប្រធានស-២១ ។ តើលោកពិតជាមានអារម្មណ៍ភ្ញាក់ផ្អើលអ៊ីចឹងដែរឬទេនៅពេលដែលគេចាប់គាត់?

**ឆ៖** បាទ, ពិតមែន ភ្ញាក់ផ្អើល មិនគួរឲ្យជឿ ។ បាទ, ខ្ញុំភ្ញាក់ផ្អើលដែរ ។

**ស៖** ដូច្នេះខ្ញុំអាចនិយាយថា លោកស្ទើតែមិនជឿ ដោយសារតែលោកស្គាល់គាត់តាំងពីមុន ហើយលោកគិតថា ដូចជាមិនអាចកើតឡើងអ៊ីចឹងទេ ដែលថាគាត់អាចជាប្រធានមន្ទីរស-២១ នោះ លោកពិតស្ទើតែមិនជឿទៅលើស្ថានភាពហ្នឹង ។ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, សូមសួរម្តងទៀត ស្តាប់អត់បាន សូមម្តងទៀត ។

**ស៖** សូមអភ័យទោស! លោកមានការតក់ស្លុតនិងភ្ញាក់ផ្អើល ដោយសារតែចំពោះលោក លោកសឹងតែមិនជឿ ដែលថាលោកជនជាប់ចោទហ្នឹង ដែលលោកស្គាល់ថា គាត់ធ្លាប់ធ្វើជាគ្រូ ហើយនិងលោកស្ទើតែមិនជឿថា គាត់ជាអតីតប្រធាននៅមន្ទីរស-២១ ។ ចំពោះលោកហ្នឹង លោកស្ទើតែមិនជឿតែម្តងថាគាត់ហ្នឹង គឺជាអតីតប្រធានស-២១ ថាលោកពិតជាមានការភ្ញាក់ផ្អើល និងតក់ស្លុតបែបហ្នឹងទេ នៅពេលដែលលោកដឹងទៅលើស្ថានភាពហ្នឹង?

**ឆ៖** បាទ, ខ្ញុំតក់ស្លុតពិតប្រាកដមែន ព្រោះដោយសារតែកាលពីគាត់ធ្វើការងារជាមួយខ្ញុំ ឃើញថា គាត់សុភាពរាបសាធម្មតា ដល់ពេលគាត់ ឮថាគាត់ជាប្រធានទៅ ខ្ញុំចេះភ្ញាក់ផ្អើល ព្រោះថាភ្ញាក់ផ្អើលខ្លាំងមែនទែន ។

**ស៖** ហើយលោកក៏បានឆ្លើយជូនអង្គជំនុំជម្រះផងដែរ ថាលោកពិតជាមានការតក់ស្លុត និងភ្ញាក់ផ្អើល ។ ហើយនៅពេលនេះ លោកនៅតែមានការតក់ស្លុត និងភ័យខ្លាចនៅពេលដែលលោកគិតអំពីរបបខ្មែរក្រហមហ្នឹង ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ, ព្រោះធម្មតាដែលខ្ញុំ មួយវ័យខ្ញុំនេះ វ័យកំពុងស្ថិតនៅក្នុងរបបហ្នឹង អ៊ីចឹងហើយលំបាកលំបិនទាំងឡាយ គឺខ្ញុំដឹងទាំងអស់ បាទ ជួរចត់ អ៊ីចឹងបានខ្ញុំតក់ស្លុត ។

**ស៖** តើខ្ញុំយល់ត្រឹមត្រូវដែរឬទេថា លោកអាចជំនះទៅលើការភ័យខ្លាចទាំងអស់នោះ ដើម្បីអាចឲ្យលោកមកក្នុងថ្ងៃនេះ ផ្តល់នូវចម្លើយហ្នឹង ។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, លោកពិតជាយល់ដូចអ៊ីចឹងមែន ព្រោះថាការតក់ស្លុតរបស់ខ្ញុំវានៅតែមាន ប៉ុន្តែហើយការមក ខ្ញុំចេញមកធ្វើសាក្សីកាលហ្នឹង ខ្ញុំត្រូវតែមកបង្ហាញដើម្បីឲ្យដឹងពីការពិត ។ ការពិតខ្ញុំវាតក់ស្លុតមែនបាទ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកសាក្សី ខ្ញុំសូមសម្តែងនូវការអរគុណចំពោះលោក ហើយលោកប្រធានខ្ញុំអស់សំណួរ

ហើយ ។

សូមអរគុណលោកដែលបានធ្វើដំណើរមកចូលផ្តល់សក្ខីកម្ម ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអរគុណលោក ប៉េង ពាន់ ដែលបានអញ្ជើញចូលរួមនៅក្នុង-- ផ្តល់សក្ខីកម្មនៅក្នុងដំណើរការសវនាការ ទៅតាមការកោះហៅរបស់អង្គជំនុំជម្រះ ។ ហើយឥឡូវនេះដំណើការនៃការស្តាប់នូវសក្ខីកម្មរបស់លោក ឃើញថាដល់ទីបញ្ចប់ហើយ ។ ដូច្នេះលោកអាចត្រលប់ទៅលំនៅដ្ឋានវិញបាន ឬក៏លោកអាចចង់បន្តដំណើរការពិនិត្យមើលដំណើរការសវនាការ គឺលោកអាចទៅអង្គុយនៅកន្លែងសាធារណជន ដើម្បីអាចមើលដំណើរការសវនាការបាន ប្រសិនបើលោកចង់ ។

មន្ត្រីតុលាការអញ្ជើញគាត់ ដើម្បីត្រលប់ទៅទំនាក់ទំនងជាមួយនឹងការិយាល័យគាំពារសាក្សី និងអ្នកជំនាញ ដើម្បីសមស្របសម្រួលឲ្យការិយាល័យនោះរៀបចំជូនគាត់ទៅលំដ្ឋានរបស់គាត់វិញ ។

ជាកិច្ចបន្ត គឺអង្គជំនុំជម្រះបន្តដំណើរការសួរសំណួរពាក់ព័ន្ធទៅនឹងចរិតចំពោះជនជាប់ចោទ ។ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទមកកាន់ឈើរាំងរវងក្រចកសេះ សម្រាប់ជនជាប់ចោទនៅចំពោះអង្គជំនុំជម្រះ ។

*(ជនជាប់ចោទចូលមកកាន់កៅអីរវង់ក្រចកសេះ)*

មុននឹងបន្តនីតិវិធីសួរចម្លើយជនជាប់ចោទអំពីអត្តចរិត ។ អង្គជំនុំជម្រះផ្តល់ឱកាសដល់ជនជាប់ចោទនៅក្នុងការធ្វើការកត់សម្គាល់ ចំពោះសក្ខីកម្មរបស់សាក្សីបញ្ជាក់អំពីចរិតទាំងប្រាំមួយរូប ដែលបានមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ ដូចអ្វីដែលបានអង្គជំនុំជម្រះបានជម្រាបជូនចំពោះជនជាប់ចោទកាលពីម្សិលមិញ ប្រសិនបើជនជាប់ចោទធ្វើការកត់សម្គាល់នូវសក្ខីកម្មទាំងនោះ។ សូមអញ្ជើញ។

[១១:២១:៥៦]

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! ដំបូងខ្ញុំសូមបញ្ជាក់ជូនមួយមាត់ថា ខ្ញុំសូមឯកភាពជាមួយនឹងសក្ខីកម្មរបស់សាក្សីទាំងប្រាំមួយនាក់នេះ ។ បន្ទាប់ទៅទៀត ខ្ញុំគ្រាន់តែសុំបែកចែកថា សាក្សីទាំងប្រាំមួយរូបនេះ អាចចែកចេញជាបីក្រុម ។ ក្រុមទីមួយ មានតែមួយម្នាក់ទេ គឺ ស៊ូ សាត ដែលមានអាយុចាស់ជាងគេ ហើយស្គាល់មជ្ឈដ្ឋានសង្គមច្រើនជាងគេ ។ បន្ទាប់មកទៀត មានពីរនាក់ គឺកូនសិស្សខ្ញុំ ហើយចុងបំផុតមានបីនាក់ដែលជាគ្រូមានអាយុច្រើន ដែលជាមនុស្សដែលគេរស់នៅក្នុងមជ្ឈដ្ឋានភូមិឃុំរបស់គេ

ស្រុកកំណើតរបស់គេតាំងពីដើមរៀងរហូតមកដល់ពេលនេះ ។ ហើយគេធ្វើការភាគច្រើន ក្រោយឆ្នាំ ១៩៧៩ នៅក្នុងរដ្ឋាភិបាល ។

ដូច្នេះមតិរបស់គេទាំងអស់ វាសម្តែងនូវឆន្ទៈរបស់គេ ។ ការមើលឃើញរបស់គេចំពោះរូបខ្ញុំ ។ ខ្ញុំសូមសរុបប៉ុណ្ណេះ ។ សូមគោរព ។

**តាំងសំណួរដោយប្រធានអង្គជំនុំ**

**សួរដោយប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត គឺនីតិវិធីក្នុងការសួរ ដោយសារពេលមុន គឺអង្គជំនុំជម្រះបានជនជាប់ចោទធ្វើសេចក្តីថ្លែងរៀបរាប់អំពីដំណើរជីវប្រវត្តិរបស់លោករួចហើយ ។ ហើយនីតិវិធីត្រូវបានផ្អាក ដោយសារតែមូលហេតុពេលវេលា ឥឡូវនេះយើងបន្ត ។ សំណួរមួយចំនួនពាក់ព័ន្ធជាមួយនឹងជនជាប់ចោទ ។

**ស៖** សំណួរទីមួយ តើហេតុផលយ៉ាងដូចម្តេចទៅដែលនាំលោកនឹងធ្វើការផ្លាស់ប្តូរឈ្មោះ ពីឈ្មោះ ឌុច ដែលជាឈ្មោះបដិវត្តន៍របស់លោក ទៅជាឈ្មោះ ហាង់ ពិន?

អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកជនជាប់ចោទអង្គុយចុះ ពីព្រោះការសួរចម្លើយនេះ មានពេលរយៈពេល ។

**ឆ៖** សូមគោរពលោកប្រធាន! នៅក្នុងឆ្នាំ១៩៨៥-៨៦ ខ្ញុំបង្រៀនថ្នាក់កុមារដ្ឋាន នៅសំឡូត មានកូនគេ មានកូនខ្ញុំ ។ ហើយនៅថ្ងៃ នៅក្នុងខែមិថុនា ១៩៨៦ នេះ មេខ្ញុំណែនាំតាមមុខសញ្ញា គឺ ស៊ូ ម៉េត នេះថាឲ្យសួរចិត្តខ្ញុំមើល នៅសំឡូតតនៅទៀត ឬក៏នៅក-១៨ ជាមួយគាត់ ។ បើសម្រេចថានៅក-១៨ ជាមួយនឹងគាត់ មេខ្ញុំលោកគ្រូ សុន សេន នេះ ឲ្យខ្ញុំប្រែឈ្មោះ នេះផ្តាំតាម ស៊ូ ម៉េត អ៊ីចឹង ។ ខ្ញុំឆ្លើយថា ខ្ញុំទៅ ហើយឈ្មោះប្រែហ្នឹង ខ្ញុំបានជម្រាបទៅមេខ្ញុំ គឺលោកគ្រូ សុន សេន តាម ស៊ូ ម៉េត ថាខ្ញុំសូមប្តូរឈ្មោះពី ឌុច ទៅជា ពិន ។

[១១:២៦:១៣]

សូមបញ្ជាក់ថារឿងនេះ ពីលើកមុនខ្ញុំដាក់ឈ្មោះ ឌុច សិស្សល្អ នៅក្នុងសៀវភៅ ថ្នាក់វចនថានដដែលហ្នឹង ឈ្មោះ ពិន ហ្នឹង ជាសិស្សខ្ជិល ដូច្នេះខ្ញុំយកឈ្មោះមនុស្សខ្ជិលវិញ ។ នេះនិយាយម្យ៉ាង ក៏ប៉ុន្តែម្យ៉ាងទៀត ពិន ។ “ព+ិ និង ន” នេះ ក្នុងវចនានុក្រមខ្មែរពុទ្ធសាសនបណ្ឌិត ដែលយើងធ្លាប់ហៅថា វចនានុក្រមសម្តេច ជួន ណាត ។ ពិន ប្រែថា កំពូល ដូច្នេះខ្ញុំក៏យកឈ្មោះ ពិន ហ្នឹងទៅ ។ ឯបញ្ហាត្រកូល ខ្ញុំពិបាកបំផុតនឹងរឿងជ្រើសរើសត្រកូលហ្នឹង មិនបានយកត្រកូលមាស ដែលជាៗជីតាខ្ញុំខាង

ម្តាយទេ ពីព្រោះទំនៀមទំលាប់មិនអនុគ្រោះឲ្យខ្ញុំធ្វើអ៊ីចឹង ។ ដូច្នេះ ខ្ញុំយកខ្សែរបស់ខ្ញុំ ព្រោះខ្ញុំជាកូនចៅចិន ។ ខ្សែពិតរបស់ខ្ញុំ គឺអាំង ភាសាហុកគៀងហៅថា "អាំង" ។ ភាសាតាជីវ ហើយនិងកុកងឺហៅថា "ហុង" ។ ខ្ញុំក៏ដាក់ ហុង ប៉ុន្តែ មិនឲ្យហុងចំពេកទេ ដាក់ "ហង់" ។

ដូច្នេះ ប្រវត្តិដែលប្រែពី ឌុច ទៅជា ហង់ ពិន វាមានការទាក់ទងរវាងខ្ញុំ និងមេខ្ញុំលោកគ្រូ សុន សេន ក្នុងបរិយាកាសមួយដែលគាត់ត្រូវការខ្ញុំ ទៅនៅជាមួយនឹងគាត់ ដើម្បីបញ្ជូនទៅនៅប្រទេស ទៅបង្រៀនអក្សរខ្មែរដល់កូនចិន ។ នេះសូមបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** ចំណុចទីពីរ សំណួរទីពីរ ថាអម្បាញ់មិញនេះ និងសាក្សីមុនៗនុ៎ង គឺមានការមិនប្រាកដប្រជាលើបញ្ហានៃកាលបរិច្ឆេទ ដែលលោកទៅធ្វើការងារជាគ្រូនៅអនុវិទ្យាល័យផ្កាំ ហើយការចាប់ផ្តើមចូលធ្វើការ ហើយនិងថ្ងៃដែលលោកបោះបង់ការងារនៅទីនោះ ហើយចាកចេញពីស្រុកស្វាយចេក មកនៅតាមគោលដៅផ្សេង ។ តើលោកបានចូលបម្រើនៅក្នុង ជាគ្រូបង្រៀន ឬក៏ជាបង្រៀនដោយស្ម័គ្រចិត្តដំបូងឡើយនៅអនុវិទ្យាល័យផ្កាំនុ៎ង ចាប់ពីពេលខែឆ្នាំណា? ហើយលោកធ្វើការងារនៅទីនោះ បានរយៈពេលប៉ុន្មាន? ដល់ពេលណាទើបលោកត្រូវបានអនុញ្ញាតមកបម្រើការងារនៅអប់រំស្រុកស្វាយចេក? ហើយនិងអំឡុងពេលណាទើបលោកទៅធ្វើការងារនៅអនុវិទ្យាល័យស្វាយចេក?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! កាលដែលខ្ញុំសុំចូលក្នុងក្របខ័ណ្ឌគ្រូបង្រៀននេះ ហើយបានចូលទៅបង្រៀនជាគ្រូស្ម័គ្រចិត្តដំបូង មិនទាន់មានប្រាក់ខែ មិនទាន់មាននេះ គឺខ្ញុំចាប់ផ្តើមបង្រៀននៅឆ្នាំ-- បើតាមខ្ញុំចាំនៅឆ្នាំ១៩៩៣ ។ ប៉ុន្តែតាមខ្ញុំចាំដែរ ក្នុងអេតាដែលទទួលស្គាល់ខ្ញុំហ្នឹង ដូចជាអង់ទីដាតទែរ-- ដាក់ពេលវេលាទៅមុខៗទៅទៀត ដូចជាទៅក្នុងឆ្នាំ១៩៩២ ខែកក្កដា ឯណោះ ។ នេះជាបញ្ហាមួយ ។

បញ្ហាទីពីរ កាលវេលាដែរ ដែលខ្ញុំត្រូវចោរប្លន់ អើយយើងហៅថា ចោរប្លន់ ជាបណ្តោះអាសន្នសិនទៅចុះ ពីព្រោះក្រោយមក ខ្ញុំសន្និដ្ឋានទៅផ្សេងតាមការវិភាគ ។ ការដែលប្រពន្ធស្លាប់ ហើយខ្ញុំត្រូវគេចាក់ត្រង់ស្លាបប្រចៀវនេះ នៅស្នាមទើសឥឡូវនេះ គឺនៅថ្ងៃ១១ ខែវិច្ឆិកា ១៩៩៥ ។ ប្រពន្ធខ្ញុំស្លាប់ ខ្ញុំក៏ត្រូវចូលទៅមន្ទីរពេទ្យបង្អែករបស់ស្រុកថ្មពួក ដើម្បីព្យាបាលបានកន្លះខែ ខ្ញុំចេញមកវិញ ហើយក៏មានការជ្រោមជ្រែងអំពីលោក ប៉េង ពាន់ អំពីលោក សឹម ភឿន ប្រធានការិយាល័យអប់រំស្រុកជំនាន់នោះ ហើយនិង ជូ វិន ម្សិលមិញនេះ បានផ្លាស់ឲ្យខ្ញុំនៅស្វាយចេកទីតាំងដែលមានសុវត្ថិភាព ។

[១១:៣១:៣៣]

ដូច្នេះ កាលបរិច្ឆេទដែលចេញពីផ្កាំទៅស្វាយចេក គឺក្រោយពេលចោរប្លន់ ដូច្នេះប្រហែលក្នុងថ្ងៃដាច់ខែ១១ ដាច់ខែវិច្ឆកា ១៩៩៥ ។

ឯចំណែកថ្ងៃដែលខ្ញុំចេញពីការិយាល័យអប់រំស្រុក ទៅបម្រើការងារជាសាស្ត្រាចារ្យភាសាបារាំង ជាគ្រូភាសាបារាំង នៅអនុវិទ្យាល័យស្វាយចេក ខ្ញុំជឿថា ជូ វិន ហើយនិង ហ៊ុន ស្មៀន គេចាំច្បាស់ជាងខ្ញុំ ខ្ញុំអត់ទេ ខ្ញុំទទួលស្គាល់កំណត់ដែលគេកត់ត្រានេះ គឺថ្ងៃ២៨ ខែតុលា ឆ្នាំ១៩៩៦ ។ ហើយថ្ងៃខែដែលខ្ញុំចេញពីស្វាយចេកទៅសំឡូតនេះ បើតាមខ្ញុំចាំ ប្រហែលអាចនៅក្នុងខែ៦ ឬខែ៧ ឯណោះទៅវិញទេ ។ នេះ ខ្ញុំសូមបញ្ជាក់កាលបរិច្ឆេទនៃការផ្លាស់ប្តូរទីតាំងរបស់ខ្ញុំប៉ុណ្ណោះ ។ សូមបញ្ចប់ដោយគោរព ។

**ស៖** លោកនៅចងចាំទេ កាលពីលោកចូលមកធ្វើគ្រូ ដំបូងឡើយធ្វើជាគ្រូស្ម័គ្រចិត្តនោះ តើការដែលសម្របសម្រួលក្នុងការចូលក្នុងក្របខ័ណ្ឌគ្រូបង្រៀនកាលនោះ តើលោកមកជម្រាបប្រាប់ដល់អង្គភាពអប់រំស្រុកហ្នឹងថាយ៉ាងម៉េច? ថាតើលោកហ្នឹង មកពីប្រភពណា? មកពីភាគីខាងណានៃកងកម្លាំងទាំងបួន មានរដ្ឋាភិបាល ហើយនិងត្រីភាគី តើលោកមាននិយាយប្រាប់ពីបញ្ហានេះទេ មកពីគណៈបក្សណាមួយ? ឬក៏លោកជម្រាបគេថាយ៉ាងម៉េច នៅក្នុងកាលដែលលោកសុំគេដើម្បីចូលធ្វើជាគ្រូក្នុងក្របខ័ណ្ឌនៅអនុវិទ្យាល័យផ្កាំនោះ?

[១១:៣៤:០៩]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ដំបូងខ្ញុំសូមបញ្ជាក់ថា ខ្ញុំត្រូវចាត់តាំងនៅផ្កាំ ដោយ សុន សេន ដើម្បីចាប់ផ្តើមរៀបចំមូលដ្ឋានសេដ្ឋកិច្ចសម្រាប់ជួរ តាមទ្រឹស្តីរបស់គេ គឺក្រោយប៉ារីស មានការបោះឆ្នោត កម្លាំងជួរត្រូវចែកចេញជាសេដ្ឋកិច្ចពីរ(២) ។ សេដ្ឋកិច្ចទីមួយ គឺសេដ្ឋកិច្ចប្រជាជន ឲ្យជួយអប់រំប្រជាជន ។ សេដ្ឋកិច្ចទីពីរ គឺសេដ្ឋកិច្ចជួរធ្វើសេដ្ឋកិច្ចខ្លួនឯង ដើម្បីចិញ្ចឹមជួរ ។ រកលុយចិញ្ចឹមជួរ ។ ខ្ញុំត្រូវគេចាត់តាំងមកនៅផ្កាំ ។

ឯចំណែកការចូលទៅបម្រើការងារនៅនឹង សុំពាក្យចូលទៅបម្រើការងារនៅក្រសួងសិក្សាធិការតាមរយៈក្រសួងរបស់រដ្ឋាភិបាលរដ្ឋកម្ពុជាជំនាន់នុ៎ង វាទៅជាការច្របាច់បញ្ចូលគ្នាដោយមានការឧបត្ថម្ភគាំទ្រពីអ្នកដែលស្គាល់ចិត្តថ្លើមខ្ញុំ ដូចជា ប៉េង ពាន់ គាត់បាននិយាយហើយ មានគាត់ មាន ឡូត ង៉ាត ហើយមានម្នាក់ទៀត គេអ្នកផ្គងផ្តើមឲ្យខ្ញុំទៅជួប តូច លន់ ប្រធានការិយាល័យអប់រំស្រុកជំនាន់នុ៎ង ខាង *អេសអិលប៉េកា (SLPK)* គឺខាងលោកតា សឺន សាន ខ្ញុំដាក់ឈ្មោះ ខាង *អេសអិលប៉េកា* ទេ ក្នុងការចូលក្របខ័ណ្ឌពេលនុ៎ង ។ តាមការអនុគ្រោះយោគយល់របស់ តូច លន់ ប្រធានការិយាល័យ

អប់រំស្រុកជំនាន់នុ៎ង ហើយបញ្ជូនពាក្យសុំនៅទៅដល់ក្រសួងសិក្សាធិការ ហើយបានក្រសួងផ្លាក់មកបាន បានខ្ញុំបានប្រាក់ខែទទួលទាន ដូច ប៉េង ពាន់ និយាយអ៊ីចឹង ។

[១១:៥៦:២៨]

**ស៖** តើលោកបានបោះបង់មុខរបរ ឬក៏បោះបង់ក្របខ័ណ្ឌជាគ្រូបង្រៀន ក្រោយពីលោកប្រឹងប្រែងធ្វើឲ្យមានការស្ម័គ្រចិត្តផង ហើយចំណាយពេលវេលាប្រឹងប្រែងជាច្រើនទម្រាំបានរៀបចំឲ្យលោកចូលនៅក្របខ័ណ្ឌគ្រូនៅអនុវិទ្យាល័យផ្តាំ ក៏ដូចជានៅក្នុងក្របខ័ណ្ឌអប់រំស្រុកស្វាយចេកកាលនោះ ហើយស្រាប់តែលោកបោះបង់ចោលនូវមុខរបរ នៅវិជ្ជាជីវៈដែលទើបតែចាប់ផ្តើមសាជាថ្មីឡើងវិញ ។ តើមានមូលហេតុអ្វីទៅ ហើយការបោះបង់នុ៎ងគឺនៅក្នុងអំឡុងថ្ងៃខែឆ្នាំណា? ហើយលោកធ្វើដំណើរទៅកាន់ទីណា?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! បញ្ហានេះវែង ព្រោះវាស្ថិតនៅក្នុងបរិបទនយោបាយនៃខ្មែរភាគីបួនទំនាស់គ្នា ។ ខ្ញុំចេញពីប្រភពកម្ពុជាប្រជាធិបតេយ្យមកបោះទីតាំងនៅផ្តាំ ដើម្បីរៀបចំសេដ្ឋកិច្ចស្រាប់ជួរក្រោយពីបោះឆ្នោតទៅ ។ ក៏ប៉ុន្តែ ដែលខ្ញុំទៅបោះទីតាំងនៅនុ៎ងមិនបានប៉ុន្មានថ្ងៃផង ក៏មានបញ្ហាមិនត្រូវគ្នា។ ខ្មែរក្រហមមិនប្រគល់ឲ្យអ៊ុនតាក់ដកអាវុធតាមសេចក្តីសន្យាក្នុងកិច្ចព្រមព្រៀងបារីសទេ ។ ប៉ុន្តែ មុននឹងខ្ញុំទៅដល់ផ្តាំមេខ្ញុំ ឲ្យខ្ញុំបោះទីតាំងនៅភូមិក្តិបថ្ម មិនដឹងស្រុកស្អីទេ បន្ទាយអំពិលមិនដឹង មិនដឹងអីទេ ប៉ុន្តែក្បែរភ្នំឆត្រ ។ នៅពេលដែលឃ្លាតឆ្ងាយបែបនេះ ហើយសភាពការណ៍បែបនេះហើយខ្ញុំជឿទុកចិត្ត អ៎! ខ្ញុំឃើញថា ខ្មែរក្រហមគ្មានលទ្ធភាពស្តារបរាជ័យរបស់ខ្លួនទេ ហើយឧក្រិដ្ឋកម្មរបស់ខ្លួនក៏ធ្ងន់ធ្ងរដែរ ។ ខ្ញុំរកផ្លូវចេញដែរ ។ ក៏ប៉ុន្តែ ក្នុងបរិបទនយោបាយដែលភាគីទំនាស់គ្នាយ៉ាងនេះម្ល៉ោងខ្ញុំក៏ត្រូវការពារខ្លួនដែរ កុំឲ្យខ្មែរក្រហមគេឃើញច្បាស់ពេកថា ខ្ញុំក្បត់គេ គេតាមម្ទេចនេះមួយ ។

[១១:៣៩:០៨]

ទីពីខ្ញុំក៏អត់ទាន់ជឿទុកចិត្តអ្នកណាដែរ ។ មែនតាមការសង្កេតរបស់ខ្ញុំជាយុទ្ធជនប្រយុទ្ធនៅក្នុងសមរភូមិខ្ញុំឃើញ ថាយុទ្ធរបស់រដ្ឋកម្ពុជាគេមានវិន័យ គេស្តាប់មេ ក៏ប៉ុន្តែមនុស្សដែលធ្លាប់បម្រើការងារក្នុងគណបក្សប្រជាជនេះ ដូច ប៉េង ពាន់ ដូច ឡូត ង៉ាត ដូច ជូ វិន ប៉ុន្តែ ជូ វិន ខ្ញុំស្គាល់ក្រោយមកទេ ដូច សឹម ភឿន អី ជាបុគ្គលជាឯកជន ខ្ញុំជឿទុកចិត្តថា គេជឿទុកចិត្តខ្ញុំ ក៏ប៉ុន្តែទៅពីលើទៀត ពីលើអ្នកអស់នុ៎ងទៀត ។ ខ្ញុំអត់ទាន់យល់ថាមាគ៌ានយោបាយរបស់បក្សប្រជាជនគេមានការអនុគ្រោះដល់ខ្មែរក្រហមចាស់ និយាយជារួម ហើយគេមានការអនុគ្រោះដល់ខ្ញុំ ខ្ញុំអត់ទាន់ជឿទេ ។ ដូច្នេះ វាស្ថិតនៅ

ក្នុងការមិនទាន់ច្បាស់លាស់ក្នុងចិត្ត ។ ខ្ញុំបានចូលទៅក្នុងក្រសួងអប់រំហ្នឹងក៏ខំរក្សាភាពនឹងនរបស់ខ្លួន ចៀសវាងគ្រោះថ្នាក់ដល់អាយុជីវិត ក៏ប៉ុន្តែធម្មតាវាចៀសមិនវាស្តាប់ប្រពន្ធបាត់ទៅហើយ នេះម្យ៉ាង ។

ដល់ខ្ញុំមកនៅស្វាយចេក ឆ្នាំ១៩៩៦ ហ្នឹង ដូចជាខែ៦ អង្កាល់នោះខ្ញុំដូចជាមិនទាន់របួសទេ ។ មើល! អ្អេ! របួសហើយខែ៦ លោកគ្រូ អៀង សារី ចុះចូលជាមួយរដ្ឋាភិបាលដែលយើងហៅថា ចលនាសមាហរណកម្មដំបូង ។ ខ្ញុំចង់ណាស់ ចង់ទៅរកភ្ជាប់ ។ ប៉ុន្តែ ម្យ៉ាងខ្ញុំអស់ស្គាល់លោកគ្រូ អៀង សារី សោះពីដើមមក ។ ដូច្នេះក៏ខ្ញុំមិនដឹងទៅរកគាត់នៅទីណាដើម្បីឲ្យបានភ្ជាប់ខ្លួនចូលមកក្នុងចលនាសមាហរណកម្មនឹងគេ ឲ្យវាច្បាស់លាស់ ហ្នឹងវាចប់មួយរឿងទៅ ។

នៅឆ្នាំ១៩៩៧ នេះ ដែលខ្ញុំនៅបង្រៀនសុខៗប្អូនពៅខ្ញុំដែលវានៅសំឡូតនោះ ខាងសំឡូត ខាង ស៊ូ ម៉េត នេះក៏ចុះចូលរដ្ឋាភិបាល បានសមាហរណកម្មនឹងគេដែរ ។ ហើយប្អូនខ្ញុំវាដឹងថា ស៊ូ ម៉េត មានការទទួលស្គាល់ច្បាស់លាស់ពីគណបក្សប្រជាជន មានជំនឿជឿទុកចិត្ត ។ ខ្ញុំថា អ៊ីចឹងមានផ្លូវហើយដែលត្រូវបង្ហាញខ្លួនជូនគណបក្សប្រជាជនតាមរយៈ ស៊ូ ម៉េត ។ ប្អូនខ្ញុំក៏មកយកខ្ញុំចេញពីស្វាយចេកនេះ ទៅនៅសំឡូត ទៅជួប ស៊ូ ម៉េត ។ ស៊ូ ម៉េត ក៏ទទួលស្គាល់ ហើយរៀបចំថានឹងបង្ហាញខ្ញុំជូនថ្នាក់ដឹកនាំគណបក្សប្រជាជន ស្រាប់តែ តាម៉ុក ឲ្យ មាស ម៉ុត ធ្វើរដ្ឋប្រហារម្តង នាំប្រជាជនចេញពីសំឡូតទៅនៅជំរំសាជាថ្មី គឺជំរំម៉ាក់មួងនេះ ទម្រាំតែបានចូលមកវិញនៅឆ្នាំ១៩៩៨ ចុងឆ្នាំហើយ ។ ស៊ូ ម៉េត រៀបរកនឹងបង្ហាញខ្លួនទៅដល់ដឹកនាំប្រជាជនក៏បែកការណ៍ ក៏ត្រូវរដ្ឋាភិបាលយកខ្ញុំមកទុកជាបណ្តោះអាសន្ននៅអយ្យការយោធារង់ចាំការកាត់ទោស ។

[១១:៤៣:១៤]

ដូច្នេះហើយបានជាមានការផ្លាស់ប្តូរចេញពីស្វាយចេកទៅនឹងសំឡូត ពីព្រោះបើមិននិយាយការពិត ខ្ញុំជឿថា មិនដែលស្ពឺវាស្ថិតនៅអាថ៌កំបាំងជារៀងរហូតទេ ។ ស្ពឺក៏ដោយវាស្ថិតនៅអាថ៌កំបាំងបានតែមួយរយៈទេ ។ ដូច្នេះវាក្នុងចលនានេះហើយដែលខ្ញុំប្រាស់ទៅសំឡូតចោលក្របខ័ណ្ឌដែលខ្ញុំបានទទួលហើយ ។ នេះខ្ញុំសូមបញ្ចាក់ជូនប៉ុណ្ណោះ ។

**ស៖** លោកចងចាំទេ ថាតើលោកបានបោះបង់ចោលការងារនៅស្វាយចេក ហើយលោកទៅរស់នៅនិងធ្វើការនៅស្រុកសំឡូតនោះនៅថ្ងៃណាខែឆ្នាំណាជាក់លាក់ដែរឬទេ? លោកនៅចងចាំដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ដែលខ្ញុំចេញពីស្វាយចេកទៅសំឡូត ខ្ញុំមិនចាំថ្ងៃខែច្បាស់ទេ ។ ក៏ប៉ុន្តែ ខ្ញុំចាំបានថា ខ្ញុំទៅដល់សំឡូតមិនបានប៉ុន្មានថ្ងៃវាមានរឿងរដ្ឋប្រហារនរោត្តម រណឫទ្ធិ

ទៅលើ ហ៊ុន សែន ។ ដូច្នេះរដ្ឋប្រហារនោះ មិនដឹងថ្ងៃណាទេ ខ្ញុំភ្លេចបាត់អស់ទៅហើយ ខ្ញុំចង់បញ្ជានេះជាគោល ។ ខ្ញុំទៅបានប្រហែលប្អូនប្រាំថ្ងៃដល់សំឡូតក៏មានកើតរឿងនុ៎ងឡើង ។

**ស៖** អ៊ីចឹងបានន័យថា លោកទៅនឹងគឺក្រោយពេលកម្លាំងខ្មែរក្រហមបានចាប់ផ្ដើមធ្វើសមាហរណកម្មមកចូលរួមជាមួយនឹងរាជរដ្ឋាភិបាលដែលមានទ្រង់ទ្រាយធំដំបូងបង្អស់នៅក្នុងខែ មិថុនា ឆ្នាំ១៩៩៦ ពិតអ៊ីចឹងមែនដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ពិត ។ ខ្ញុំចេញពីស្វាយចេកទៅសំឡូតនៅឆ្នាំ១៩៩៧ ។

**ស៖** ក្នុងអំឡុងពេលដែលមានការផ្ដាច់ខ្លួនសាជាថ្មីម្ដងទៀតនៃកម្លាំងនៅតំបន់ខាងភូមិភាគ--ខាងពាយព្យ គឺភូមិភាគ៥ ដែលលោកបាននិយាយអម្បាញ់មិញទាក់ទិនជាមួយនឹង មាស ម៉ុត ទាក់ទិនជាមួយនឹងមន្ត្រីខាងអតីតខ្មែរក្រហមមួយចំនួនបានផ្ដាច់ខ្លួនទៅកាន់កាប់នៅតំបន់សំឡូតឡើងវិញនោះ ។ សួរថាក្នុងអំឡុងពេលនោះ តើលោកនៅឯណា? លោកចងចាំនៅព្រឹត្តិការណ៍នុ៎ងទេ ហើយអង្កាល់នោះលោកនៅឯណា ហើយលោកធ្វើអ្វី?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ពេលដែលខ្ញុំទៅសំឡូតនេះ ខ្ញុំមានកន្លែងស្នាក់នៅពីរ ។ ខ្ញុំមិនទៅនៅជាមួយនឹងប្អូនពៅខ្ញុំទេ ខ្ញុំទៅនៅជាមួយនឹងក្មួយសាច់ថ្លៃ គឺក្មួយប្រពន្ធខ្ញុំ ពីព្រោះប្ដីវាជានីរសារជំនិតរបស់ ស៊ូ ម៉េត ។ នេះកន្លែងទីតាំងដែលខ្ញុំរស់នៅ ។ ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ចំពោះសំណួររបស់លោកប្រធានអម្បាញ់មិញ ។

[១១:៤៧:១៩]

**ស៖** យើងមិនទាន់យល់ច្បាស់ទេ ថាតើនៅព្រឹត្តិហេតុនៃការផ្ដាច់ខ្លួនសាជាថ្មីនៃអតីតកម្លាំងខ្មែរក្រហមកាលនោះ នៅកាន់កាប់នៅតំបន់សំឡូតនុ៎ង សួរថាតើលោកនៅតំបន់សំឡូតនៅទៅ ឬក៏លោកទៅតំបន់សំឡូតនឹងក្រោយពេលដែលមានព្រឹត្តិការណ៍នៃការផ្ដាច់ខ្លួនសារជាថ្មីនៃកម្លាំងអតីតខ្មែរក្រហមនៃតំបន់សំឡូត?

**ស៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំទៅដល់នុ៎ង ខ្ញុំទៅនៅផ្ទះនីរសាររបស់ ស៊ូ ម៉េត ។ ដំណឹងដែលថា តាម៉ុក មកត្រាត ក៏ខ្ញុំដឹង ។ ក៏ប៉ុន្តែ ស៊ូ ម៉េត ខ្លួនគាត់នុ៎ងថា មិនអីទេ ផងនៅហ្នឹងហើយខំតែធ្វើការទៅ ។ ខ្ញុំក៏ជឿថា មិនអីតាមគេ ។ ចៅហ្វាយស្រុកសំឡូតហ្នឹង ជិះម៉ូតូកាន់មុខផ្ទះខ្ញុំ ប្អូនពៅខ្ញុំហ្នឹង ប្រាប់ថា បងអើយខ្ញុំទៅបាត់ដំបូង យកកូនឲ្យនឹងប្រពន្ធទៅទុកសិន ខ្ញុំត្រលប់មកវិញទេ បងកុំទៅណា។ ខ្ញុំក៏នៅតាមបញ្ជា ស្រាប់តែព្រឹកស្អែកឡើងកងទ័ព មាស ម៉ុត នឹងទៅប្រមូលកៀរប្រជាជនចេញ

ពីសំឡូតយកទៅដាក់នៅជំរំជនភៀសខ្លួនពីរកន្លែង ។ មួយកន្លែងពួកចេញពីខាងសំឡូតទៅយកទៅដាក់នៅភូមិម៉ាក់មួង ។ មួយកន្លែងទៀតចេញពីខាងកោះកុង ខាងអីទៅយកទៅដាក់នៅភូមិសាលចៅ ។ ដូច្នេះកាលដែល មាស ម៉ុត ប៉ះបោរតាមបញ្ជារបស់ តាម៉ុក ផ្តាច់ខ្លួនសាជាថ្មីនេះក្រោយព្រឹត្តិការណ៍រដ្ឋប្រហារនរោត្តម រណឫទ្ធិ ទៅលើ ហ៊ុន សែន ។ ដូច្នេះប្រហែលជា ខែ៨ ខែ៩ បានខ្ញុំទៅដល់ម៉ាក់មួង ឆ្នាំ ១៩៩៧ ។ សូមគោរពជម្រាបលោកប្រធានប៉ុណ្ណេះ ។

**ស៖** អ៊ីចឹងបានន័យថា លោកបានចាកចេញពីស្វាយចេកទៅកាន់តំបន់សំឡូតនុ៎ង មុនពេលព្រឹត្តិការណ៍នៃការផ្តាច់ខ្លួនសាជាថ្មីរបស់កងកម្លាំងខ្មែរក្រហម អតីតខ្មែរក្រហមកាលនោះ ។ ពិតមែនដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ពិតណាស់ ។

**ស៖** តើលោកទៅនៅជំរំជនភៀសខ្លួនដែលលោកបាននិយាយអម្បាញ់មិញនេះ ដោយសារមានការគេកៀរប្រជាពលរដ្ឋសាជាថ្មីចុងក្រោយ ក្រោយពីមានការផ្តាច់ខ្លួនសារជាថ្មីនៃកម្លាំងអតីតកម្លាំងខ្មែរក្រហមកាលនោះ ។ តើលោកទៅនៅជំរំនោះអស់រយៈប៉ុន្មាន? ហើយពេលណាទើបលោកត្រលប់មកវិញ? ហើយលោកត្រលប់មកវិញលោកទៅរស់នៅទីណា?

[១១:៥០:៣៦]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំទៅដល់ជំរំម៉ាក់មួង ប្រហែលជាក្នុងខែប្រាំបួន ឆ្នាំ ១៩៩៧ ដល់ត្រលប់មកវិញក្នុង១៩៩៨ រវាងខែប្រាំពីរ ខែអីហ្នឹង ខ្ញុំអត់ចាំទេ ។ រវាងខែប្រាំពីរ គឺជាដំណើរត្រលប់មាតុភូមិនិវត្តដំបូងគេនៃពួកជំរំសាលចៅ ហើយនិងជំរំម៉ាក់មួងនេះ ។

ដូច្នេះ ខ្ញុំអត់ចាំថ្ងៃខែច្បាស់ទេ ប៉ុន្តែ-- គ្រាន់តែប៉ាន់ប្រមាណថារវាងខែប្រាំបី ឬខែប្រាំពីរ ឬខែប្រាំបីហ្នឹង ឆ្នាំ១៩៩៨ ។

**ស៖** លោកត្រលប់មកលោកនេះ តើលោកទៅរស់នៅកន្លែងណាខ្លះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំត្រលប់មកលើកនេះ ខ្ញុំនៅផ្ទះប្អូនពៅខ្ញុំ នៅភូមិអូរទទឹង ឃុំតាសាញ ស្រុកសំឡូត ក្បែរសាលាស្រុក ម្ខាងអូរម្នាក់ ។ ខ្ញុំអត់មានទៅណាទៀតទេ នៅតែហ្នឹងផ្ទះនុ៎ង ។

**ស៖** ឥឡូវនេះនិយាយអំពីប្រវត្តិរបស់លោកពាក់ព័ន្ធជាមួយនឹងជំនឿសាសនាវិញ ។ សួរថាតាំងពីដឹងក្តីមករហូតមកដល់លោកចូលធ្វើបដិវត្តន៍ កាលពីអំឡុងទសវត្សន៍ចុងឆ្នាំ៦០ ហើយនិងជាហូរហែ

មកទៀត សួរថាតើលោកមាននិន្នាការ ឬក៏មានជំនឿកាន់សាសនាអ្វីដែរកាលនោះ?

[១១:៥២:៤៥]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ជីតាខ្ញុំខាងម្ដាយជាពុទ្ធសាសនិកម្នាក់ដែលអ្នកស្រុកអ្នកភូមិកំណើតរបស់ខ្ញុំជឿ ហើយគេគោរព ។ ខ្ញុំសូមនិយាយនេះ វាចូលអបិយជំនឿបន្តិច ព្រះសពវត្តពៅវើយ គ្រូកំណើតខ្ញុំនេះ សុគតប្រហែលជានៅក្នុងឆ្នាំ១៩៥៣ ហើយជីតាខ្ញុំអនិច្ចកម្មប្រហែលជានៅក្នុងឆ្នាំ១៩-- ភ្លេចខុសមួយឆ្នាំអីហើយ ប្រហែលជាក្នុងឆ្នាំ១៩៥៥ ។ នៅពេលដែលជីតាខ្ញុំស្លាប់ទៅ ចាស់ៗនៅភូមិពៅវើយហ្នឹង គេតែងតែតំណាលថា ឃើញយប់ៗភ្លើងបួងលើដំបូលវិហារ គេជឿថា វត្ថុសក្តិសិទ្ធិ តម្រូវឲ្យព្រលឹងជីតាខ្ញុំ និងព្រលឹងព្រះសពវត្តពៅវើយនេះទៅការពារវិហារក្នុងឋានៈជាមហិទ្ធិឫទ្ធិអាថ៌កំបាំងការពារស្រុកភូមិហ្នឹង ។ នេះវាចូលដល់បញ្ហានេះ ខ្ញុំក៏មានទទួលឥទ្ធិពលបញ្ហានេះមួយកម្រិត ។

នៅពេលដែលខ្ញុំបានរៀនសូត្រចេះដឹងទៅ ជាពិសេសដល់មហាវិទ្យាល័យអក្សរសាស្ត្រ ការវែកញែក បញ្ជាក់ឲ្យឃើញថា ព្រះពុទ្ធសាសនានេះ យើងហៅថា សាសនាក៏បាន ពីព្រោះវាមានអង្គបី ។ ទីមួយ គឺមានទស្សនវិជ្ជា, ទស្សនវិជ្ជារបស់ព្រះពុទ្ធសាសនានេះ គឺអធិធម្ម ដែលបារាំងហៅថា *លើកាទុងប៉ុយឌីក* ។ ហើយតែកាលណាមានសាសនាហើយ វាមានអង្គមួយទៀតរូបផ្សំ គឺអង្គការចាត់តាំង វាមានថ្នាក់ដឹកនាំកំពូលនៃសាសនា ហើយវាមានបរិស័ទព្រានអាយ ។ ដូច្នេះវាមានវិន័យ ។ ដូច្នេះបើយើងមើលទិដ្ឋភាពនេះ យើងចាត់ទុកជាព្រះពុទ្ធសាសនាថាជាសាសនាបាន ។ ក៏ប៉ុន្តែបើយើងមើលទិដ្ឋភាពមួយទៀត ព្រះសមណគោតម ព្រះអង្គមិនដែលតាំងខ្លួនជាព្រះដ៏ពិតទេ ថ្វីដ្បិតតែព្រះពុទ្ធប្រវត្តិរូប-- (អ៊ំ សូមទោស) ពុទ្ធប្រវត្តិចែងថា ព្រះអង្គជាទេវបុត្រមួយអង្គមកយោនយកកំណើតក្នុងឧទរនាងសិរិមហាមាយា នៅក្នុងសយិវង្សក៏ដោយ ។ នៅពេលដែលព្រះអង្គរៀបចូលព្រះបរិនិព្វាន ព្រះអង្គប្រាប់ថា អត់ពីកថាគតទៅមានតែគម្ពីរបាលីហ្នឹងឯងជាទីពឹងរបស់អ្នកទាំងឡាយតំណាងអង្គកថាគត ។

[១១:៥៦:០៦]

ដូច្នេះ ក្នុងអ្នករៀនអ្នកសូត្រ គេជឿថា ព្រះពុទ្ធសាសនាមានលក្ខណៈប្លែកមួយដោយឈរវិទ្យាសាស្ត្រ ឈរការប្រៀនប្រដៅមានលក្ខណៈវិទ្យាសាស្ត្រ ។ ដោយឡែក សាសនាផ្សេងទៀត សាសនាព្រាហ្មណ៍ មានយកព្រះសិវៈ ដែលយើងហៅថា ព្រះឥសូរនោះ ព្រះពិស្ណុ ដែលយើងហៅថា ព្រះនារាយណ៍ ហើយនិងព្រះព្រហ្មធ្វើជាគោល ត្រៃមុទិ ព្រហ្មណនិយម ។ ឯចំណែកសាសនាគ្រិស្តវិញគេយកព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធទុកជាគោល ។ ខាងអ៊ីស្លាមយកព្រះអាឡោះ ជាធំ

ព្រះមហាម៉ាត់គ្រាន់តែជាអ្នកនាំព្រះបន្ទូលរបស់ព្រះជាម្ចាស់មកផ្សព្វផ្សាយដល់មនុស្សលោកទេ ។

នេះការរៀនសូត្រវាបានដឹងប៉ុណ្ណឹង ។ នៅពេលដែលខ្ញុំបាទប្រែចិត្តធ្វើបដិវត្តន៍ ក៏ដោយសារបានរៀនទស្សនវិជ្ជាមួយដែលខ្ញុំបានរាយការណ៍ជូនអង្គជំនុំជម្រះរួចមកហើយ គឺបឋមវិជ្ជាទស្សនវិជ្ជា ដែលមានចំណងពិតប្រាកដជាភាសាបារាំងថា *"ប្រាំងស៊ីប អេឡេម៉ង់ទ័រ ឌឺ ឡា ហ្វីឡូហ្សូហ្វី"* ។ *ប្រាំងស៊ីប អេឡេម៉ង់ទ័រ ឌឺ អា ហ្វីឡូហ្សូហ្វី* នេះចាត់ទុកសម្ភារៈនិយមថាជាធំ ថាជាច្បាស់លាស់ ថាជាវិទ្យាសាស្ត្របំផុត ។ ថាជាកម្រងគ្រប់និន្នការទស្សនវិជ្ជាទាំងអស់ក្នុងលោក ។ បដិសេធវត្ថុអាថ៌កំបាំង វត្ថុអាថ៌កំបាំងនេះ គេហៅថា គំនិតនិយម ដែលជឿលើព្រះ ដែលជឿលើបារមីរបស់ព្រះជាម្ចាស់ ។

ពេលដែលខ្ញុំវក់វីហ្នឹងសម្ភារៈនិយមហ្នឹងមែនទែនធ្វើឲ្យខ្ញុំស្រឡាញ់ទ្រឹស្តី ម៉ៅ សេទុង ដូចខ្ញុំបានជម្រាបអង្គសវនាការពីលើកមុនរួចមកហើយថា ទ្រឹស្តី ម៉ៅ សេទុង ទីមួយគាត់និយាយថា គ្មានទស្សនៈអ្វីដែលមិនចរិតវណ្ណៈទេ ។ តាមពិត ខ្ញុំនិយាយជាភាសាបារាំងចោះ ព្រោះគាត់សរសេរអត្ថបទសៀវភៅគាត់ហ្នឹងជាភាសាបារាំង គាត់ថា *"អូគីនីសកុងហ្សាក់សុង សង់អំប្រាំង តេដឺក្លាស"* (និយាយភាសាបារាំង) ខ្ញុំចាប់ចិត្តថា នេះជាសច្ចធម៌មួយ ។

ដល់ក្រោយមកទៀត ម៉ៅ សេទុង ដដែលហ្នឹងគាត់និយាយថា "សេចក្តីស្នេហាប្រជាជនពិតប្រាកដ គឺត្រូវប្រគល់ឥទ្ធិភាពអនុវត្តផ្តាច់ការទៅដាក់ឲ្យកណ្តាប់ដៃវណ្ណៈអធន" ។ ខ្ញុំថានេះជាគោលទស្សនៈវិជ្ជាមួយត្រឹមត្រូវ ដែលអនុវត្តកើត ដើម្បីសង្គ្រោះជាតិប្រជាជនកម្ពុជា ។ នៅពេលដែលខ្ញុំកំពុងវក់នឹងលទ្ធកុម្មុយនីស្តបែបនេះ ខ្ញុំតាំងចិត្តថាមិនជឿអ្វីទាំងអស់ ។

[១១:៥៩:៣៤]

តែដល់ក្រោយមកខ្ញុំចេះតែគិត ចេះតែចោទខ្លួនឯង គេត្រូវបក្សបញ្ចេញទៅដំណាលៗនឹងខ្ញុំដែរ នៅឆ្នាំ១៩៦៧ គេទៅដល់ឯរតនគីរីនោះ ភូមិភាគឦសាន ម៉េចក៏ខ្ញុំត្រូវដាច់នីរសារ ហើយទៅនៅនឹងចម្ការលើ ត្រូវឲ្យរដ្ឋាភិបាលគេចាប់ខ្ញុំយកមកដាក់គុកវិញ ។ ពេលដាក់គុកម៉េចបានគេរដ្ឋការគុក គេរកខ្ញុំដើម្បីយកទៅសម្លាប់មិនឃើញ បែរទៅចាប់មនុស្សផ្សេងទៀតពីរនាក់ មានមិត្ត ឡោ សាន គ្រូបង្រៀន ហើយនិងបង ឃៀង ហុក កសិករយកទៅសម្លាប់ ចេញពីគុកព្រៃស យកទៅសម្លាប់ដោយមិនបានកាត់ទោស ។ ខ្ញុំចេះតែសួរខ្លួនឯងថា ម៉េចក៏មិនស្លាប់ៗ តើមកពីអី?

បញ្ហានេះ វាកើតមកធ្វើឲ្យខ្ញុំមន្ទិលសង្ស័យលើសម្ភារៈនិយមរួចទៅហើយ ដល់ឃើញបរាជ័យរបស់កុម្មុយនីស្ត ។ ទីមួយនៅឥណ្ឌូនេស៊ី ដូចខ្ញុំបានជម្រាបអង្គសវនាការពីលើកមុន ។ ឥណ្ឌូនេស៊ីពីដើម

មានប្រជាជាន-- មានមូស្លីមមួយចំនួនធ្លាក់ទៅក្នុងកណ្ដាប់នៃជនកុម្មុយនីស្ដ ។ ជនកុម្មុយនីស្ដជាប្រធានបក្សកុម្មុយនីស្ដឥណ្ឌូនេស៊ីឈ្មោះ អៃឌីត ។ សមមិត្ត អៃឌីត កាន់កាប់ជាប្រធានសភាឥណ្ឌូនេស៊ី ប៉ុន្តែឆ្នាំ១៩៦៦ ស៊ូ ហាតូ លេងខ្ទេច ។

ខ្ញុំចាប់ផ្ដើមឃើញថា គុកកុម្មុយនីស្ដមិនប្រាកដជាយ៉ាងម៉េចទេ បើអ៊ីចឹង ។ ដល់ក្រោយមកបានៗខ្ញុំសម្រេចចិត្តថា មិនកើតទេ ឃើញមហាបដិវត្តន៍វប្បធម៌វណ្ណៈអធនចិននេះរលំទៅទៀត ។ តេងសាវភីង គាត់ចាប់ពួកអាក្រុមបួននាក់ហ្នឹងដាក់គុក ដាក់ឲ្យតុលាការកាត់ទោស ហើយគេកាត់ទោសអស់មួយជីវិត ហើយចេះតែឃើញបរាជ័យកុម្មុយនីស្ដបណ្ដើរៗ បានឲ្យខ្ញុំចេញពីសម្ភារនិយមមករកគំនិតនិយម ។ ចេញពីកុម្មុយនីស្ដមករក*គ្រិស្ដានិស្ទើស* ។

ដូច្នេះសរុបមក កាលដែលខ្ញុំប្រែចិត្តបែបនេះ ពីព្រោះខ្ញុំឃើញថា សេចក្ដីស្រឡាញ់ប្រជាជនរបស់លទ្ធិកុម្មុយនីស្ដគឺត្រូវតែគោរពវណ្ណៈ ។ ឯចំណែក សេចក្ដីដែលព្រះសម្មាសម្ពុទ្ធដែលព្រះបរមគ្រូលោកប្រដៅយើង ជាសេចក្ដីស្រឡាញ់ដែលអត់មានវណ្ណៈទេ ប៉ុន្តែខ្ញុំជឿថា មិនទាន់មានបារមី ។

ដូចជាខ្ញុំបានរាយការណ៍ជូនអង្គប្រជុំលើកមុនអ៊ីចឹង ធម៌ឲ្យពរថា សព្វេ សត្តា អវេរាសក្ខីហោងទោ ។ សត្វទាំងពួង ទាំងឡាយកុំចង់ពារវេរាហ្នឹងគ្នា គប្បីរស់នៅជាមួយគ្នាដោយសុខ ។

[១២:០២:៣៣]

ដូច្នេះ វាអត់មានសេចក្ដីស្រឡាញ់អី ដែលវណ្ណៈទេក្នុងព្រះពុទ្ធសាសនា ។ ក៏ប៉ុន្តែខ្ញុំឃើញវា អត់បារមី ដើម្បីនឹងញ៉ាំងចិត្តមនុស្សឲ្យស្រឡាញ់គ្នាតាមហ្នឹង កុំឲ្យកាន់វណ្ណៈ ។ ដោយឡែក បើមើលសាសនាគ្រិស្ដឃើញពាក្យប្រដៅរបស់គេពីរ ។ ទីមួយគេថា "ចូលអ្នកស្រឡាញ់អ្នកជិតខាងរបស់អ្នកដូចជាព្រះស្រឡាញ់អ្នកអ៊ីចឹង"។ ក៏ប៉ុន្តែ ពាក្យប្រដៅមួយទៀតរបស់ព្រះយ៉េស៊ូធ្ងន់ណាស់ "ចូរអ្នកស្រឡាញ់ខ្មាំងសត្រូវរបស់អ្នក ហើយអធិដ្ឋានឲ្យអ្នកណាដែលរុកគួនអ្នក" ។ ខ្ញុំថា អ្ហើ បើសិនមនុស្សទាំងអស់គោរពកោតខ្លាចព្រះយេស៊ូ ហើយខំធ្វើតាមពាក្យនេះ នឹងមានសន្តិភាព ។ ខ្ញុំឃើញបញ្ហានេះមានកម្លាំង ប៉ុន្តែនិយាយនេះមិនបដិសេធអ៊ីស្លាមទេ ព្រោះអ៊ីស្លាមក៏បង្កើតសេចក្ដីស្រឡាញ់មួយ ដែលអត់វណ្ណៈដែរ ប៉ុន្តែខ្ញុំមិនប៊ានិយាយជ្រៅទេ ព្រោះគម្ពីរកូរ៉ាន ដែលមហាម៉ាត់ លោកនាំព្រះបន្ទូលរបស់ព្រះជាម្ចាស់មកឲ្យប្រជាជន ខ្ញុំអត់បានអានទេ ទើបនឹងទិញបាន ។

ដូច្នេះ ខ្ញុំសូមទទួលស្គាល់ថា អ៊ីស្លាមក៏ជាសាសនាមួយដែលនាំណែឲ្យមនុស្សស្រឡាញ់មនុស្សដោយគ្មានវណ្ណៈដូចកុម្មុយនីស្ដ ។ ខ្ញុំយល់សភាពការណ៍នេះ ត្រូវតែមានវណសិរ្សរបស់អ្នកជឿ ដែល

ស្រឡាញ់ដោយអត់វណ្ណៈ ។ ដូច្នេះហើយបានជាខ្ញុំជ្រើសរើសយកសាសនាគ្រិស្ត ។ នេះវាជាការបញ្ជាក់ត្រលប់ទៅក្រោយវិញទេ តាមពិតអង្គាល់ដែលខ្ញុំជ្រើសរើសយកសាសនាគ្រិស្ត មកពីខ្ញុំឃើញថា ទីមួយសាសនាគ្រិស្តឈ្នះ ហើយទីពីរខ្ញុំមើលចំពោះមុខទេ ។ ចំពោះមុខយ៉ាងម៉េច? ប្រពន្ធខ្ញុំស្លាប់ បើសិនជាកាលនោះ ខ្ញុំស្លាប់ទៀត កូនខ្ញុំទៅឯណា? បើខ្ញុំកាន់សាសនាគ្រិស្ត កូនខ្ញុំក៏បានទទួលការជ្រមុជ ខ្ញុំស្លាប់ទាំងប្រពន្ធ ទាំងប្តី កូនខ្ញុំច្បាស់ជាវិហារគេយកទៅចិញ្ចឹម ។ កូនស្រីខ្ញុំមិនធ្លាក់ខ្លួនទៅធ្វើជាសំផឹងទេ វាគ្រាន់តែមិនមាន ហើយក៏ប៉ុន្តែវាសង្គ្រោះកូនខ្ញុំបាន ។ នេះខ្ញុំមើលចំពោះមុខឃើញអ៊ីចឹង ឯចំណែកផលប្រយោជន៍នៅលើសាកលលោកឃើញថា *គ្រិស្តាទីស* នឹងឈ្នះកុម្មុយនីស្ត ។ បានៗជាខ្ញុំសម្រេចយកនេះ ។

ដូច្នេះ ខ្ញុំមិនមែនចូល *គ្រិស្តាទីស* ដើម្បីទៅតតាំងប្រឆាំងជាមួយនឹង *ប៊ូតឌីស* ទេ ហើយក៏អត់មានគោលបំណងទៅតតាំងប្រឆាំងជាមួយនឹងអ៊ីស្លាមដែរ ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ជូនអំពីការប្តូរប្រែសាសនារបស់ខ្ញុំប៉ុណ្ណេះ ដោយគោរព ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងត្រូវហូប-- ពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ ហើយអង្គជំនុំជម្រះលើកទៅរសៀលចាប់ផ្តើមពីម៉ោងមួយនិងសាមសិបនាទី ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទកាន់បន្ទប់រងចាំ ហើយឲ្យនាំគាត់មកកាន់សាលសវនាការវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកនៅម៉ោង ១២:០៦ ដល់ម៉ោង ១៣:៣៤នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។

លោក អាឡាំង វែនណឺ ប្រសិនបើលោកមានចេតនាក្នុងការលើកបញ្ហាដដែល នោះអង្គជំនុំជម្រះមិនអនុញ្ញាតទេ ។ អញ្ជើញ ។

**លោក អាឡាំង វ៉ែនណឺ៖**

លោកប្រធាន ខ្ញុំសូមជម្រាបលោកប្រធានថា សហសេវិករបស់ខ្ញុំ ក្រុមពីរ និងក្រុមប្អូន បានស្នើខ្ញុំ ជាពិសេស លោក ហុង គីមសួន និង លោក គង់ ពិសី ស្នើឲ្យខ្ញុំជម្រាបលោកប្រធានថា មូលហេតុដែលគាត់មិនមកចូលរួមតាំងពីថ្ងៃចន្ទ ដោយសារតែពួកគាត់ព្យាយាមប្រមូលឯកសារដើម្បីគាំទ្រទៅលើករណីដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលខ្ញុំជម្រាបកាលពីសប្តាហ៍មុន ។ ដូច្នេះហើយ ទើបលោកទាំងពីរមិនមានវត្តមាននៅទីនេះជាមួយយើងខ្ញុំតាំងពីថ្ងៃចន្ទ និងថ្ងៃអង្គារ ហើយរួមទាំងថ្ងៃហ្នឹងផង ។

ដូច្នេះហើយទើបគាត់ស្នើខ្ញុំឲ្យជម្រាបលោកប្រធានឲ្យជ្រាបពីបញ្ហានេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណ ដែលលោកបានផ្តល់ព័ត៌មាននេះដល់អង្គជំនុំជម្រះ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទមកកាន់ទីកន្លែងឈើរាងវង់ក្រចកសេះទុកសម្រាប់ជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះ ។

*(ជនជាប់ចោទដើរកាន់កៅអីវង់ក្រចកសេះ)*

[១៣:៣៦:២៥]

ជនជាប់ចោទ កាលពីព្រឹកមិញ លោកបាននិយាយរៀបរាប់យ៉ាងលម្អិត យ៉ាងច្បាស់លាស់ហើយអំពីការប្រែប្រួលនូវការកាន់សាសនារបស់លោក ហើយចុងក្រោយលោកបានជ្រើសរើសនូវកាន់សាសនាគ្រិស្តសាសនានោះ ។

**ស៖** សំណួរសួរថា តើលោកចាប់ផ្តើមកាន់សាសនាគ្រិស្តហ្នឹងចាប់ពីពេលណាមក? ហើយទីកន្លែងសំខាន់ដែលលោកទៅប្រារព្ធពិធីតាមជំនឿសាសនាគ្រិស្តហ្នឹងជាចំបងនៅកន្លែងណា នៅក្នុងអំឡុងពេលដែលលោកកាន់សាសនាគ្រិស្តនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំទទួលពិធីជ្រមុជនៅថ្ងៃ៦ មករា ១៩៩៦ នៅឯងស្ទឹងសង្កែ ក្រោមអធិបតីភាពរបស់គ្រូគង្វាល គ្រិស្តហ្វ័រ ដេ. ឡាប៉ែល និងគ្រូគង្វាល ដានីញ៉ែល អេលីស ។ កន្លែងដែលខ្ញុំចូលទៅរៀនសូត្រសិក្ខាសាលាមួយឆ្នាំម្តង នៅពួកជំនុំគ្រិស្តបរិស័ទខ្មែរ ចម្ការសំរោងទីពីរ។ ពាក្យ ពួកជំនុំនេះ អង់គ្លេសហៅ *ឆើច* (Church) នៅចម្ការសំរោងទីពីរ ។ នៅពេលដែលខ្ញុំទៅដល់សំឡូត ខ្ញុំដាក់ឆ្ងាយហើយ ហើយនៅតុលាការយោធាក៏ខ្ញុំដាច់ឆ្ងាយដែរ បានតែអធិដ្ឋានទេ ។ មកពេលនេះ នៅមន្ទីរឃុំឃាំងអយ្យការ មន្ទីរឃុំឃាំងរបស់ អ.វ.ត.ក នេះ ។ ប៉ាស្ទ័រ គ្រូគង្វាល គ្រិស្តហ្វ័រ ដេ.

ឡាប៉ែល អញ្ជើញមកញ៉ឹកញាប់ជួបខ្ញុំ ក្រៅពីនេះខ្ញុំជួបក្រៅផ្លូវការដែរ ក្រៅផ្លូវការសាសនា ជាមួយនឹងលោកឪពុក រ៉ូប៉ែ ប៊ិហ្សេ មួយខែម្តង ។

នេះសូមគោរព រាយការណ៍ជូនលោកប្រធានប៉ុណ្ណេះ ។

[១៣:៣៩:២៩]

**ស៖** នៅពេលដែលត្រលប់ទៅកិច្ចការវិជ្ជាជីវៈ ឬក៏មុខរបរលោកវិញ ក្រោយពេលដែលលោកត្រលប់-- គេកៀរ កម្លាំងកងទ័ពខ្មែរក្រហម ដែលថាមានការផ្តាច់ខ្លួនវិញម្តងនោះ ហើយបានកៀរប្រជាពលរដ្ឋ ហើយទាំងលោកផងបានទៅនៅជំរំនៅព្រំដែន ហើយក្រោយមកក៏មានការមាតុភូមិនិវត្តន៍ត្រលប់មកវិញ ។

សំណួរសួរថា ពេលដែលលោកមកដល់សំឡូតលើកនេះ លើកចុងក្រោយនេះ ថាតើលោកធ្វើការងារអ្វី ឬក៏ប្រកបមុខរបរអ្វីនៅសំឡូត?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! គណៈកម្មាធិការដីខាងសំឡូតនេះ ដែលមាន ស៊ូ ម៉េត ហ្នឹងម្នាក់ ហែន សុផល បច្ចុប្បន្នចៅហ្វាយស្រុកសំឡូតម្នាក់ និងឧត្តសេនីយ គង់ (ស្អីគង់ទេ) ម្នាក់ទៀត បានពិគ្រោះគ្នាទៅ សម្រេចឲ្យខ្ញុំទទួលភារកិច្ចជាប្រធានការិយាល័យអប់រំស្រុក ។ កំពុងរៀបចំលក្ខណៈសម្បត្តិហ្នឹងហើយ ហើយនិងលក្ខណៈសម្បត្តិ ដើម្បីបង្ហាញខ្លួនឲ្យច្បាស់លាស់ជូនរដ្ឋាភិបាលហ្នឹងហើយ ដែលបែកការណ៍ដោយសារ និក ដនឡុប ហើយនិង នេត ថាយ័រ វាធ្លាក់ទៅដល់ គ្រិស្តូប៉េស៊ូ បានរដ្ឋា-ភិបាលយកខ្ញុំមកទុក ដើម្បីការពារសុវត្ថិភាពផង នៅអយ្យការយោធា នៅថ្ងៃ១០ ខែឧសភា ១៩៩៩ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** តើលោកនៅចងចាំទេថា អ្នកកាសែតចំនួនពីររូប ដែលលោកបាននិយាយអម្បាញ់មិញ នេត ថាយ័រ ហើយនិង និក ដនឡុប ដែលបានទៅជួបលោក ធ្វើសម្ភាសន៍ជាមួយលោកនោះ ថាតើនៅថ្ងៃខែឆ្នាំណាដែរ? លោកចាំដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមិនចាំថ្ងៃខែទេ គ្រាន់តែអាចបញ្ជាក់ជាគោល១បានដូចតទៅ៖

ដំបូង និក ដនឡុប វាទៅម្នាក់វាទេ ។ រឿងវានិយាយថា ទៅជួបខ្ញុំដោយចៃដន្យ មិនមែនទេ វាស្គាល់ខ្ញុំហើយស្រេចទៅហើយ ។ គឺវាស្វែងទៅរកខ្ញុំ ដែលកំពុងតែខំកសាងសាលាស្រុកនុំង ហើយដល់ក្រោយមកបាន១ វាបានរូបថតខ្ញុំ វាថតច្រើនប៉ុស្តិ៍ណាស់ យកមកជួប នេត ថាយ័រ ។ ដល់ក្រោយមក

បានវាទៅទាំងពីរនាក់ ដំបូងវាចេញខ្លួនម្តងម្នាក់ទៅថ្ងៃនុ៎ង ដល់ក្រោយមកបានវាចេញខ្លួនទាំងពីរនាក់ ។ នៅពេលដែលវារុញឯកសារសួរចម្លើយមួយទៅបង្ហាញខ្ញុំ នេត ថាយ័រ ។ ខ្ញុំថា ហ្នឹងហើយខ្ញុំ ឌុច ប្រធានមន្ទីរស-២១ ។ ខ្ញុំខំលាក់យូរហើយ បើខ្ញុំមិនលាក់ម្តេចបាន? ប៉ុល ពត, នួន ជា, តា ម៉ុក គេខំនិយាយថា ស-២១ ហ្នឹងជាសម្ផតិកម្មរបស់របស់យួន ជាការប្រឌិតរបស់យួន មិនមែនរបស់បក្សកុម្មុយនីស្តកម្ពុជាទេ ។ ឥឡូវបើខ្ញុំបំបែកការណ៍ហ្នឹង ខ្ញុំស្លាប់ហើយ ។

[១៣:៤៣:៥៣]

ដូច្នេះ តាំងពីបែកហ្នឹងមក ខ្ញុំព្រួយដែរ ។ តាម៉ុក មកជាប់នៅអយ្យការយោធាតាំងពីថ្ងៃ៦ ខែមីនា ឆ្នាំ១៩៩៩ ក៏ប៉ុន្តែជើងដៃ តាម៉ុក បែបចំណាប់ដែរ ។ ដូច្នេះ ខ្ញុំតក់ស្លុតដែរ ។

នេះជម្រាបប្រសាសន៍ដោយត្រង់ ។ ដូច្នេះ ការដែលខ្ញុំជួបហ្នឹង វាសម្ភាសហ្នឹងវាអត់ឲ្យឃើញម៉ាស៊ីនថត ម៉ាស៊ីនអីរបស់វាទេ ។ វាសួរខ្ញុំធម្មតា ប៉ុន្តែថ្ងៃមួយនោះ អ្នកថតពីរនាក់ អា និក ដនឡុប ហ្នឹងមួយ ហើយនិងជនជាតិ ហ្គាល់ល័រវ៉ា ម្នាក់ទៀតទៅថតខ្ញុំ ។

សរុបមកដល់ចុងបញ្ចប់ ដែលខ្ញុំបានជម្រាបអង្គសវនាការពីលើកមុនរួចមកហើយថា គ្រិស្តប៉េស្ស៊ូ នាំខ្ញុំទៅនៅស្នាក់នឹង អូតែលមនោរម្យ ក្រុងបាត់ដំបង ហើយសួរចម្លើយខ្ញុំ ចាប់តាំងពីថ្ងៃ៣០ មេសា ១៩៩៩ រហូតចប់ យប់ថ្ងៃ៣ ឧសភា ១៩៩៩ ។ នេះ ដូច្នេះការដែលជួបដំបូង គឺ អា និក ដនឡុប ដល់ក្រោយមកបាន គ្រិស្ត-- អ៎ ន៎ែ សុំទោស ដល់ក្រោយមកបាន នេត ថាយ័រ ហើយនិង និក ដនឡុប ទៅជួបជាមួយគ្នា ហើយថ្ងៃនោះមានជនជាតិ ហ្គាល់ល័រវ៉ា ម្នាក់ផង ខ្ញុំអត់ស្គាល់ឈ្មោះទេ ។ ដល់ចុងបញ្ចប់បានៗ ទៅជាមួយគ្នា គឺ គ្រិស្តប៉េស្ស៊ូ, កញ្ញា រុតអ៊ីយហ្គោ, ហេង ហាំខេង នេះ វាទៅជាអ្នកបកប្រែ ។ រួចហៅខ្ញុំទៅនៅស្នាក់នៅ អូតែលមនោរម្យនេះ ។ ខ្ញុំសូមនិយាយ-- និយាយច្របូកច្របល់សាចុះសាឡើង សូមអធ្យាស្រ័យ ។ សូមចប់ប៉ុណ្ណេះ។

**ស៖** អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់ជនជាប់ចោទដែរឬទេ?

ប្រសិនបើមានសូមអញ្ជើញ ។ សូមអញ្ជើញ លោកស្រីចៅក្រម ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

សូមអរគុណ លោកប្រធាន ។

**ស៖** លោក កាំង ហ្គេកអ៊ាវ គោលបំណងនៃការសួរសំណួរទាក់ទងទៅនឹងអត្តចរិតរបស់លោក គឺដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធទាំងឡាយយកមកប្រើប្រាស់ អំពីការដាក់ទោសប្រសិនបើលោកត្រូវបាន

គេកាត់ឲ្យជាប់ទោសនោះ ។ តើលោកយល់អំពីគោលបំណងនេះដែរឬទេ?

តើលោកស្រីចង់ឲ្យខ្ញុំនិយាយឡើងវិញនូវអ្វីដែលខ្ញុំបានលើកឡើងដែរឬទេ?

**ឆ៖** ខ្ញុំជម្រាប--

**ស៖** -- *(មិនមានការបកប្រែ)*

**ឆ៖** អរគុណ លោកជំទាវ ខ្ញុំជឿថាគេបកប្រែខុសៗ ខ្ញុំជឿថាគេបកប្រែដើម្បីកាត់ទោសនៅពេលណា ដែលគេកាត់ទោសខ្ញុំឲ្យដាក់ទោសនៅពេលណា ដែលគេកាត់ទោសខ្ញុំឲ្យមានទោស ។ ខ្ញុំជឿថា ដើម្បីសម្រាលដោះបន្ទុកខ្ញុំទៅវិញទេ ។ តើខ្ញុំបាទយល់នេះត្រឹមត្រូវដែរទេ? សូមលោកជំទាវមានប្រសាសន៍ ។

**ស៖** ខ្ញុំចង់បញ្ជាក់ឲ្យលោកឲ្យបានច្បាស់ លោកមិនទាន់ត្រូវបានកាត់ទោស ឬក៏ដាក់ទោសនោះទេ ប៉ុន្តែក្រោយពីការពិនិត្យទៅលើអត្តចរិតរបស់លោក គឺវាមានសារប្រយោជន៍ប្រសិនបើលោកត្រូវបានគេកាត់ទោស ។ ហើយវាក៏ជាប្រយោជន៍នៅក្នុងការដាក់ទោស ឬក៏បន្ធូរបន្ថយទោសដែរ តើលោកយល់ច្បាស់ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ប្រសិនបើខ្ញុំអាចលើកឡើងបាន ខ្ញុំជឿថា ខ្ញុំមានការឆ្ងល់ទាក់ទងទៅនឹងការតាំងសំណួរនៅក្នុងការដាក់ទោសនៅទីនេះ ។ ចំពោះអ្វីដែលខ្ញុំយល់ គោលបំណងទាក់ទងទៅនឹងអត្តចរិតរបស់ជនជាប់ចោទ គឺវាមិនមែនកម្រិតត្រឹមតែការកំណត់ទៅលើការដាក់ទោសប៉ុណ្ណោះទេ ហើយវាក៏ជាគោលបំណងក្នុងការចូលរួមនៅក្នុងនីតិវិធីដើម្បីការរកការពិត ហើយនិងដើម្បីស្វែងយល់ថាតើជនជាប់ចោទជាមនុស្សយ៉ាងម៉េច? ហើយគោលបំណងនៃការដឹងនេះ គឺវាអនុញ្ញាតឲ្យយើងយល់អំពីមូលហេតុដែលទាក់ទងទៅនឹងអង្គហេតុដែលដាក់បន្ទុកទៅលើគាត់។ ដូច្នេះហើយចំពោះខ្ញុំ ខ្ញុំសូមបញ្ជាក់ថាការតាំងសំណួរទៅលើបញ្ហាអត្តចរិត គឺវាមិនមែនកម្រិតទៅបញ្ហាដែលដាក់ទោសប៉ុណ្ណោះទេ ។

[១៣:៥៩:៤៧]

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកចៅក្រម ឡាវែន ។

**ស៖** ខ្ញុំមានសំណួរមួយចំនួនតូចសម្រាប់លោក កាំង ហ្គេកអ៊ាវគឺជាជាសំណួររបស់ខ្ញុំ ដែលខ្ញុំចង់សួរ ។ កាលពីសប្ដាហ៍មុន នៅក្នុងផ្នែកទីបី នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺដីកាដំណោះស្រាយត្រូវបានអាន ។ ហើយគឺយើងបានអានមុនពេលដែលអ្នកជំនាញ និងមុនពេលដែលយើងកោះហៅសាក្សីផងដែរ ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់នៅទីនេះ ។ តើលោកមានយោបល់បន្ថែមណាផ្សេងដែរឬទេ ស្ដីពីអំពីការរៀបរាប់សង្ខេបនៅក្នុងដីកាដំណោះស្រាយទាក់ទងទៅនឹងអត្តចរិតរបស់លោក?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្លឹមសារដែលមានចែងនៅក្នុងដីកាដំណោះស្រាយ ឬក៏ហៅថាដីកាបញ្ជូនរឿងឲ្យជំនុំជម្រះនេះ ខ្ញុំអត់ប្រកែកទេ យល់ស្របទាំងអស់ ។ ដោយឡែក តែបង្ហាញបច្ចេកទេសមួយតូច គឺប្រហារជារឿងវ៉ៃម៉ាស៊ីនខុស ។ កូនទីបី ដែលកើតនៅថ្ងៃ៣០ មីនា-- មិថុនា ១៩៧៧ នេះ អ៎! សូមទោស វង្វេងឆ្នាំកូនទៀតហើយ ។ កូនទីបីរបស់ខ្ញុំ មិនមែនជាកូនស្រីទេ គឺជាកូនប្រុស ។ នេះជារឿងតូចតាចទេ ក៏ប៉ុន្តែជាខ្លឹមសារ ខ្ញុំសូមបញ្ជាក់ឡើងវិញ ខ្ញុំយល់ស្របទាំងអស់ អត់មានកែប្រែអីទេ ។

**ស៖** ដើម្បីកែតម្រូវទៅលើចំណុចនេះ បានន័យថា លោកចង់មានន័យថា កូនទីបីរបស់លោក គឺជាកូនប្រុស ដែលកើតនៅថ្ងៃឆ្នាំណាដែរ?

**ឆ៖** ឆ្នាំអត់ខុសទេ ជម្រាបប្រសាសន៍លោកជំទាវ ឆ្នាំអត់ខុសទេ ក៏ប៉ុន្តែដល់វាក់ខ្ញុំ ខ្ញុំវង្វេងហើយឆ្នាំកូន ។ ឆ្នាំអត់ខុសទេ ថ្ងៃខែអត់ខុសទេ ខុសតែភេទ ។ កូនខ្ញុំភេទប្រុស មិនមែនភេទស្រីទេ កូនទីបី ។

**ស៖** នៅក្នុងដីកាដំណោះស្រាយបានលើកឡើងថា លោកមានកូនបួនរូប ។ កូនស្រីទីមួយ កើតនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៧ តើត្រឹមត្រូវដែរឬទេ? ហើយកូនប្រុសកើតនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ៧៨ តើត្រឹមត្រូវដែរឬទេ? ហើយលោកបាននិយាយថា កូនប្រុសមួយទៀត គឺកើតនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ៨១ តើត្រឹមត្រូវដែរឬទេ? ហើយកូនមួយទៀត គឺកើតនៅថ្ងៃទី២៨ ខែ១០ ឆ្នាំ៨៥ ដែលជាកូនប្រុសដែរ តើត្រឹមត្រូវដែរឬទេ? ដូច្នេះលោកមានកូនប្រុសបីរូប និងកូនស្រីមួយរូប ។

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ត្រឹមត្រូវហើយ កូនស្រីច្បង កូនបីទៀត សុទ្ធតែប្រុស ។

**ស៖** សូមអរគុណ ។ យោងតាមដីកាដំណោះស្រាយ ស្ដីអំពីអត្តចរិតរបស់លោក គឺមានការលើកឡើងអំពីយោបល់ទាក់ទងទៅនឹងបញ្ហាចិត្តសាស្ត្រនិងវិកលចរិកផងដែរ ។ ហើយក៏វាបានលើកឡើងបញ្ជាក់បន្ថែមទៀត ដោយអ្នកជំនាញពីររូបដែលគាត់បានធ្វើការផ្ដល់សក្ខីកម្មផ្ទាល់មាត់ គឺលោកសាស្ត្រា

ចារ្យ កា ស៊ុនបូណាត និងលោកស្រី ហ្វ្រង់ស័រ ស៊ីរ៉ូនី ហ្កៀលបូ ។ តើលោកមានយោបល់ណាមួយផ្សេងទៀតដែរឬទេ ចង់លើកឡើងទាក់ទងទៅនឹងសក្ខីកម្មរបស់អ្នកជំនាញទាំងពីរនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! អត្ថបទជំនាញរបស់លោកសាស្ត្រាចារ្យទាំងពីររូប ខ្ញុំបានធ្វើសេចក្តីចាប់អារម្មណ៍ជូនអង្គសវនាការហើយ ។ ខ្ញុំនៅរក្សាសេចក្តីចាប់អារម្មណ៍នេះទាំងស្រុង អត់កែប្រែអីទេ ។

[១៣:៥៥:៤០]

**ស៖** បន្ថែមទៅលើយោបល់ទាំងនោះ ហើយនិងយោបល់ស្តាប់ចម្លើយរបស់សាក្សីអំពីអត្តចរិតដែលយើងបានកោះហៅ និងស្តាប់ពីរថ្ងៃនេះ ។ បុគ្គលផ្សេងទៀតក៏បានលើកឡើងសេចក្តីសង្កេតអំពីអត្តចរិតរបស់លោកផងដែរ ហើយការលើកឡើងទាំងអស់នោះ គឺមាននៅក្នុងសៀវភៅ និងការបោះពុម្ពផ្សេង ស្តីអំពីខ្មែរក្រហមផងដែរ ហើយក៏មាននៅសំណុំរឿង ។ ដូច្នេះខ្ញុំចង់សួរលោកនូវចំណួរមួយចំនួនទាក់ទងទៅនឹងស្តីសង្កេតផ្សេងៗ អំពីអត្តចរិត និងបុគ្គលិកលក្ខណៈរបស់លោកដែលគេបានលើកឡើងនៅក្នុងសៀវភៅទាំងអស់នោះមួយចំនួន ។

ជាដំបូង គឺសៀវភៅរបស់ អេលីហ្សាប៊ែត បេកឃ័រ នៅពេលដែលសង្គ្រាមរលត់ទៅ ។ នេះជាចំណងជើងសៀវភៅ លេខ ERN គឺ 00237694 ហើយនិង 00238316 គឺមានលេខ ERN ជាភាសាអង់គ្លេស 00231997 ដល់លេខ00232710 នៅក្នុងទំព័រ១៦២ គាត់បានលើក ឡើងថា ឌុចបានគ្រប់គ្រងទៅលើបញ្ជាកាប់សម្លាប់មួយចំនួន ហើយគាត់ក៏បានគ្រប់គ្រងទៅលើអ្នកទោសមួយចំនួនគឺវាទាក់ទងទៅនឹងការគ្រប់គ្រងទៅលើខ្មាំង និងទៅលើកូនក្មេង ហើយនៅផ្នែកផ្សេងៗទៀត គឺគ្រប់គ្រងទៅលើកម្មកររោងចក្រផ្សេងៗ ។ ហើយយើងឃើញមានការចុះហត្ថលេខារបស់ ឌុច តាមរយៈសិទ្ធិទទួលបានពីថ្នាក់លើ ។ តើលោកយល់ស្របទៅលើការវាយតម្លៃទៅលើចំណុចដែលបានលើកឡើងនៅក្នុងសៀវភៅនោះដែរឬទេ ឬក៏លោកមានយោបល់បន្ថែមទៅលើចំណុចនេះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ស-២១ ជាយន្តការឧក្រិដ្ឋដែលប្រព្រឹត្តទៅលើមនុស្សប្រុសមនុស្សស្រី មនុស្សចាស់ មនុស្សក្មេង រហូតដល់កុមារ និងទារក ។ បើសិនជាយើងរាប់អំពីស្រទាប់វិញគឺចាប់តាំងពីកម្មករ យុទ្ធជនបដិវត្តន៍ រហូតទៅដល់កម្មាភិបាលជាអចិន្ត្រៃយ៍មជ្ឈិមបក្ស ហើយក៏រួមមានទាំងបញ្ញាជនផង ។ នេះគឺខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ដើម្បីឲ្យស្របទៅនឹងសេចក្តីអះអាងរបស់ អេលីហ្សាប៊ែត បេកឃ័រ ។ ឯចំណែកសិទ្ធិដែលទទួលបានពីមេ ខ្ញុំក៏បានបញ្ជាក់ជូនអង្គប្រជុំរួចហើយថា ស-២១

នេះ វាចាត់តាំងឡើងតាមមាត្រា៨ នៃលក្ខន្តិកៈបក្ស ហើយមេដែលចុះមកគ្រប់គ្រងខ្ញុំគឺ សុន សេន ដែលកំណត់ដោយសេចក្ដីសម្រេចថ្ងៃ៩ តុលា ១៩៧៥ ។ នេះគឺខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ឲ្យកាន់តែល្អិតនិងច្បាស់លាស់ជាងអត្ថបទរបស់ អេលីហ្សាប៊េត បេកឃ័រ ។

**ស៖** ខ្ញុំមានចំណាប់អារម្មណ៍ចង់ដឹងថា តើលោកឯកភាពដែរឬទេ ថាផ្នែកខ្លះនៃអត្តចរិតរបស់លោក គឺត្រូវគោរព ហើយនិងធ្វើតាមអ្វីជាសេចក្ដីលំអិត ដែលអេលីហ្សាប៊េត បេកឃ័រ បានសរសេរនៅក្នុងសៀវភៅរបស់គាត់នោះ?

[១៤:០០:១២]

**ឆ៖** ខ្ញុំយល់ថា សំណួររបស់លោកជំទាវ សំដៅថាខ្ញុំគោរពថ្នាក់លើ តាមពិតខ្ញុំគោរពថ្នាក់លើដោយឥតលក្ខខណ្ឌមែន ។

**ស៖** ខ្ញុំជឿថា ចំណុចដែល អេលីហ្សាប៊េត បេកឃ័រ ចង់បញ្ជាក់នោះ គឺនៅក្នុងការងាររបស់លោក លោកបានផ្ដោតយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើសេចក្ដីលម្អិតការងារនោះ ហើយលោកពិតជាបានយកចិត្តទុកដាក់អ៊ីចឹងមែន ឬក៏លោកធ្វើដូចម្ដេច? តើលោកឯកភាពនឹងពាក្យគាត់ហ្នឹងឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំឯកភាពទាំងស្រុងចំពោះបញ្ហានេះ ។

**ស៖** គាត់ក៏និយាយទៀតថា ឌុច នៅទីបំផុតហ្នឹង គាត់ក្លាយទៅជាមនុស្សដ៏សំខាន់បំផុត ក្នុងចំណោមមនុស្សមួយចំនួនតូច ដែលថាទួលស្លែងនោះបានក្លាយទៅជាកន្លែងមួយជាមណ្ឌលប្រព័ន្ធបង្កើតនូវភាពព្រឺខ្លាច តើលោកមានមតិអ្វីទេ ដែលគាត់និយាយថា លោកក្លាយទៅជាមនុស្សមួយចំនួនតូចដែលថាមនុស្សសំខាន់របស់បក្សនៅក្នុងប្រទេសនាសម័យនោះ?

**ឆ៖** តាមការវិភាគរបស់ខ្ញុំ ដែលស្គាល់ធាតុពិតរបស់បក្សកុម្មុយនីស្តកម្ពុជា ខ្ញុំឃើញថា អ្នកដែលមានតួនាទីសំខាន់ គឺសមាជិកមជ្ឈិម ។ សមាជិកមជ្ឈិមនេះ ខ្ញុំបានរាយការណ៍ជូនអង្គប្រជុំច្រើនលើកហើយ វាមានបួនថ្នាក់ ។ រងអចិន្ត្រៃយ សមាជិកមជ្ឈិមពេញសិទ្ធិ សមាជិកមជ្ឈិមត្រៀម និងជំនួយការមជ្ឈិម ។ ឯចំណែកខ្ញុំបាទ វានៅឆ្ងាយពីគេណាស់ មិនទាន់បានចូលមជ្ឈិមទេ ដូច្នេះខ្ញុំនិយាយនេះ មិនមែនគេចចង់ខ្លួនពីឧក្រិដ្ឋកម្មទេ គ្រាន់តែបង្ហាញថា សារសំខាន់ដែលបក្សកុម្មុយនីស្តកម្ពុជាផ្ដល់ឲ្យផ្ដល់តួនាទីឲ្យឋានានុក្រមរបស់ខ្លួន តាមឋានៈបែបនេះ ។

**ស៖** ហើយគាត់ក៏បានសរសេរបន្តទៅទៀត ហើយគាត់ពន្យល់យោបល់នោះ ដោយនិយាយថា ឌុច បានជួយបង្កើតនូវភស្តុតាងប្រឆាំងនឹងជនសង្ស័យនៅពេលនោះ ដោយត្រួតត្រាទៅលើចម្លើយសារ

ភាពរបស់ជនទាំងនោះ ដែលបញ្ជាក់ថាជាបទឧក្រិដ្ឋ ជាភស្តុតាងនៃបទឧក្រិដ្ឋ ហើយគាត់ក៏បានបំភ្លៃ ហើយអនុវត្តនូវការងារហ្នឹង ក្នុងតួនាទីរបស់បក្ស ដើម្បីកម្ទេចខ្មាំង តើលោកអាចនិយាយបានដូចម្តេច អំពីការវាយតម្លៃរបស់សៀវភៅគាត់នោះ?

[១៤:០៣:៤២]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំធ្លាប់បានរាយការណ៍ជម្រាបអង្គសវនាការយើងហើយ ឧក្រិដ្ឋកម្មទីមួយ ដែលខ្ញុំគិតថា ធ្ងន់ធ្ងរ គឺកសាងកម្មាភិបាល ដោយមានខ្ញុំតែម្នាក់ គេប្រើបានតែម្នាក់ទេ បើសិនជាខ្ញុំបានទៅកសាងកម្មាភិបាលបានប្អូនដប់ម្ភៃនាក់ច្រើនទៀត ដោយស្មោះត្រង់នឹងគេ ហើយនិងខិតខំធ្វើការល្អិតល្អន់ ហ្មត់ចត់ ដូចខ្ញុំគេបានកម្មាភិបាលច្រើន ។ ដូច្នេះ ឧក្រិដ្ឋកម្មវាខ្ពស់ពេលណោះ ឯចំណែកឧក្រិដ្ឋកម្មដែលទាក់ទងនឹងការសួរចម្លើយ ចារលើចម្លើយឲ្យគេស្រួលយល់ ពិតជាឧក្រិដ្ឋកម្មមួយធ្ងន់ធ្ងររបស់ខ្ញុំ ដែលខ្ញុំធ្វើដោយផ្ទាល់ដៃអត់ប្រកែកទេ ។ នេះគឺខ្ញុំសូមនិយាយអំពីសារសំខាន់នៃការងារនេះ បែបនេះទៅវិញ ។

**ស៖** លោកបានឮពាក្យសក្ខីកម្មរបស់លោក ដេវីដ ឆេនឌ័ល័រ ហើយបាន គេបានបញ្ជាក់នៅក្នុងសៀវភៅមួយថាសំឡេងពីស-២១ ដែលបានអាននៅក្នុងតុលាការពីមុន ហើយខ្ញុំចង់ឲ្យលោកមានមតិទៅលើសក្ខីកម្មដែលលោកសាស្ត្រាចារ្យ ដេវីដ ឆេនឌ័ល័រ បានផ្តល់នៅក្នុងតុលាការនេះ ។ ហើយគាត់បាននិយាយថា គាត់និយាយថា លោកចង់ក្លាយទៅជាមនុស្សពូកែក្នុងការងាររបស់លោកនៅស-២១ ហើយថាលោកបានគិតថាលោកត្រូវតែធ្វើការងារហ្នឹងឲ្យបានល្អជាងដទៃ ហើយលោកចង់ៗឲ្យមានលក្ខណៈពូកែ ដូចដែរលោកជាសិស្សពូកែនោះដែរ ហើយលោកក៏ចង់បង្ហាញភាពស្មោះត្រង់ ហើយនិងជំនាញទៅលើ ទៅថ្នាក់លើ ហើយលោកក៏ចង់ឲ្យគេកោតសរសើរចំពោះការងាររបស់លោក។ តើនោះគឺជាការវាយតំលៃត្រឹមត្រូវទៅលើអត្តចរិតរបស់លោកក្នុងការងារដែរឬទេ?

[១៤:០៦:០៤]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! បើនិយាយពីចង់ ខ្ញុំពិតជាចង់។ ប៉ុន្តែ ក្នុងពេលនេះ ខ្ញុំមិននិយាយពីមូលហេតុអីបានជាខ្ញុំចង់ទេ ។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំពិតជាចង់ ។

**ស៖** តើលោកឯកភាពជាមួយនឹងសេចក្តីសង្ខេបនេះដែរឬទេ? គេនិយាយថា លោកជាមនុស្សឈ្លាសវៃ លោកមានការអប់រំខ្ពស់ លោកធ្វើការងារប្រឹងប្រែង ហើយលោកធ្វើការដោយប្រុងប្រយ័ត្ន យកចិត្តទុកដាក់ លោកចង់ឲ្យមេរបស់លោកសប្បាយចិត្តនឹងការងារ ។ លោកចង់ក្លាយទៅជាអ្នកមាន

អាជីព គ្រប់អ្វីដែលលោកធ្វើ ។ លោកមានការស្វាហាប់ម៉ឺងម៉ាត់ក្នុងការងាររបស់លោក ។ យកចិត្តទុកដាក់ចំពោះសេចក្តីលម្អិត សូម្បីតែរឿងតូចៗក៏ដោយ ហើយរក្សាកំណត់ត្រាឲ្យបានត្រឹមត្រូវ ឲ្យមានការរៀបចំល្អទៀតផង ហើយជាទូទៅ លោកមានមោទនភាពអំពីការងារដែលលោកបានធ្វើ ។ តើនេះជាសេចក្តីមួយដែរថាត្រឹមត្រូវឬទេ? ឬក៏លោកមានមតិដូចម្តេច ចំពោះពាក្យនេះ?

**ឆ៖** ខ្ញុំអត់ប្រកែកទេ ទទួលស្គាល់ ។

**ស៖** អ្នកជំនាញពីររូប បាននិយាយសង្កត់ធ្ងន់ថា នៅពេលដែលលោកធ្វើការនៅស-២១ លោកត្រូវបានជំរុញឲ្យធ្វើការងារនោះ ដោយថាខ្លាចគេសម្លាប់លោក ។ ប៉ុន្តែ នៅក្នុងសម្តីរបស់លោក ដេវីដ ឆេនដ័ល័រ នៅក្នុងតុលាការនេះ ដែលគាត់បានពិនិត្យមើលចម្លើយសារភាព ហើយនិងចំណារជាច្រើនដែលលោកបានសរសេរនោះ គាត់បាននិយាយថា តាមធម្មតា លោកបានកែតម្រូវ ហើយធ្វើការរិះគន់ចំពោះសេចក្តីសារភាព ចំពោះអ្នកទោស ហើយលោកបានចំណារថា ឲ្យធ្វើទារុណកម្ម ជំរុញឲ្យអ្នកជំរុញអ្នកសួរចម្លើយឲ្យរកកាយ ឬក៏ទម្លាយការពិត ហើយក៏រៀបចំឲ្យមានសង្វាក់នៃការសួរសំណួរចម្លើយនោះតទៅទៀត ។ តើមតិរបស់លោក ដេវីដ ឆេនដ័ល័រ ទៅលើចំណាររបស់លោកនៅលើសេចក្តីសារភាពនៅស-២១ នោះ ត្រឹមត្រូវ ឬក៏យ៉ាងដូចម្តេច?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ភស្តុតាងវានៅសល់ អត់មានអ្នកណាប៊ានប្រកែកនិងភស្តុតាងទេ ខ្ញុំពិតជាបានចារ ហើយខិតខំចារ ដើម្បីជំរុញការងារសួរចម្លើយដើម្បីឲ្យថ្នាក់លើស្រួលអាន ស្រួលយល់មែន។ ក៏ប៉ុន្តែមូលហេតុអី នេះវាជាបញ្ហាដែលខុសគ្នារវាងខ្ញុំ និង ឆេនដ័ល័រ ។ ឆេនដ័ល័រ គាត់ទុកដល់បញ្ហាពីរមិនអាចចុះសម្រុងគ្នាបានទេ ។ បើតាមខ្ញុំ ខ្ញុំមានទស្សនៈវិជ្ជាមួយថា ការខំធ្វើការងារវាមានមូលហេតុពីរ ។ ទីមួយ ខំធ្វើឲ្យបានល្អ ព្រោះខ្លាចស្លាប់ បើធ្វើមិនល្អទៅវាស្លាប់ ។ ក៏ប៉ុន្តែមួយទៀត ធ្វើល្អ ដើម្បីស្អីអានេះវាបញ្ហាមួយផ្សេងទៀត ។ នៅក្នុងទស្សនវិជ្ជា យើងខ្ញុំហៅអាធ្វើល្អ ព្រោះខ្លាចស្លាប់ នេះហៅថាឯកភាពមុខផ្ទុយៗ ដែលបារាំងយើងអាចនិយាយថា *អ៊ុយនីតេដេកុងត្រាស់ ។* នេះសូមបញ្ជាក់ជូនការយល់ដឹងរបស់ខ្ញុំ ចំពោះការងារដែលខ្ញុំធ្វើ វាមានមូលហេតុខ្លាចស្លាប់ ។

[១៤:១០:៤៣]

**ស៖** ខ្ញុំបានកត់សម្គាល់ថា លោកមានការភ័យខ្លាចថាគេនឹងសម្លាប់លោក ។ ប៉ុន្តែ ទាំងលោកដេវីដ ឆេនដ័ល័រ ហើយនិង បេកយ័រ និយាយថាលោកបានធ្វើអ្វី ដែលលើសពីការចាំបាច់ដើម្បីរក្សាជីវិតរបស់លោកនៅស-២១ តើលោកមានមតិ ឬក៏មានសេចក្តីសង្កេតម៉េចទៅលើសម្តីរបស់ពួកគាត់នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ការងារនៅស-២១ ខ្ញុំរត់អត់ទាន់ទេ មានឯកសារមួយចំនួនអត់បានចារ ។ ហើយឯកសារមួយចំនួនដែលជាមនុស្សសំខាន់ៗយើងខ្ញុំទាក់ទងជាមួយនឹងមេតាមទូរស័ព្ទ ។ ដូច្នេះ ដល់និយាយថា វាលើសពីសេចក្ដីត្រូវការចាំបាច់ អត់មែនទេ ការងារដែលខ្ញុំខំមួយថ្ងៃៗវាយ៉ាងវាជាងដប់ម៉ោង បីបួនដប់ម៉ោង មិនទាន់គ្រប់សំណូមពរនៃការងារហ្នឹងផង ។

សូមបញ្ជាក់ជូនលោកជំទាវ ដោយស្មោះប៉ុណ្ណោះ ។

**ស៖** ខ្ញុំមិនយល់ថា មតិយោបល់នោះគឺជាការរិះគន់ការងាររបស់លោកទេ ឬក៏ថាអាចបញ្ជាក់ថាលោកជាមនុស្សឧស្សាហ៍ព្យាយាមដែលចាំបាច់លោកត្រូវតែធ្វើប៉ុណ្ណោះ ។ ប៉ុន្តែ តាមពិតលោកធ្វើលើសពីអ្វីដែល ហួសពីអ្វីដែលចាំបាច់សម្រាប់នឹងឲ្យលោកបានរួចរស់មានជីវិតនោះ បានន័យថាវាច្រើនជាងតម្រូវការដែលសម្រាប់រក្សាជីវិតលោកនោះ ។ តើលោកអាចបញ្ជាក់បានដូចម្ដេចចំណុចនេះ?

**ឆ៖** ខ្ញុំសូមជម្រាបប្រសាសន៍លោកជំទាវដោយស្មោះត្រង់ ។ អម្បាញ់មិញ ខ្ញុំបានបញ្ជាក់រួចហើយថា កាលដែលយើងខ្ញុំខំខ្នះខ្នែងបែបនេះក៏ដោយ ក៏នៅមិនទាន់គ្រប់នឹងសំណូមពរការងារ ។ រួចឥឡូវនេះ វាចោទបញ្ហាថា លើសអំពីសំណូមពរដែលរក្សាជីវិតឲ្យរស់ គ្មានអ្នកណាប៉ានវាស់យកលក្ខណៈវិនិច្ឆ័យអីទៅវាស់ថាអ្វីជាសំណូមពរនៃការសុំរស់នោះបានទេ ។ របបបក្សកុម្មុយនីស្តកម្ពុជា គេហៅថា របបត្រដេវិក យកជើងទ្រមេឃ ។ សង្ស័យគ្រប់បញ្ហា ចាប់អារម្មណ៍ថាគេក្បត់គាត់គ្រប់បញ្ហាដូច្នេះខំនោះៗ ខំៗ ។ ដូច្នេះរកលក្ខណៈវិនិច្ឆ័យកម្រិតណា ដើម្បីវាស់ថា អានេះ វាត្រឹមតែជាក្របខ័ណ្ឌនៃការសុំរស់ អត់មានក្របខ័ណ្ឌកំណត់កើតទេ ។

នេះសូមជម្រាបលោកជំទាវ ដោយស្មោះត្រង់តាមការយល់ដឹងរបស់ខ្ញុំប៉ុណ្ណោះ ។

[១៤:១៣:៥២]

**ស៖** តាមការសង្កេតរបស់ខ្ញុំនៅក្នុងពេលសវនាការនោះ ដែលគាំទ្រដោយសក្ខីកម្មរបស់អ្នកជំនាញ និងសក្ខីកម្មផ្សេងៗទៀតនោះ បានបង្ហាញថាលោកត្រៀមខ្លួនជាស្រេចនឹងទទួលព័ត៌មាន ហើយនិងភស្តុតាង លុះត្រាតែភស្តុតាងទាំងអស់នោះ មានជាលាក់លក្ខណ៍អក្សរ ។ តើការនិយាយបែបនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ការនិយាយបែបនេះត្រឹមត្រូវស្ទើតែទាំងស្រុង ។ ក៏ប៉ុន្តែបញ្ហាខ្លះ ដែលខ្ញុំស្គាល់ច្បាស់ មិនបាច់ភស្តុតាងអីក៏បានដែរ ។ ឧទាហរណ៍ ជុំ ម៉ី ពីមុនមក ខ្ញុំអត់ដែលស្គាល់ ជុំ ម៉ី ទេ ។ ឆ្នាំ២០០៦ ខែកុម្ភៈ ចេះមិនដឹង ជុំ ម៉ី ឲ្យសម្ភាសជាមួយនឹងវិទ្យុបារាំងអន្តរជាតិ ថា

មួយជីវិតគាត់ ដែលធ្វើ-- ដែលជាប់គុកនៅស-២១ នេះ ឃើញខ្ញុំតែមួយភ្លែតនៅរោងជាង ។ ខ្ញុំឮសម្ភាសបែបនេះ ខ្ញុំថាពិត ពិតជាមនុស្សម្នាក់ដែលរងគ្រោះនៅស-២១ មែន ព្រោះរោងជាងហ្នឹង ខ្ញុំចូលទៅតែម្តងគត់ ដោយមិត្ត ហ៊ី ជូនទៅ ទៅមើលគេធ្វើឡាំងគ្រាប់ ។ គ្រាន់តែឮប៉ុណ្ណឹង គឺខ្ញុំទទួលស្គាល់ភ្លាម ។ វាច្បាស់ ភស្តុតាងវាច្បាស់ ។ នេះសូមគោរពជម្រាបលោកជំទាវប៉ុណ្ណេះ ។

**ស៖** នៅពេលដែលលោកបានចូលធ្វើការនៅស-២១ ជាអនុប្រធាននោះ តើប្រព័ន្ធហើយនិងបែបបទនៃការងារនោះ គឺចាប់ផ្តើមមានការវិវឌ្ឍន៍នៅពេលនោះ ឬក៏លោកបានប្រើជំនាញនៃការគ្រប់គ្រងដើម្បីអភិវឌ្ឍប្រព័ន្ធនោះឲ្យបានល្អជាងមុន?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំចូលទៅមន្ទីរស-២១ ជាអនុប្រធាន ខ្ញុំបានអភិវឌ្ឍប្រព័ន្ធនេះ ខាងការងារសួរចម្លើយ ដោយបង្រៀនកម្មាភិបាលសួរចម្លើយ កសាងកម្មាភិបាលសួរចម្លើយ ។ ហើយបន្ទាប់មកទៀត ដើរជាមួយនិង ណាត ជាប្រធាននេះ ទៅមើលគេសួរ ដើម្បីឲ្យយល់ជាពិសោធន៍ក្នុងការបង្រៀនគេតទៅទៀត នេះជាការអភិវឌ្ឍន៍ផ្នែកទីមួយ ។

ឯចំណែកផ្នែកទីពីរវិញ កាលណាគេ មនុស្សណាដែលគេចង់ឲ្យខ្ញុំដឹង ណាត គេចង់ឲ្យខ្ញុំ គេរុញមកឲ្យខ្ញុំចារ តើត្រូវសួរត្រង់ណាទៀត១? ហើយបានគេយកទៅមើលហើយគេចារបន្ថែមទៀត ដូច្នេះ វាមានចំណារមួយជាន់ហើយ មួយជាន់ទៀត ដើម្បីជំរុញឲ្យអ្នកសួរ គេសួរ ។ ដូច្នេះការអភិវឌ្ឍន៍មានតែផ្នែកខាងសួរនេះទេ ក្រៅពីនោះរក្សាតាមគោលការណ៍ចាស់របស់អតីតរបស់មន្ទីរនគរបាលកងពល៧០៣។

**ស៖** តើនៅចំណុចពេលណាដែលលោកចាប់ផ្តើមជឿយ៉ាងច្បាស់ថា ស-២១ គឺជាអង្គការ ឬក៏ជាយន្តការឧក្រិដ្ឋមួយ ដូចដែលបានបញ្ជាក់នៅក្នុងភស្តុតាងដែលជំរុញថា ជាទស្សនៈចេញពីការយល់ដឹងផ្ទៃក្នុងរបស់ខ្លួនលោកនោះ?

[១៤:១៨:០២]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ការយល់ដឹងអំពីឧក្រិដ្ឋកម្មនេះ វាមិនមែនកើតមានត្រឹមតែនៅមន្ទីរស-២១ទេ គឺចាប់តាំងពីគេប្រគល់នាទីមន្ទីរ១៣ ឲ្យខ្ញុំធ្វើជាប្រធាន ។ យល់ថាការសម្លាប់មនុស្សគ្មានហេតុផលនេះ វានាំឲ្យ វាជាឧក្រិដ្ឋកម្មមួយ ។ ក៏ប៉ុន្តែ គេអះអាងជំរុញឲ្យខ្ញុំធ្វើដោយអះអាងថា មិត្តត្រូវតែទទួល ប្រើពាក្យថា "ត្រូវតែទទួល" ហើយគេសង្កត់មួយម៉ាត់មួយទៀត បក្សទាមទារកុលបុត្ររបស់ខ្លួនឲ្យបំពេញការងារនេះ មិត្តត្រូវតែបំពេញ ។ ដូច្នេះ ដោយប្រកែកមិនរួច ហើយគេអះអាងថា មជ្ឈិមបក្សទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រ ។ មន្ទីរ១៣ ចាំតែទទួលមនុស្សដែលគេចាប់ឲ្យ ។

ដូច្នេះ ខ្ញុំរក្សាគោលគំនិតដែលថា មជ្ឈិមបក្សគេទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រ ។ ខ្ញុំនៅរក្សាទស្សនៈនេះរហូតជួប ភីតធ័រ ឡឺប្រ៊ីក ក៏ខ្ញុំឆ្លើយបែបនេះជាមួយ ភីតធ័រ ឡឺប្រ៊ីក នៅឆ្នាំ១៩៩៩ ។ ភីតធ័រ ឡឺប្រ៊ីក ទៅជួបខ្ញុំម្តងនៅអយ្យការយោធា ជាមួយនឹងចៅក្រមស៊ើបអង្កេតនៃអយ្យការយោធាក៏ខ្ញុំឆ្លើយរបៀបនេះ ។ ទើបនឹងមកជួបមេធាវីរបស់ខ្ញុំទាំងពីរនាក់លើកនេះ ដែលបានពិគ្រោះគ្នាទៅត្រូវតែយល់ទទួលស្គាល់ថា នេះវាមិនមែនជាប៉ូលិស ដែលរដ្ឋាភិបាលទទួលខុសត្រូវទេ ព្រោះរដ្ឋាភិបាលនេះជារដ្ឋាភិបាលផ្តាច់ការ ជារដ្ឋាភិបាលអនុវត្តបទឧក្រិដ្ឋ ។

ដូច្នេះត្រូវទទួលស្គាល់ថា ខ្លួនឯងបានប្រព្រឹត្តបទឧក្រិដ្ឋកម្ម ឬទស្សនៈនេះនៅក្រោយទេ ។ ប៉ុន្តែពីលើកមុនដឹង ដឹងអាហ្នឹងវាខុស ដឹងថាអាហ្នឹងវាឧក្រិដ្ឋ ក៏ប៉ុន្តែនៅតែគិតថាខ្លួនឯងជាប៉ូលិស អ្នកដែលទទួលខុសត្រូវ គឺរដ្ឋាភិបាល គឺមជ្ឈិមបក្ស ។ នេះវា១វិវឌ្ឍន៍បែបនេះ ។ នេះ គឺសូមជម្រាបបញ្ជាក់ជូនលោកជំទាវប៉ុណ្ណេះ ។

**ស៖** ប្រសិនបើពីដំបូងនោះលោកចាប់ផ្តើមជឿជាក់ថា វាជាអង្គការឧក្រិដ្ឋនៅពេលដែលលោកធ្វើជាប្រធាននៃម-១៣ នោះ តើលោកធ្លាប់បានផ្តល់គំនិតអ្វីមួយខ្លួនថា ខ្លួននឹងចង់ចេញពីបក្សហ្នឹងពីដំណាក់កាលនោះទេ មុនពេលថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! បញ្ហានេះខ្ញុំពិតជាចង់ចេញ ប៉ុន្តែរកមធ្យោបាយចេញអត់រួចនេះសូមនិយាយខ្លីមួយម៉ាត់ ។ ព្រឹត្តិការណ៍សំខាន់ ដែលធ្វើឲ្យខ្ញុំមានលេស សម្រាប់សូមចេញ គឺនៅពេលដែលអ្នកទោសដណ្តើមកាំភ្លើងបាន ហើយបាញ់មិត្តយើងឲ្យរបួសនៅឆ្នាំ១៩៧៣ នៅទីតាំងមួយដែលខ្ញុំកំពុងតែធ្វើស្រែ នៅក្បែរភ្នំពីស១ ។ គេរត់អស់សាម-សែសិបនាក់ទៅ គេឆក់កាំភ្លើងបានទាំងអស់ទៅ គេបាញ់ពួកអ្នកកងការពារហ្នឹងឲ្យរបួសបីបួននាក់ ។ ខ្ញុំឆក់ឱកាសនេះ សូមអនុញ្ញាត វ៉ន វេត ឲ្យគាត់ដាក់ទោសខ្ញុំ ។ ពាក្យថា "ដាក់ទោស" ហ្នឹងឲ្យគាត់ដកស័ក្តិ ដកបុណ្យ ដកចេញពីបក្សក៏បានដែរឲ្យតែធ្វើម៉េច ។ តែគាត់មិនព្រម ដូចខ្ញុំបានជម្រាបអង្គសវនាការហើយ ខ្ញុំសូមអង្វរគាត់ថាឲ្យដាក់ទោសខ្ញុំ ព្រោះខ្ញុំធ្វើខុស គាត់បែរខ្នងដាក់ខ្ញុំ ។ ដូច្នេះខ្ញុំចេញអត់រួចទេ ។

ដល់ក្រោយមក ក្រោយ១៧ មេសា ខ្ញុំប្រាថ្នាសូមចេញម្តងទៀត ។ នេះក៏ខ្ញុំបានរាយការណ៍ជូនអង្គសវនាការហើយ ដោយរកមកខាងក្រសួងវប្បធម៌មកមិនបាន ខ្ញុំចង់ចេញទៅក្រសួងឧស្សាហកម្ម ។ ថ្ងៃ៣១ ចេង អន សរសេរសំបុត្រទៅ ថ្ងៃ៣១ ខែឧសភា ១៩៧៥ ចេង អន សរសេរសំបុត្រទៅខ្ញុំវិញថា អង្គការមិនឲ្យមិត្តចេញទេ ។ មិត្តនៅរង់ចាំសេចក្តីសម្រេច ។

[១៤:២២:៤២]

**ឆ៖** ត្រលប់ទៅពេលមួយដែលលោកជាប្រធានស-២១ នោះ តើលោកបានកាត់បន្ថយចំនួនចំណារ ដែលលោកធ្វើនៅលើសេចក្តីសារភាពដែរឬទេ នៅពេលដែល នួន ជា ក្លាយទៅជាមេរបស់លោក? ឬក៏លោកបានកាត់បន្ថយចំនួនដោយសារថា លោក សុន សេន គាត់ត្រូវច្រើន លោកធ្វើច្រើន ប៉ុន្តែពេលនេះលោកមានបន្ថយដែរឬទេ?

**ស៖** ជម្រាបប្រសាសន៍លោកជំទាវ! ដំបូងខ្ញុំអត់បានបន្ថយទេ ដល់ក្រោយមកឃើញ នួន ជា មិនសូវចាប់អារម្មណ៍យកចិត្តទុកដាក់ ខ្ញុំបន្ថយៗ ហើយនិយាយជាមួយនឹងគាត់ទៀត ថាខ្ញុំដូចជាមិនទុកចិត្តសោះលើរឿងឯកសារ ។ គាត់ថា គេក៏ចេះធ្វើការដែរណាមិត្ត នេះគាត់បញ្ជាក់ ។ ដល់ក្រោយមកបានៗខ្ញុំឃើញឯកសារស-២១ ចេញទៅទោះបីខ្ញុំចារក៏ដោយ មិនចារក៏ដោយអចិន្ត្រៃយ៍មជ្ឈិមពិនិត្យ ។ សុទ្ធតែអចិន្ត្រៃយ៍មជ្ឈិម គេពិនិត្យ ។ ដូច្នេះ ចំណារខ្ញុំពិតជានៅរយៈកាលដំបូងនៃការមកដល់របស់ នួន ជា ចំពោះ សុន សេន អ៊ំ! នៃការដែលខ្លួន នួន ជា គាត់បន្ទាបខ្លួនមកក្តាប់ស-២១ ជំនួស សុន សេន ។ ការងារវានៅតែលើ សុន សេន ដដែលទេ ពេលគាត់មកពីសមរភូមិវិញគាត់មើលឯកសាររបស់គាត់ គាត់ចារ ។ ឧទាហរណ៍គាត់ចេញនៅថ្ងៃ-- អ៊ំ! នែ៎ នួន ជា ប្រាប់ខ្ញុំនៅថ្ងៃ ១៥ ខែសីហា ១៩៧៧ ក៏ប៉ុន្តែឯកសារដែលនៅសល់នេះ មានអាថ្ងៃ១១ ខែ១១ ១៩៧៧ ។ ឯកសារដែលខ្ញុំដាក់អមទៅនឹងសេចក្តីបញ្ជាក់របស់ខ្ញុំទៅលើពាក្យបណ្តឹងរបស់អ្នកស្រី ភីង ហ្គុតស៊ុនថារី ចារនៅថ្ងៃ១១ សុន សេន ចារនៅថ្ងៃ ១១ ខែវិច្ឆិកា ១៩៧៧ នេះសូមបញ្ជាក់អ៊ីចឹង ។

ខ្ញុំបានបន្ថយមែន ក៏ប៉ុន្តែការងារវានៅលើគេចាត់ចែងទាំងអស់ គិតគូរទាំងអស់ត្រួតពិនិត្យទាំងអស់ ។

**ស៖** តើលោកធ្លាប់គិតដែរឬទេ ថាលោកមិនសូវយកចិត្តទុកដាក់ខ្លាំងទៅលើការធ្វើចំណារលើសេចក្តីសារភាព ដែលថាមានអ្នកទោសមួយចំនួន ឬក៏អ្នកផ្សេងមួយចំនួនត្រូវស្លាប់ទៅហើយនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! មានអ្នកខ្លះស្លាប់ដោយមិនទាំងបានសួរផង នេះមានមែនសួរអត់ទាន់ ។ ដូច្នេះ ខ្ញុំសូមឆ្លៀតឱកាសនេះដែរបញ្ជាក់ថា អ្នកទោសណាដែលអចិន្ត្រៃយ៍គេយកចិត្តទុកដាក់មែនទែន គេប្រាប់ថា មិត្តឌុច អានេះតាមដានវាឲ្យជាប់ ។ អាហ្នឹងយើងក៏ខំធ្វើទៅ ។ អ្នកណាដែលអចិន្ត្រៃយ៍គេមិនយកចិត្តទុកដាក់ ក៏ទុកចួនអីយកបានចម្លើយ យកមិនបានទេក៏គ្នាស្លាប់បាត់ទៅ ។ នេះគឺវាមានការអនុវត្តនឹងរបៀបនេះ ។

**ស៖** ខ្ញុំចង់ត្រលប់បន្តិចទៅជីវិតគ្រួសាររបស់លោកនៅក្នុងសម័យកាលនោះ ។ ក្រៅពីប្អូនថ្លៃរបស់លោក ដែលស្លាប់នៅស-២១ តើមានសមាជិកក្រុមគ្រួសាររបស់លោកជាគ្រួសារតែមួយនៅមានទំនាក់ទំនងជិតស្និតនឹងគ្នាដដែលដែរឬទេ?

[១៤:២៦:៤៦]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ដំបូងខ្ញុំសូមបញ្ជាក់ថា ប្អូនថ្លៃខ្ញុំដែលស្លាប់នៅស-២១មានម្នាក់ពិតមែន ។ ក៏ប៉ុន្តែ នៅខាងកំពង់ធំមានម្នាក់ទៀត ដែលគេអាច ដែលអចិន្ត្រៃយ៍គេឲ្យខាងឧត្តរសម្រេច ហើយមិនឲ្យខ្ញុំដឹងទាល់តែសោះ គឺប្តីរបស់នាងទីពីរ បន្ទាប់ពីខ្ញុំ ។ សូមបញ្ជាក់ថា ម្តាយខ្ញុំ គាត់តក់ស្លុតណាស់ គាត់ភ័យណាស់ ភ័យខ្លាចតែរបើកខ្ញុំមួយអស់ហើយជីវិតមួយគ្រួសារហ្នឹង ។ ដូច្នេះ វាភ័យនោះទៅវិញទេ មិនមែនមកចោទប្រកាន់ខ្ញុំថា ការពារប្អូនថ្លៃមិនបាននោះទេ គឺភ័យម្តាយខ្ញុំក៏ដោយ ជាពិសេសម្តាយខ្ញុំ ។ ភ័យណាស់ ភ័យខ្លាចតែរបូតខ្ញុំទៅមួយទៀតគ្រួសារហ្នឹងអស់ហើយ អស់មួយពូជគ្មានសល់ទេ ។ ហ្នឹងសូមជម្រាបបញ្ជាក់លោកជំទាវអ៊ីចឹង ។ ដូច្នេះ គ្រួសារយើងខ្ញុំមានការតក់ស្លុតត្រង់ហ្នឹង មិនមែនរឿងការអន់ចិត្តដោយខ្ញុំការពារប្អូនមិនជាប់ទេ ។

**ស៖** ចំពោះសមាជិកក្រុមគ្រួសារផ្ទាល់របស់លោក ដែលជាសាច់ញាតិដូចជាប្រពន្ធ ហើយនិងកូនរបស់លោក កូនប្រុស កូនទីមួយ កូនទីពីរ មិនមានអ្វីកើតឡើងអាក្រក់ចំពោះពួកគេទេ នៅក្នុងពេលដែលលោកធ្វើការងារនៅទីនោះ?

[១៤:២៨:៤២]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ដំបូងខ្ញុំសូមនិយាយអំពីទស្សនៈរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះកុមារជាទូទៅ ។ ពួកនោះទុកកុមារ ទុកកូនយុវជន កម្មាភិបាល កសិករ កម្មករអី ជាកម្មសិទ្ធិរបស់អង្គការ ។ អង្គការជាម៉ែឪ នេះគេគិតអ៊ីចឹង ។ ចំណែក អ្នកណាដែលឪពុកម្តាយត្រូវចាប់ អ្នកឯងត្រូវតែទៅជាមួយឪពុកម្តាយ គេមិនប៊ានទុកខ្លាចអ្នកឯងសងសឹក ។ នេះជាបញ្ហាមួយផ្សេងទៀត ។ ដូច្នេះ កូនខ្ញុំក៏ដោយ កូនកម្មាភិបាលផ្សេងទៀតក៏ដោយ តែកើតមកគឺជាកុមារ គឺជាកូនរបស់បក្ស ជាកូនរបស់អង្គការ ដែលគេយកចិត្តទុកដាក់ដូចគ្នា ។ កូនមិត្ត ហ៊ុយ ស្រែ, នុន ហ៊ុយ ពេលដែលកើតមកមិត្តហ៊ុយ មិនទាន់ចាប់ គេថ្នាក់ថ្នមក្នុងឋានៈជាកូនរបស់អង្គការ ។ ដល់មិត្តហ៊ុយ ត្រូវចាប់កុមារនោះក៏គ្នាស្លាប់ទៅជាមួយឪពុកម្តាយគ្នាបាត់ទៅ ។

ដូច្នេះ ផ្ទាល់ខ្លួនខ្ញុំ បើខ្ញុំនៅតែមិនត្រូវគេចាប់ កូនខ្ញុំក៏នៅតែត្រូវគេទទួលស្គាល់ថា ជាកូនរបស់

អង្គការ នេះគឺសូមជម្រាបបញ្ជាក់ជូនលោកជំទាវប៉ុណ្ណោះ ។

**ស៖** ប៉ុន្តែក្នុងរង្វង់គ្រួសារលោកមានលទ្ធភាពនឹងរស់នៅជីវិតជាក្រុមគ្រួសារជាមួយគ្នា តើអ៊ីចឹងមែនឬទេ?

[១៤:៣០:២៤]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! មានតែក្រោយទេ ចុងក្រោយបំផុតនេះ ទើប-- មើលពីចម្ងាយវាហាក់ដូចជាការមានលទ្ធភាពរស់នៅជាក្រុមគ្រួសារជាមួយគ្នា ព្រោះអី? ព្រោះនៅពេលដែលមានគេឆ្លើយដាក់លោកគ្រូ សុន សេន មេខ្ញុំ ហើយ នួន ជា គាត់ទទួលស្តាប់ដល់ច្រើនៗទៅ សុន សេន គាត់ដេញប្រពន្ធខ្ញុំពីពេទ្យឲ្យមកនៅស-២១ ។ ដូច្នេះ មើលពីនាយមកវាហាក់ដូចជា ខ្ញុំមានលទ្ធភាពរស់នៅជាមួយនឹងគ្រួសារ ។ ក៏ប៉ុន្តែ តាមពិតវាមានន័យស្មើរតែប្រហែលគេដកសិទ្ធិបក្សរួចទៅហើយ នេះគឺៗខ្ញុំសូមជម្រាបលទ្ធភាពរឿងពិតប៉ុណ្ណោះ ។

**ស៖** អ៊ីចឹងលោកនិយាយថា វាមើលទៅហាក់ដូចជាចំណងគ្រួសាររស់នៅជុំគ្នាធម្មតា ប៉ុន្តែតាមការពិតលោកស្ថិតនៅក្រោយការត្រួតពិនិត្យរបស់គណៈអចិន្ត្រៃយ៍ តើមែនឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! កម្មាភិបាលគ្រប់ជាន់ថ្នាក់របស់បក្សកុម្មុយនីស្តកម្ពុជាសុទ្ធតែនៅក្រោមការគ្រប់គ្រងផ្ទាល់ ឬប្រយោលពីអចិន្ត្រៃយ៍ ។ ស-២១ វាស្ថិតនៅក្រោមការគ្រប់គ្រងដំបូងផ្ទាល់ពីសមាជិកអចិន្ត្រៃយ៍ម្នាក់ឈ្មោះ សុន សេន ។ ដល់ក្រោយមកវានៅក្រោម-- វាហាក់ដូចជានៅក្រោមការគ្រប់គ្រងរបស់ នួន ជា ក៏ប៉ុន្តែវាមានមនុស្សពីរនាក់ចេញចូលផ្ទះខ្ញុំព្រឹកល្ងាចបានតាមចិត្ត គឺឈ្មោះ ឈឹម សំអោក ហៅ ប៉ង់ ហើយនិងឈ្មោះ មិត្ត លីន គេមកតាមដានមើលខ្ញុំ ។ ដូច្នេះ ខ្ញុំនៅតែក្រោមការគ្រប់គ្រងរបស់អចិន្ត្រៃយ៍តែដដែល គ្រាន់តែដំបូងវាផ្ទាល់តាមរយៈ សុន សេន គឺ សុន សេន ដល់ក្រោយមកវាប្រយោលទៅនឹង នួន ជា តាមរយៈពួកពីរនាក់នុ៎ង គឺ ប៉ង់ ហើយនិង មិត្ត លីន ។

**ស៖** ប៉ុន្តែ អង្គហេតុដែលថាលោកអាចរស់នៅជាមួយគ្នាជាក្រុមគ្រួសារនោះ ប៉ុន្តែវាមានលក្ខណៈផ្ទុយពីមនុស្សផ្សេងទៀត ដូចជា ក្រុមគ្រួសារ ឬក៏កុមារដែលត្រូវបានគេឃុំខ្លួននៅក្នុងស-២១ ដែលលោកបានប្រទះឃើញជារៀងរាល់ថ្ងៃ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ត្រឹមត្រូវពីព្រោះគេបែងចែក ខ្មាំង មិត្ត ។ មិត្ត គឺមានយុវជន និងកម្មាភិបាល ។ ខ្មាំង គឺអ្នកជាប់ទោស ។

**សៈ** នៅពេលដែលលោកទៅផ្ទះនិងមកកន្លែងធ្វើការ តើលោកធ្លាប់គិតអំពីភាពខុសគ្នារវាងជីវិតគ្រួសាររបស់លោក និងជីវិតរបស់អ្នកជាប់ឃុំនៅមន្ទីរស-២១ ដែរឬទេ?

**ឆៈ** ជម្រាបប្រសាសន៍លោកជំទាវ! រឿងនេះវា *ក្លាស្ស៊ីក* ទៅហើយតាំងពីយើងខ្ញុំនៅម-១៣ម្ល៉េះ ។ វាជាការប្លែកគ្នាបែបនេះ ត្រូវតែអនុវត្ត ។

[១៤:៣៤:២៤]

**សៈ** ខ្ញុំសួរថាតើលោកធ្លាប់ដែលគិតអំពីភាពខុសគ្នារវាងជីវិតគ្រួសាររបស់លោក និងជីវិតរបស់អ្នកឃុំនៅមន្ទីរស-២១ ដែរឬទេ?

**ឆៈ** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំគិត ហើយមិនមែននេះទេ គិតៗតាំងពីនៅម-១៣ម្ល៉េះ ។ គិត វាឃើញប្លែកគ្នា ប៉ុន្តែនេះគេពន្យល់ថា ការប្លែកគ្នារវាងមិត្តនិងសត្រូវ ។ គេពន្យល់អ៊ីចឹង មិត្តត្រូវតែបំពាក់ទស្សនៈនេះឲ្យទៅជាៗខួរក្បាលរបស់ខ្លួន គេថា *ប៊្លូសេដេ សឺតឺកុងសិបស្យុង* ។

**សៈ** តើលោកជាអ្នកសម្រេចក្នុងការមិនបញ្ចូលឈ្មោះកុមារនៅក្នុងមន្ទីរស-២១ ដែរឬទេ?

**ឆៈ** ជម្រាបប្រសាសន៍លោកជំទាវ! រឿងនេះដូចជាខ្ញុំជម្រាបពីដើមមកហែៗមកស-២១ វាជាតំណរបស់កងពលមន្ទីរនគរបាលកងពល៧០៣ តំណនេះវាដំណើរមករហូត អត់បញ្ចូលទេឈ្មោះកុមារ។ មានឃើញតែបួននាក់ប៉ុន្នឹងនៅមន្ទីរៗ គឺកូន ចាច់ ជា បួននាក់ហ្នឹង ក្រៅពីនោះ អត់មានឃើញឈ្មោះកុមារទេ ។

**សៈ** តើនេះជាគោលនយោបាយនៅពេលនោះ ឬក៏យ៉ាងម៉េច ដែលថាក្មេងទាំងអស់នោះ វាមិនមានភាពចាំបាច់អ្វីត្រូវកត់ឈ្មោះចូលទៅក្នុងបញ្ជីទេ? តើវាជាគោលនយោបាយ ឬក៏យ៉ាងម៉េច?

**ឆៈ** បើនិយាយពីទូទាំងប្រទេសខ្ញុំអត់ដឹងទេ ក៏ប៉ុន្តែបើការប្រតិបត្តិនៅស-២១ វារត់របត់ទៅហើយវារត់របត់ទៅអ៊ីចឹង តាំងពីមុនខ្ញុំទៅកាន់កាប់ជាប្រធានស-២១ ម្ល៉េះ ព្រោះគោលនយោបាយកូនរបស់ខ្មាំង គឺខ្មាំង មិត្តកុំទុកខ្លាចវាសងសឹក ។ គោលនយោបាយវាចែងឯនោះ ។ ដូច្នេះ ការប្រតិបត្តិវានៅលើយើងមិនបានកត់ឈ្មោះ នេះជាការប្រតិបត្តិ ។

**សៈ** ការបញ្ជាក់លើកឡើងមួយចំនួនគឺនិយាយអំពីជំនាញរបស់លោកជាគ្រូ និងការស្រឡាញ់ការបង្រៀន ហើយនិងក៏លើកឡើងអំពីជីវិតជាសិស្ស ហើយនិងការដែលលោកព្រួយបារម្ភ និងយកចិត្តទុកដាក់ចំពោះអ្នកដែលក្រីក្រ ។ ថាតើលោកយល់ស្របជាមួយនឹងការលើកឡើងសង្ខេបដូច្នេះ ចំពោះអ្វីដែលគេបានបញ្ជាក់ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំយល់ស្រប ។

**ស៖** ខ្ញុំចង់ដឹងអំពីការយល់ឃើញរបស់លោកទៅលើវិស័យអប់រំនៅក្នុងសម័យរបបខ្មែរក្រហម? ចំពោះខ្ញុំ ខ្ញុំយល់ឃើញយ៉ាងច្បាស់ថា អតីតសិស្សដែលគាត់មកផ្ដល់ភស្តុតាងទាក់ទងទៅនឹងអត្តចរិត គឺបានគោរពលោកក្នុងនាមជាគ្រូ ហើយលោកក៏បានបញ្ជាក់យ៉ាងច្បាស់ថា លោកជាមនុស្សម្នាក់រូបដែលគោរពគ្រូរបស់លោកផងដែរ ។ ហើយលោក កា ស៊ុនបូណាត លើកឡើងអំពីបរិបទវប្បធម៌ទាក់ទងទៅនឹងចម្លើយរបស់គាត់ ។ តើលោកអាចពន្យល់បានដែរឬទេ អំពីគោលនយោបាយដែលលោកបានអនុវត្តនៅមន្ទីរ ស-២១ ថាកុមារមិនត្រូវបានគេឲ្យទៅមានការរៀនសូត្រអប់រំទេ? តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! បញ្ហារៀនសូត្ររបស់កុមារក្រោយ១៧ មេសា វាមិនមែនមានតែនៅស-២១ ទេ ដែលគ្មានអាណាគេគិតគូរ ទូទាំងប្រទេសក៏មិនទាន់គិតគូរដែរ ។ ខ្ញុំបានជម្រាបចៅក្រមស៊ើបអង្កេតរួចហើយ សិក្សាធិការលុប យកគ្រូគ្រប់ជាន់ថ្នាក់ទៅស្រែ លត់ដំឲ្យធ្វើទៅជាកសិករ ។ ផែនការ ប៉ុល ពត ចង់កសាងបឋមសិក្សាបួនឆ្នាំ មធ្យមសិក្សាបួនឆ្នាំ ឧត្តមសិក្សាបួនឆ្នាំ សៀវភៅកំពុងតែសរសេរនៅក្រសួងអប់រំរបស់អ្នកស្រី យុន យ៉ាត ប្រពន្ធ សុន សេន ។ ទើបនឹងបានមួយក្បាលពីរប៉ុណ្ណឹង មិនទាន់ចេញជាគ្រោង ចេញជាអីនៅឡើយទេ ។

ដូច្នេះ ការរៀនសូត្ររបស់កុមារទូទាំងប្រទេសអត់មានអ្នកណាគិតគូរទេ ។ សូមបញ្ជាក់ថា មុន ១៧ មេសា សម័យសង្គ្រាម សៀត ឆែ ហៅ ទុំ លេខាតំបន់២២ នៅទល់មុខភ្នំពេញនេះ បង្កើតឲ្យមានការរៀនសូត្ររបស់ថ្នាក់មធ្យមសិក្សា ត្រូវបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថា សេរីនិយម ។ នេះខ្ញុំ-- វាៗច្បាស់អ៊ីចឹង ប៉ុន្តែវាអត់មានឯកសារអីទេ ជាសម្ដីរបស់ សុន សេន និយាយមកខ្ញុំតាមទូរស័ព្ទ ទុកដូចជាក្បត់ ទុកដូចអីអ៊ីចឹង ។ ឯចំណែក សៀត ឆែ ហៅ ទុំ គាត់សរសេរថា អាហ្នឹង ដើម្បីទាក់ទាញកុំឲ្យមនុស្ស យុវជន វារត់មកភ្នំពេញ អានេះវាទៅអ៊ីចឹង ។

[១៤:៤០:៣៦]

ដូច្នេះ ជំនាន់ ប៉ុល ពត ការរៀនសូត្របែបសង្គមចាស់គេរំលាយចោល វប្បធម៌សង្គមចាស់គេរំលាយចោល គេកសាងការរៀនសូត្របែបថ្មី ដែលមិនទាន់មានអីនៅឡើយ ។ នេះ គឺវាអ៊ីចឹង ដូច្នេះមិនមែនតែ ស-២១ ទេ ដែលមិនគិតគូរសិក្សាធិការទូទាំងប្រទេស ។

**ស៖** តើលោកយល់យ៉ាងម៉េចអំពីគោលនយោបាយនៃការផ្លាស់ប្ដូរយ៉ាងខ្លាំងនៅក្នុងវិស័យអប់រំជាពិសេសក្នុងចំណោមកូនក្មេងទាំងឡាយនៅក្នុងរបបខ្មែរក្រហម? តើលោកយល់យ៉ាងម៉េចដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ហ្នឹងហើយដែល ប៉ុល ពត ហៅថា មហាចលនា មហាជន មហាលោតផ្លោះ មហាអស្ចារ្យនោះ ។ ខាងសិក្សាធិការលោតផ្លោះទៅរកសិក្សាធិការមួយបែបថ្មីសន្ធាង ដែលស្ថិតនៅក្នុងជាការយល់សប្តិ ។ សេដ្ឋកិច្ចឈានទៅដល់សេដ្ឋកិច្ចមួយ ដែលមានតែវណ្ណៈពីរទេ គឺកម្មករ និងកសិករ ។ ការទាក់ទងផលិកម្មទៅតាមគោលការណ៍កុម្មុយនីស្ត ម្នាក់ៗតាមសមត្ថភាពទៅម្នាក់ៗវិញ តាមសេចក្តីត្រូវការ ។ យើងខ្ញុំធ្វើការចង់ងាប់ បាយមួយ អ៎! ពីរពេល មានបារីជក់ប៉ុណ្ណឹង ខោអាវមួយឆ្នាំប៉ុន្មាន គេកំណត់អ៊ីចឹង តាមសេចក្តីត្រូវការអ៊ីចឹង ។

សូមជម្រាបបញ្ជាក់អ៊ីចឹង ។ នេះហើយដែលគេហៅថា មហាចលនា មហាជន មហាលោតផ្លោះ មហាអស្ចារ្យ សេដ្ឋកិច្ចក៏ប្តូរ ស្អីក៏ប្តូរ សាសនាក៏លុបបំបាត់ ។

**ស៖** អ្វីដែលខ្ញុំចង់ដឹង ក្នុងនាមលោកជាគ្រូដែលយកចិត្តទុកដាក់ និងមានជំនាញ តើលោកយល់យ៉ាងម៉េចអំពីគោលនយោបាយចំពោះក្មេង និងក្មេងមកពីកូនកសិករ ដែលមិនត្រូវការចំណេះដឹងទាក់ទងទៅនឹងមិនមានការអប់រំនោះ ។ តើលោកយល់យ៉ាងម៉េច ដែលមិនបានផ្តល់ចំណេះដឹងឲ្យពួកគេផ្សេងៗហ្នឹង?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ចំណេះដឹងដែលបក្សកុម្មុយនីស្តត្រូវការ វាមាន គឺទីមួយទឹកចិត្តស្មោះត្រង់ចំពោះបក្ស ស្មោះត្រង់ទាំងស្រុងនិងដាច់ខាត ធ្វើម៉េចអប់រំគេឲ្យបានស្មោះត្រង់នឹងបក្សទាំងស្រុង ហើយដាច់ខាត នេះទីមួយ ។ ទីពីរ គឺត្រូវឲ្យមានមុខជំនាញក្នុងការងារណាដែលខ្លួនធ្វើ ។ បើកងការពារត្រូវជំនាញក្នុងការការពារ បើអ្នកសួរត្រូវជំនាញក្នុងការសួរ បើអ្នកធ្វើស្រែវាត្រូវជំនាញក្នុងការធ្វើស្រែ ។ នេះគំនិតបែបនោះ ។ ឯចំណែកសិក្សាធិការតាមរបបថ្មីនេះ ដូចខ្ញុំបានជម្រាបលោកជំទាវអ៊ីចឹង វាស្ថិតនៅក្នុងគំរោង ។ សូមរាយការណ៍ជូនប៉ុណ្ណោះ ។

**ស៖** តើលោកយល់យ៉ាងម៉េចទៅលើគោលនយោបាយបែបនុ៎ង?

**ឆ៖** គោលនយោបាយបែបនេះ ទោះបីយើងខ្ញុំយល់ថា អាក្រក់ ថាធ្វើទៅមិនកើត ក៏វាត្រូវតែហៃអើតាមគេ ។ មិនធ្វើមិនបាន មិនទទួលជឿមិនបាន មិនធ្វើឫកជាជឿមិនបាន មិនអនុវត្តតាមគេ គឺមិនបាន ។ នេះវាអត់មានរបត់ទៅណាទេ អត់ប្រកែករួចទេ ។

**ស៖** ដូច្នេះ លោកមិនដែលប្រាប់អំពីទស្សនៈយោបល់របស់លោកទៅកាន់មេរបស់លោក សុន សេន និងអ្នកផ្សេងទៀតទេ អំពីគោលនយោបាយវិស័យអប់រំរបស់បក្សកុម្មុយនីស្តកម្ពុជានោះ?

[១៤:៤៥:២២]

**ឆ៖** មិនៗប៉ានប្រាប់ទេ មិនប៉ានប្រាប់ទេ ។ ខ្ញុំសូមជម្រាបបញ្ជាក់ជូនលោកជំទាវនូវរឿងមួយ ដែលខ្ញុំមិនដែលបានឮសោះ ។ គេមានចម្រៀងមួយ ប៉ុល ពត តែង “បក្សកុម្មុយនីស្តមហិមាអើយ គឺអ្នកនេះហើយជាអ្នករំដោះប្រជាជនកម្ពុជា ឲ្យរួចចាកផុតអំពីការជិះជាន់នានា សាងកម្ពុជា កម្ពុជាថ្មី។ អ្នកប្រដាប់អាវុធដោយលទ្ធិម៉ាក្សលេនីន ជាក់ដ៏មានជោគជ័យ អង់អាចក្លាហាន វាយប្រយុទ្ធក្រៃ ហើយអ្នកខំថ្នែ យើងខ្ញុំឲ្យទៅជាបុត្រកម្ពុជាដ៏ឧត្តម ។ យើងខ្ញុំស្រឡាញ់អ្នកម្ល៉េះណ៎ា យើងខ្ញុំប្តេជ្ញាបូជាជីវិត សម្បត្តិឧត្តមដោយស្មោះស្ម័គ្រ ដោយស្ម័គ្រចិត្ត ឥតបង្ខំ ត្រូវការយើងខ្ញុំស្រេចលើអ្នកហើយ” ។

ដូច្នេះ បក្ខជនមួយរូប វារក្សាចម្រៀងនេះ គេត្រូវឲ្យរក្សាចម្រៀងនេះ ។ ដូច្នេះ អត់មានរឿងអីប្រកែកជាមួយនឹងមាគ៌ាបក្សទេ ។ មាគ៌ាដាក់មកត្រូវតែខំយល់ឲ្យជ្រួតជ្រាប ហើយអនុវត្តឲ្យកើត ។ នេះ គឺសូមបញ្ជាក់អ៊ីចឹង អត់មានពេលណាទៅពិភាក្សាហ្នឹងគេបានទេ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

លោកប្រធាន ថាតើពេលនេះ គឺជាពេលសមស្រប ដែលយើងត្រូវឈប់សម្រាកសិនដែរឬទេ?

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងពេលត្រូវសម្រាក អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងបី និងប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ ។

*[សវនាការសម្រាបពីម៉ោង ១៤:៤៧នាទី ដល់ម៉ោង ១៥:០៧នាទី]*

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។

សូមអញ្ជើញលោកមេធាវី ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអភ័យទោសលោកប្រធាន មុនយើងនឹងចាប់ផ្តើមលើការសវនាការដេញដោល ខ្ញុំសូមជម្រាបជូនអង្គជំនុំជម្រះឲ្យបានជ្រាបថា មេធាវីការពារបានដាក់ជូនក្រឡាបញ្ជីនូវឯកសារមួយចំនួនដែលឯកសារនោះ ត្រូវបានដាក់បញ្ចូល ហើយមានលេខ ERN នៅ E5/9 ជាឯកសារថ្មី ដែលមេធាវីការពារសូមអនុញ្ញាតដាក់ចូលនៅក្នុងសេចក្តីសន្និដ្ឋាន ហើយយើងមិនដាក់ដេញដោលនៅពេលនេះទេ ។ ប៉ុន្តែ ខ្ញុំសូម

ជម្រាបជូនអង្គជំនុំជម្រះថា យើងបានបញ្ជូនឯកសារនេះ ទៅដើមបណ្តឹងរដ្ឋប្បវេណី និងទៅការិយាល័យសហព្រះរាជអាជ្ញារួចមកហើយ ហើយនិងជូនទៅអង្គជំនុំជម្រះផងដែរ ។

ដូច្នេះហើយនៅពេលដែលយើងដល់ថ្ងៃពិភាក្សានោះ គឺថាភាគីគ្រប់ទាំងអស់គឺទទួលបានឯកសារហ្នឹងក្នុងដៃគ្រប់ៗគ្នា ។ អ៊ីចឹងគ្រាន់តែជម្រាបអង្គជំនុំជម្រះឲ្យបានជ្រាប ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ដែលបានផ្តល់ដំណឹងនេះដល់អង្គជំនុំជម្រះ ក៏ដូចជាភាគី ។

ជាកិច្ចបន្ត ខ្ញុំផ្តល់នូវវេទិកាទៅលោកស្រីចៅក្រម ខាតវ៉ាយថ៍ ដើម្បីបន្តតាំងសំណួរដល់ជនជាប់ចោទ ។ សូមអញ្ជើញ ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។

**ស៖** លោក កាំង ហ្គេកអ៊ាវ លោកបានជម្រាបអង្គជំនុំជម្រះកាលពីមុននោះថា ការជ្រើសរើសកុមារដើម្បីឲ្យធ្វើជាអ្នកយាម ហើយឲ្យធ្វើជាអ្នកសួរចម្លើយ ហើយដើម្បីជាអ្នកសម្លាប់អ្នកទោសនៅស-២១ ផង ។ ក្នុងខណៈលោកជាអតីតគ្រូបង្រៀន តើលោកមានចម្ងល់ដែរឬទេ អំពីការអនុវត្តនូវនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយយកកុមារមកប្រើតាមរូបភាពនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! បញ្ហានេះមិនមែនជាត្រឹមតែជារឿងឆ្ងល់ទេ វាជារឿងដែលមិនយល់ស្រប ក៏ប៉ុន្តែត្រូវតែធ្វើតាមគេដោយខានមិនបាន ពីព្រោះគេកំណត់ថាកុមារជាកូនរបស់អង្គការ អង្គការចង្អុលត្រង់ណាទៅត្រង់នុំង ។ រួចដូចខ្ញុំបានជម្រាបលោកជំទាវអង្គជំនុំជម្រះនៅពេលសវនាការលើកមុនហើយ នៅពេលដែលអង្គសវនាការពិភាក្សាអំពីមនុស្សម្នាក់ ខ្ញុំសូមមិនបញ្ចេញឈ្មោះទេ ហើយដោយខ្ញុំភ្លេចលេខកូដបាត់ទៅហើយ ខ្ញុំសូមនិយាយថា កុមារម្នាក់ ក្មេងជំទង់ម្នាក់ដែលខ្ញុំយកមកពីខាងកំពង់ឆ្នាំង ។

គុណធម៌ដែលបក្សកុម្មុយនីស្តកម្ពុជាតម្រូវឲ្យយើងខ្ញុំគិតគឺ ទីមួយ វណ្ណភាព ទីពីរ មានគុណធម៌ស្មោះត្រង់ជាមួយនឹងអង្គការ ទីបី មិនចង់ដឹង មិនចង់ឮអ្វីច្រើនទេ បក្សប្រើធ្វើអីធ្វើហ្នឹងៗ ខំធ្វើនុំង ។ បុគ្គលរូបនេះមិនទាំងស្គាល់ខ្ញុំផង ។ នេះជាភារកិច្ចដែលគេកំណត់ឲ្យខ្ញុំ ក៏ដូចជាបក្សជនគ្រប់រូប អប់រំកសាងកុមារ ។

ដូច្នេះ មិនមែនគ្រាន់តែជារឿងឆ្ងល់ទេ គឺជារឿងដែលត្រូវតែធ្វើ ទោះបីជាមិនពេញចិត្តយ៉ាងណា

ក៏ដោយត្រូវតែធ្វើដោយខានមិនបាន ។

**សៈ** លោកបាននិយាយម្តងហើយម្តងទៀត អំពីការទទួលស្គាល់ពិរុទ្ធភាព ហើយនិងការទទួលខុសត្រូវចំពោះអំពើរបស់លោក ក្នុងចន្លោះថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ខែមករា ឆ្នាំ១៩៧៩ តើមានទិដ្ឋភាពណាមួយនៃការទទួលស្គាល់នេះ ដែលលោកចង់បំភ្លឺ ឬក៏ចង់បន្ថែមជូនអង្គជំនុំជម្រះឲ្យបានជ្រាបដែរឬទេ?

**ឆៈ** ជម្រាបប្រសាសន៍លោកជំទាវ! ការទទួលស្គាល់ពិរុទ្ធភាពរបស់ខ្ញុំនៅក្នុងមន្ទីរស-២១ ខ្ញុំសូមបញ្ជាក់ថាស-២១ វាជាយន្តការមួយដែលមានមនុស្សច្រើនតាមតួលេខដែលយើងត្រូវស្គាល់ទាំងគ្នាជាងពីរពាន់នាក់រួមចំណែកធ្វើ ក៏ប៉ុន្តែមនុស្សអស់នោះ ត្រូវតែគោរពខ្ញុំតែម្នាក់គត់ ព្រោះនៅស-២១ ខ្ញុំជាតំណាងបក្សកុម្មុយនីស្តកម្ពុជានៅក្នុងមន្ទីរនេះ ។ វាគ្រាន់តែគោរពទៅតាមជាន់ថ្នាក់ ។

[១៥:១៤:៣៥]

ដូច្នេះ បុគ្គលិកពិតប្រាកដទាំងឡាយណារបស់ស-២១ ខ្ញុំពិតជាមានអំណាចទៅលើគេ ឲ្យគេប្រព្រឹត្តឧក្រិដ្ឋកម្មដោយខានមិនបាន ។ គេអត់ប៊ានប្រកែកទេ ហើយបញ្ជាខ្ញុំកម្រិតណា គេត្រូវតែធ្វើកម្រិតនេះ នេះជាបញ្ហាមួយ ។ ឯបញ្ហាទីពីរទៀតដែលខ្ញុំឃើញថា ឧក្រិដ្ឋកម្មដែលខ្ញុំអនុវត្តដោយផ្ទាល់ដៃគឺចារលើឯកសារនេះជាបញ្ហាមួយសំខាន់ណាស់ ។ ពីលើនោះទៅទៀត គឺខ្ញុំបង្រៀន ខ្ញុំកម្ចាត់ទស្សនៈត្រឹមត្រូវ ខ្ញុំកសាងទស្សនៈឧក្រិដ្ឋទៅឲ្យគេ ដូចខ្ញុំបានជម្រាបលោកជំទាវរួចហើយ ។

តាមខ្ញុំចាំការណែនាំរបស់ខ្ញុំ ពីថ្ងៃ១៨ កុម្ភៈ ១៩៧៦ ខ្ញុំណែនាំគេថា “មនុស្សដែលបក្សចាប់មកហើយត្រូវកំណត់ថាជាខ្មាំង បើមិត្តមិនកំណត់ថាជាខ្មាំងទេ មិត្តសួរចម្លើយមិនចេញទេ” ។ គេជាបញ្ញាជន គេឃើញមនុស្ស គេគិតតើគ្នាខុសអីចឹងមែនឬមិនមែនៗ? យើងបណ្តោយឲ្យបញ្ញាជនគិតបែបនេះយូរៗបញ្ញាជនអស់ហ្នឹង ទៅជាមានទស្សនៈមួយប្រឆាំងនឹងបក្សខ្លួនឯង ។ បើបញ្ញាជនទាំងអស់នោះគេប្រឆាំងនឹងបក្សខ្លួនឯងហើយ ខ្ញុំដែលទទួលខុសត្រូវពីលើហ្នឹងក៏ត្រូវទទួលទារុណកម្មដែរ ខានមិនបានទេ ខាងផ្លូវបក្ស គឺខ្ញុំត្រូវទទួលខុសត្រូវអីចឹង ។ ដូច្នេះ ការអប់រំនេះជាឧក្រិដ្ឋកម្មទីពីរ ។

ឯចំណែកឧក្រិដ្ឋកម្មដែលខ្ញុំមើលជារួម គឺខ្ញុំកសាងអ្នកបន្តដៃ ដូចខ្ញុំបានជម្រាបលោកជំទាវអំមិញអីចឹង ។ ខ្ញុំតែម្នាក់ឯងស្មោះត្រង់ជាមួយនឹងបក្សបានតែមួយទេ បើខ្ញុំកសាងអ្នកផ្សេងទៀតបានម្ភៃ គេអរឧក្រិដ្ឋកម្មវាកាន់តែទូលាយ និងជម្រៅឲ្យគេ ។

សរុបមកពាក្យដែលខ្ញុំថាធ្វើការហ្មត់ចត់ ពាក្យដែលថាខ្ញុំឧស្សាហ៍ ពាក្យដែលខ្ញុំថាព្យាយាមខ្នះ

ខ្វែងសព្វបែបយ៉ាងទាំងអស់នេះ ។ បើនិយាយនៅក្នុងរដ្ឋាភិបាលមួយ ដែលស្នេហាជាតិពិតប្រាកដ វាជាគុណធម៌របស់ខ្ញុំដែលខ្ញុំត្រូវតែទទួល ។ ក៏ប៉ុន្តែ ដល់រដ្ឋាភិបាលនេះវាជាយន្តការឧក្រិដ្ឋដ៏សែនឃោរឃៅសម្រាប់សតវត្សនេះ ការងារទាំងប៉ុន្មានដែលខ្ញុំធ្វើនេះ វាទៅជារឿងមួយរំឭកឡើងពេលណា គួរឲ្យឈឺចាប់ ហើយនិងខ្មាស់អៀនពេលនោះ ។ នេះជម្រាបលោកជំទាវយ៉ាងនេះ ។

ខ្ញុំសូមបញ្ចប់ចម្លើយខ្ញុំត្រឹមប៉ុណ្ណោះ ។

**ស៖** វាទំនងជាបង្ហាញថា ម្យ៉ាងទៀតលោកនៅតែសមាជិកដែលមានស្វាមីភក្តិ ហើយនិងស្មោះត្រង់ចំពោះបក្សកុម្មុយនីស្តកម្ពុជាច្រើនឆ្នាំបន្ទាប់ពី ខែមករា ឆ្នាំ១៩៧៩ ។ ហើយម្យ៉ាងទៀត លោកបាននិយាយថា តាមពិតលោកបានបង្កើន ចេះតែសង្ស័យឡើងច្រើនឡើងថា លោកអាចនឹងក្លាយជាអ្នកទោសរបស់របបនោះដែរ ដែលបញ្ជាក់នៅក្នុងដីកាដំណោះស្រាយ ។ ថាតើលោកបានសម្រេចថានឹងចេញពីបក្សកុម្មុយនីស្តកម្ពុជាក្នុងពេលណាមួយដែរឬទេ មុនពេលដែលគេចាប់ខ្លួនលោកនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ការមិនពេញចិត្តពិតជាមាន ការចង់ចេញក៏ពិតជាមាន ក៏ប៉ុន្តែកើតជាមនុស្សត្រូវលៃផ្លូវដើរឲ្យស្រួល ។ សុភាសិតខ្មែរមួយម៉ាត់គេនិយាយថា “ដាក់ជើងក្រោយឲ្យស៊ុបសិន សឹមលើជើងមួយទៀត ឈានជំហានទៅមុខ” ។ បើយើងដាក់ជើងក្រោយមិនទាន់ស៊ុបទេ យើងឈានជំហានទៅមុខមិនបានទេ ដួល ។ ដូច្នេះ ដើម្បីនឹងចេញកើត វាទាល់តែមានលក្ខណៈសម្បត្តិសត្យានុម័តិដែលអាចឲ្យយើងចេញបាន ដូចជាខ្ញុំធ្វើរួចមកហើយនេះ ។ នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាមិនប្រគល់ឲ្យ អ៊ុនតាក់ ដកអារុធ ធ្វើឲ្យមេខ្ញុំស្អុកស្អាញមិនហៅខ្ញុំទៅធ្វើការ ។ ដល់ក្រោយមកអ៊ុនតាក់ សម្រេចវិក្តិបច្ច នៅក្នុងខែសីហា ខ្ញុំមិនចាំខែ ។ ពេលហ្នឹងហើយ ដែលខ្ញុំដាច់ខ្សែជាមួយនឹងមេ ក៏ប៉ុន្តែវានៅយូរៗ អាល្អួបគេមកវៃម្តងនៅផ្កាំ ។ លោកជំទាវឮហើយ ប៉េង ពាន់ និយាយក្នុងសវនាការនេះ ។

[១៥:២០:២០]

ដូច្នេះ យើងត្រូវគិតឲ្យសព្វ មុននឹងលើកជើងបោះជំហានទៅមុខត្រូវឈរឲ្យរឹងប៉ឹងសិន ។ ហ្នឹងគឺជម្រាបបញ្ជាក់លោកជំទាវប៉ុណ្ណោះ ខ្ញុំបានគិតគូរថ្លឹងថ្លែងដំណើរការដើម្បីកុំឲ្យគ្រោះថ្នាក់ ក៏ប៉ុន្តែនៅតែគ្រោះថ្នាក់ សម្លាប់បានទាំងប្រពន្ធ ខ្លួនឯងរបួសទៀត ។

**ស៖** នៅក្នុងពេលដែលគាត់ផ្តល់សក្ខីភាព ហ្វ្រង់ស័រ ប៊ីរ៉ូនី ហ្បៀលបូ គាត់បាននិយាយអំពីដំណើរការផ្លូវចិត្តសាស្ត្រដែលលោកបានឆ្លងកាត់ ។ នៅពេលចាប់ផ្តើមសវនាការនេះ លោកបានសម្តែង

ពីវិប្បដិសារីរបស់លោកអំពីការឈឺចាប់របស់ជនរងគ្រោះនៃស-២១ ។ តើលោកមានអារម្មណ៍ខុសពីហ្នឹងទេបន្ទាប់ពីសវនាការបានឮមនុស្សមួយចំនួនជាអ្នកជាប់ឃុំនៅស-២១ ហើយអ្នកដែលធ្លាប់ធ្វើការនៅស-២១ ឬក៏អ្នកដែលរស់រានមានជីវិត ក្នុងចំណោមអ្នកដែលស្លាប់នៅក្នុងស-២១ តើលោកមានអារម្មណ៍ថាមានវិប្បដិសារី ខុសពីអ្វីមុនទេបន្ទាប់ពីបានស្ដាប់ពួកអ្នកអស់ទាំងនោះរួចមក?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! វិប្បដិសារីរបស់ខ្ញុំមាន ហើយវាមានការវិវឌ្ឍន៍ ត្រង់ដែលសាស្ត្រាចារ្យ ស៊ីរ៉ូនី មើលខ្ញុំទាន់ ឬមិនទាន់ ខ្ញុំមិនបានជាពិនិត្យពិច័យការសិក្សាវិភាគរបស់គាត់ទេ ។ ចំណែកខ្ញុំ ខ្ញុំដឹងថាខ្ញុំមានការវិវឌ្ឍន៍ទៅមុខ ខាងវិប្បដិសារីរបស់ខ្លួនដែលបានប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុងមន្ទីរស-២១ ។

លោកជំទាវឃើញនឹងភ្នែកស្រាប់ហើយ ជនរងគ្រោះពិតប្រាកដ ចង្អុលមុខខ្ញុំចុះ! ថ្កោលទោសខ្ញុំចុះ! ខ្ញុំអត់ប៉ិនប្រកែកនឹងគេមួយមាត់ទេ ខ្ញុំឱនលំទោន ទទួលការស្ដីបន្ទោសដោយស្មោះ នេះវាវិវឌ្ឍន៍ទៅអ៊ីចឹង ។ ហើយសូមជម្រាបលោកជំទាវដោយស្មោះថា ម្សិលមិញមិត្តភក្តិខ្ញុំចាស់ ស៊ូ សាត នៅពេលដែលជួបគ្នាហ្នឹង គេចង្អុលមុខខ្ញុំណា គេថា អ៊ាវ ឯងនេះលង់ខ្លួននឹងជឿ ប៉ង់សេម៉ៅ សេទុង គេនិយាយបារាំង ។ គេនិយាយបារាំងមួយកំណាត់ ខ្មែរមួយកំណាត់អ៊ីចឹង បានន័យថា ខ្ញុំនេះវាឆ្កួតនឹងគំនិតម៉ៅសេទុង ។ ខ្ញុំទទួល ។ ប៉ុន្តែខ្ញុំមិនប្រើរូបមន្តបែបនេះទេ ខ្ញុំយកដៃទៅដាក់លើជើងគេ គេអង្គុយលើកៅអីខ្ញុំអង្គុយលើគ្រែ ខ្ញុំយកដៃដាក់លើជើងគេ មើលមុខគេធ្វើភ្នែកម៉ក់ៗ ។ គេបន្តទៅទៀតតើ គេថាម៉ៅសេទុង ហ្នឹងវាខុសអំប្លា ឲ្យប្រពន្ធដឹកច្រមុះ ។ ដល់និយាយអ៊ីចឹង ខ្ញុំអើ ក្នុងឋានៈជាមិត្តភក្តិ ហើយទស្សនៈវាមិនត្រូវអ៊ីចឹងដែរ កុំចេះតែថា អ្នកឯងមិនមែនអ្នកនយោបាយផង ។ នៅតែដាក់លើជើងគេ ហើយនៅតែនិយាយពាក្យបដិសេធហ្នឹងបែបឱនលំទោន ។

[១៥:២៤:០៥]

គេនិយាយមួយមាត់ទៀតថា អ្នកដឹកនាំខ្មែរហ្នឹងមិនដឹងជាស្អីផងទេ។ ដល់គេនិយាយមកអ៊ីចឹងខ្ញុំទទួលទៀត ។ ខ្ញុំថា អ៎ហ្នឹងគេខឹងហើយអ្ហែ ។ សរុបមក ការដែលគេចង្អុលមុខខ្ញុំ គេស្ដីបន្ទោសឲ្យខ្ញុំបែបនេះ ខ្ញុំឃើញអារម្មណ៍របស់គេ ថាគេគិតគួសោកស្ដាយជំនួសខ្ញុំដែរនូវការដែលខ្ញុំសម្រេចចិត្តខុស ។

ដូច្នេះ វិប្បដិសារីវាមាននៅក្នុងអំពើប្រព្រឹត្ត ដូចដែលខ្ញុំនិយាយហូរហែមក ទោះបីជាតិប្រជាជនកម្ពុជា លោកដាក់ទោសខ្ញុំយ៉ាងម៉េច ខ្ញុំអត់ប្រកែកទេ ។ នេះវិប្បសារីវាស្ដែងចេញមកពីអ៊ីចឹង ទាំងអស់ឲ្យសូមទោស សូមទោស។ បើកទ្វារឲ្យសូមទោសម៉ោងណា ខ្ញុំសូមទោសម៉ោងហ្នឹង ។ ចង្អុលមុខខ្ញុំនៅ

ក្នុងអង្គសវនាការក្តី នៅឯណាក្តី ខ្ញុំអត់ប្រកែកទេ ។ នេះវិប្បដិសារីវាស្តែងចេញមកអំពី មកអំពើជាក់ស្តែងបែបនេះ ។ ហើយចុងបញ្ចប់ខ្ញុំនិយាយ នៅពេលដែលអ្នកជំនាញខាងចិត្តសាស្ត្រទាំងពីរ លោកសាស្ត្រាចារ្យទាំងពីរលោកនេះ ខ្ញុំថា សូមមេត្តាជួយផ្តល់យោបល់យ៉ាងម៉េចដល់ខ្ញុំផង។ ឲ្យមនុស្សជាតិទាំងមូល លោកទទួលស្គាល់ខ្ញុំជាមនុស្សម្នានឹងគេផង ។ នេះក៏ជាសម្តែងចេញអំពីការសោកស្តាយរបស់ខ្ញុំមកជាអំពើប្រព្រឹត្តជាក់ស្តែងរួចហើយ ។ នេះសូមគោរពរាយការណ៍ជូនលោកជំទាវប៉ុណ្ណេះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ខ្ញុំមិនមានសំណួរអ្វីទៀតទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ចំពោះហេតុការណ៍ដែលថា អំពើមួយចំនួនដែលគេបានចោទប្រកាន់នោះ គឺជាអំពើដែលមិនអាចជឿជាក់ថា ជាអំពើហិង្សាមួយ ។ អ៊ីចឹង តាមទស្សនៈរបស់លោកនៅក្នុងខ្សែជីវិតរបស់លោកក្នុងកុមារភាព ឬក៏ក្រោយពីហ្នឹងមកទៀតលោកបានប្រឈមមុខនឹងស្ថានភាពមួយចំនួននៃការហិង្សាដែលអាចពន្យល់ អំពីការចូលរួមនៅក្នុងការប្រព្រឹត្តអំពើ ដែលបានចោទប្រកាន់ ។ អ៊ីចឹង ចំពោះវ័យកុមាររបស់លោក តើលោកបានប្រឈមមុខនឹងបញ្ហាអំពើហិង្សាអ្វីខ្លះ? ថាតើទំនាក់ទំនងនៅក្នុងក្រុមគ្រួសាររបស់លោក តើលោកធ្លាប់ទទួលរងអំពើហិង្សានៅក្នុងសាលាដែរឬទេ? នោះជាអំពើដែលលោកធ្លាប់បានទទួល ឬក៏ទទួលស្គាល់ថាមានដែរឬទេ?

[១៥:២៧:៣៤]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ក្នុងជីវិតខ្ញុំ គឺកុមារភាព ខ្ញុំមិនបាននិយាយទេ រឿងមួយនេះ ពីព្រោះវាប៉ះពាល់ដល់គុណគ្រូដែលខ្មែរយើងធ្លាប់គោរព ។ នៅថ្នាក់អតិកដ្ឋាន មានគ្រូម្នាក់វ៉ៃខ្ញុំទាំងបំពាននូវកំហុសមួយដែលខ្ញុំអត់បានប្រព្រឹត្ត ។ នៅករណីនេះ ម្តាយខ្ញុំគាត់ប្តឹង។ ប៉ុន្តែ ដល់ក្រោយមកខ្ញុំអាណិតដែរគ្រូខ្ញុំគាត់ត្រូវឈឺស្លាប់បាត់ទៅហើយ ។ ដូច្នេះ ខ្ញុំក៏មិនមានចាត់ទុកគាត់ជាស្អីតទៅទៀតទេ នេះជារឿងមួយ ។ រឿងពីរ ឧក្រិដ្ឋកម្មរបស់អ្នកនយោបាយទៅលើជាតិប្រជាជនកម្ពុជា។ ឧទាហរណ៍ដូចខ្ញុំបានរាយការណ៍ជូនលោកចៅក្រមអ៊ីចឹង លន់ នល់ គាត់ទៅកាត់កកសិករនៅសំឡូតនៅឆ្នាំ១៩៦៦។ ដូច្នេះ ខ្ញុំក៏មានទស្សនៈមួយដូចដែលគេសរសេរនៅក្នុងបដា ពេលដែលមានគ្រាប់ផ្លាស្ទិក មួយគ្រាប់ផ្ទុះ

នៅក្នុងវាំង គ្រាប់បែកហ្នឹងផ្ទុះទៅសម្លាប់ព្រះអង្គម្ចាស់ មាឃវណ្ណ, នរោត្តម មាឃវណ្ណ ។ បងានោះគេសរសេរ ថា “ទុកអាយុជីវិតឲ្យសត្រូវៗ គឺសម្លាប់ប្រជាជនខ្លួនឯង” ។

សរុបមក ទោះបីមានបាតុភាពយ៉ាងនេះក៏ដោយ ទោះបីមានចម្រៀង ដូចដែលខ្ញុំបានធ្លាប់រាយ-ការណ៍ជូនថៅក្រុមស៊ើបអង្កេតក៏ដោយ អំពីរឿងអាគីងចង្រៃ ចម្រៀងឈ្មោះអាគីងចង្រៃហ្នឹងក៏ដោយ។ បើពាក្យស្លោករបស់បក្សកុម្មុយនីស្តកម្ពុជាថា “បំណុលឈាម ត្រូវតែសងដោយឈាមក៏ដោយ” ក៏ការទទួលភារកិច្ច ជាប្រធានមន្ទីរនគរបាលតាំងពីម-១៣ រហូតមក វាស្ថិតនៅក្នុងក្របខ័ណ្ឌមួយដែលជៀសមិនរួច ។ ហើយវាស្ថិតនៅក្នុងក្របខ័ណ្ឌមួយ ដែលខ្ញុំអង្វរកគេ ដែលគេក៏សុខចិត្ត មិនបង្ខំឲ្យខ្ញុំសម្លាប់មនុស្សដោយដៃឯង ។ មិនទាមទារចាប់អ្នកនេះ ឬចាប់អ្នកនោះទាល់តែសោះ។ ទោះបីមានហេតុផលបែបនេះក៏ដោយ ក៏ឧក្រិដ្ឋកម្មដែលឯងធ្ងន់ធ្ងរបំផុត ខ្ញុំពិតជាទទួលថា វាពិតជាធ្ងន់ធ្ងរមែនសកម្ម-ភាពដែលខ្ញុំធ្វើចន្លោះពី ១៧ មេសា រហូតដល់ ៦ មករា ដោយចាប់ផ្ដើមពី ១៨ សីហា ខ្ញុំ ៧៥ ខ្ញុំជាអនុប្រធាន ហើយពី ខែមីនា ១៩៧៦ ខ្ញុំជាប្រធាន ។ ដូច្នេះឧក្រិដ្ឋកម្មទាំងនេះ វាពិតជាធ្ងន់ធ្ងរ ខ្ញុំទទួលស្គាល់ពេញទី ។ ខ្ញុំសូមបញ្ចប់សេចក្ដីរាយការណ៍របស់ខ្ញុំប៉ុណ្ណេះ សូមគោរព ។

[១៥:៣៥:៥៥]

**សៈ** យើងនិយាយអំពីអំពើហិង្សាឡើងវិញ ។ លោកបានជម្រាបយើងខ្ញុំថា ចំពោះបុគ្គលមួយចំនួនហើយដោយសារតែការអប់រំ គឺអ្នកទាំងអស់នោះត្រូវបានគេអនុញ្ញាតឲ្យប្រើប្រាស់នូវអំពើហិង្សាទោះបីជាអំពើហិង្សានោះ មិនត្រឹមត្រូវក៏ដោយ លោកបានរៀបរាប់ថា សាស្ត្រាចារ្យរបស់លោក ដែលបានវាយលោក ហើយគាត់វាយលោកដោយមិនត្រឹមត្រូវនោះទេ ។ ប៉ុន្តែ យ៉ាងណាក៏ដោយ ទោះបីជាគាត់វាយលោកក៏ដោយ លោកជឿថា គឺថាគាត់ជាសាស្ត្រាចារ្យរបស់លោក ទើបគាត់អាចវាយលោកបាន ថាតើដោយសារតែគាត់ជាសាស្ត្រាចារ្យ ទើបលោកយល់ថា អំពើហិង្សានោះគឺវាត្រឹមត្រូវចំពោះលោក ឬយ៉ាងម៉េច?

**ឆៈ** រឿងនេះ វាជារឿងចាស់តាំងពីឆ្នាំ១៩៥៣ មកម្ល៉េះ ។ បើខ្ញុំគិតអំពីការយល់ដឹង និងសតិអារម្មណ៍របស់ខ្ញុំកាលនោះ ខ្ញុំខឹងនឹងគ្រូដែរ ខ្ញុំតូចចិត្តនឹងគ្រូដែរ ដឹងថាគាត់ខុស ដឹងថាគាត់កាច ក៏ប៉ុន្តែខ្ញុំខិតខំបំភ្លេច ។ ដល់ក្រោយមកគាត់សម្លាប់ អ៎!គាត់ស្លាប់ខ្លួនគាត់បាត់ទៅ ខ្ញុំក៏បំភ្លេចរឿងហ្នឹងបានទៅវិញទៅ ។

បើនិយាយអំពីផ្លូវមនុស្សជាតិ ផ្លូវមនុស្សធម៌ គ្មានអំពើហិង្សាណាដែលត្រូវអត់ឱនឲ្យបានទេ ។

ក៏ប៉ុន្តែ បក្សកុម្មុយនីស្តកម្ពុជា គេមានពាក្យមួយម៉ាត់ គេហៅថា ហិង្សាបដិវត្តន៍ ហិង្សាវណ្ណៈ ។ នេះហើយជារបបទស្សនវិជ្ជាមួយដែលឃោរឃៅបំផុត ដែលអាក្រក់បំផុតរបស់កុម្មុយនីស្ត ហើយដូចព្រឹកមិញដែរ ដែលខ្ញុំបាននិយាយថា វាផ្ទុយនឹងច្បាស់សាសនា ពុទ្ធសាសនា ផ្ទុយនឹងច្បាប់របស់ពុទ្ធសាសនា ផ្ទុយនឹងច្បាស់គ្រឹស្តសាសនា ផ្ទុយនឹងច្បាស់ឥស្លាម ។ ដូច្នេះខ្ញុំឃើញថា នៅក្នុងលោកនេះគ្មានហិង្សាណាដែលត្រូវអត់ឱនបានទេ ។ មិនមែនដូចពាក្យកុម្មុយនីស្ត គេថាមានហិង្សាមួយបែបហ្នឹងហៅថាហិង្សាបដិវត្តន៍ ហៅថា ជាគុណធម៌នោះទេ អាហ្នឹងឃោរឃៅណាស់ ។

**ស៖** និយាយអំពីប្រធានបទនេះដដែល ទាក់ទងទៅនឹងកាលដែលលោកជួបប្រទះនូវអំពើហិង្សានៅក្នុងប្រវត្តិរបស់លោក ។ នៅក្នុងការអប់រំរបស់លោក និងនៅក្នុងក្រុមគ្រួសារ ថាតើមានអំពើហិង្សាកើតឡើងដែរឬទេ? ឬក៏វាអាចមានដែរឬទេ ហើយលោកយល់ថា អំពើហិង្សាទាំងអស់នោះ គឺវាត្រឹមត្រូវដែរឬទេ? ឬក៏ពេលខ្លះទៅឪពុកម្តាយរបស់លោកមានការវាយលោក ដើម្បីឲ្យលោកកែខ្លួនដែរឬទេ?

**ឆ៖** សូមជម្រាបលោកចៅក្រមថា ម្តាយខ្ញុំគាត់នៅរស់នៅឡើយទេ ខ្ញុំមិនចង់ទាំងប៉ាននិយាយបញ្ហានេះផង ប៉ុន្តែជាក់ស្តែងនៅពេលណាដែលខ្ញុំខុសពិត គាត់វាយមួយរំពាត់ពីរ មានអី អត់ឈឺ ។ បើកាលណាខ្ញុំមិនខុសៗ គ្រាន់តែគាត់ស្តីឲ្យហ្នឹង ក៏ខឹងដែរ ក៏តូចចិត្តនឹងគាត់ដែរ ។

សូមបញ្ជាក់ថា ម្តាយខ្ញុំគាត់មិនវ៉ៃខ្ញុំនឹងស្អីទេ វ៉ៃខ្ញុំនឹងក្បាបដូង ។

**ស៖** ប្រសិនបើខ្ញុំយល់មិនខុសនោះទេ លោកគឺជាកូនបងគេនៅក្នុងក្រុមគ្រួសារ ថាតើដោយសារតែលោកជាកូនបងនេះហើយ ទើបឲ្យលោកមានឋានៈមួយពិសេសនៅក្នុងគ្រួសារ ថាលោកមានតួនាទីធំជាងគេ ហើយអប់រំចិញ្ចឹមថែទាំ បងប្អូន ប្អូនប្រុសផងដែរ ។ ដូច្នេះ ទាំងអស់នេះហើយ គឺវាបានផ្តល់លទ្ធភាពឲ្យលោកប្រើប្រាស់អំពីហិង្សា ដូចជាវ៉ៃមួយរំពាត់ ពីរបីរំពាត់ ដើម្បីកែតម្រូវប្អូនៗរបស់លោក តើអ៊ីចឹងមែនទេ?

[១៥:៤៤:៥៦]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំពិតជាកូនច្បង ។ ក៏ប៉ុន្តែដូចខ្ញុំ ហើយនិងសាក្សីជាច្រើនបាននិយាយថា ខ្ញុំគិតតែពីរៀនទេ ។ ប្អូនៗស្រេចនៅលើម្តាយខ្ញុំ ហើយការអប់រំប្អូនៗដែលជាប់លាប់ជាងគេ គឺប្អូនស្រីម្នាក់ដែលបន្ទាប់ខ្ញុំ ។ នេះជារឿងនៅក្នុងក្របខ័ណ្ឌគ្រួសារខ្ញុំ ដែលមានលក្ខណៈអ៊ីចឹង ។

**ស៖** នៅពេលដែលលោកធ្វើជាគ្រូ ថាតើការងារបង្រៀនរបស់លោកនោះ តើវាមានករណីកើតឡើងដែលថាលោកធ្លាប់វាយ ឬក៏ប្រើអំពើហិង្សាដែរឬទេ នៅក្នុងពេលដែលលោកបង្រៀននោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! អត់មានទេ ។ សូមបញ្ជាក់ថា សូមជម្រាបបញ្ជាក់ថា នៅបឋមសិក្សា គ្រូអាចវ៉ៃសិស្សបានខ្លះ ។ ចំណែកនៅមធ្យមសិក្សា គ្រូវ៉ៃសិស្សអត់បានទេ ។ នេះគឺការពិតនៅសិក្សាធិការជំនាន់ខ្ញុំចេញធ្វើគ្រូ ។

**ស៖** ចុះចំពោះលោកផ្ទាល់ តើលោកជឿថាការវ៉ៃនេះ គឺជាអ្វីដែលគេបង្រៀននៅក្នុងគរុវិជ្ជាដែរឬទេ? គឺវាផ្ទុយទៅនឹងបញ្ហានៃការបង្រៀនផ្នែកគរុវិជ្ជាដែរឬទេ? *(សូមកែតម្រូវ)*

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! កាលដែលខ្ញុំធ្វើគ្រូនៅឡើយ ខ្ញុំអត់បានគិតដល់ជម្រៅនៃបញ្ហានេះទេៗ ក៏ប៉ុន្តែគ្រូខ្លះធ្វើគំរូឲ្យខ្ញុំ ជាគំរូរស់ មិនបាច់វ៉ៃទេ តែសិស្សចូលចិត្ត ។ នៅមធ្យមសិក្សាមានគ្រូតែម្នាក់គត់ ដែលចេះងោកងាកដាក់កូនសិស្សហ្នឹង នៅកំពង់ធំៗ ។ ងោកងាកទេមិនមែនវ៉ៃទេ សម្លុតកំហែង ឡូឡា អត់អូសស៊ីទេណ៎ា គឺគ្រូតែម្នាក់គត់ដែលហ៊ានកំហែងដែលងោកងាកដាក់សិស្ស ។ ក៏ប៉ុន្តែខ្ញុំពេលនោះ ខ្ញុំឃើញតែគ្រូហ្នឹងចំណេះវិជ្ជាខ្សោយ បានៗប្រើការកំហោកកំហែងសិស្ស ។ ឯចំណែកគ្រូខ្ញុំច្រើនលើសលុប គេអត់ប្រើហិង្សាទេ តែសមត្ថភាពគេមាន សិស្សពេញចិត្ត សិស្សស្រួលយល់ សិស្សស្រួលចាំ ។ នេះគឺជាការសង្កេតរបស់ខ្ញុំតាំងពីនៅថ្នាក់ទី៣ ។

**ស៖** ទោះបីជាលោកមិនបានគិតច្រើនទៅលើបញ្ហានេះក៏ដោយ យ៉ាងហោចណាស់លោកក៏បានកោតសរសើរចំពោះអ្នកដែលធ្លាប់ជាគំរូរបស់លោក ដែលគាត់ទាំងនោះមិនបានប្រើនូវអំពើហិង្សាចំពោះសិស្ស តើនេះជាអ្វីដែលខ្ញុំយល់ត្រឹមត្រូវដែរឬទេ?

[១៥:៥១:៥១]

**ឆ៖** អរគុណលោកចៅក្រម ត្រូវហើយ ។

**ស៖** នៅពេលនេះ ខ្ញុំសូមលើកនូវប្រធានបទមួយទៀត ដែលវាខុសគ្នាបន្តិចទៅនឹងអំពើហិង្សានេះ វាជាទាក់ទងទៅនឹងអំពើហិង្សាផ្នែកនយោបាយម្តង ។ លោកបាននិយាយថា លោកបានជួបប្រឈមទៅនឹងហេតុការណ៍ហិង្សាប្រភេទនយោបាយនេះ តើលោកអាចជម្រាបយើងខ្ញុំដែរឬទេ នៅក្នុងប្រវត្តិរបស់លោក តើនៅពេលណាមួយដែលលោកចាត់ទុកថាអំពើហិង្សាផ្នែកនយោបាយទាំងនោះ វាត្រឹមត្រូវសម្រាប់គេ? នៅពេលណាដែលវាបញ្ជាក់ថាវាត្រឹមត្រូវក្នុងការអំពើទាំងអស់នោះ ហើយដោយសារមូលហេតុអ្វី?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ថ្ងៃនេះ ពីលើកមុន ខ្ញុំបាននិយាយអំពីទិញផ្សារនយោបាយនៅសំឡូត ហើយខ្ញុំក៏បាននិយាយអំពីហិង្សានយោបាយនៅឥណ្ឌូនេស៊ី ។ ហើយខ្ញុំក៏ធ្លាប់និយាយអំពីទោសឧក្រិដ្ឋរបស់ពួកអាក្រុមបួននាក់ចិនដែរ ។ ដូច្នេះ ជាទស្សនៈរបស់ខ្ញុំគ្រប់ពេលវេលាមិនដែលទទួលស្គាល់ថា ហិង្សានយោបាយជាភាពត្រឹមត្រូវទេ ។

**ស៖** ខ្ញុំគិតថាប្រហែលជាមានបញ្ហាបន្តិចទាក់ទងទៅនឹងការបកប្រែ ដូច្នេះ សូមអនុញ្ញាតឲ្យលោករៀបរាប់ឡើងវិញបន្តិច នៅចំណុចអម្បាញ់មិញនេះ ។

[១៥:៥៤:៣០]

**ឆ៖** ហិង្សានយោបាយនៅសំឡូតក៏ដោយ ។ នៅឆ្នាំ១៩៦៦ ដដែលហ្នឹង មានហិង្សានយោបាយមួយនៅឥណ្ឌូនេស៊ី ហើយនៅ៦៦ ដដែលហ្នឹង មានហិង្សានយោបាយមួយនៅចិន ។ ហិង្សានយោបាយទាំងអស់ ខ្ញុំមិនដែលទទួលស្គាល់ថា ត្រឹមត្រូវទេ ។ ទោះបីបក្សកុម្មុយនីស្តកម្ពុជាខំអប់រំ ហើយអប់រំទៀត ថាហិង្សាវណ្ណៈ ហិង្សាបដិវត្តន៍ វាត្រចះត្រចង់យ៉ាងណាក៏ដោយ ។

**ស៖** ខ្ញុំជឿថា នៅក្នុងប្រវត្តិផ្ទាល់របស់លោក គឺមានពេលមួយនោះដែលលោកធ្វើការជ្រើសរើសសម្រេច ហើយនិងប្ដេជ្ញាចំពោះបក្សកុម្មុយនីស្តកម្ពុជា។ ថាតើលោកទទួលស្គាល់អំពីការប្ដេជ្ញារបស់លោកចំពោះបក្សកុម្មុយនីស្តកម្ពុជា ថាវាជាការត្រឹមត្រូវដែរឬទេ? ហើយលោកទទួលស្គាល់អំពើហិង្សាផ្នែកនយោបាយដែរឬទេ នៅពេលលោកប្ដេជ្ញាចំពោះបក្សកុម្មុយនីស្តកម្ពុជានោះ? យើងឃើញថាវាភាពខុសគ្នាបន្តិច ចំពោះគ្រូដែលគាត់ជឿថា អំពើហិង្សាគឺវាមិនសមរម្យឡើយ នៅក្នុងសង្គមស៊ីវិល្ឡ ហើយវាមានការផ្លាស់ប្ដូរនៅលើចំណុចនេះ ដូច្នេះហើយសូមឲ្យលោកពន្យល់លើហេតុផល ហើយនិងជម្រើសរបស់លោកនៅពេលដែលជ្រើសរើសផ្ទាល់នៅពេលនោះ?

[១៥:៥៧:០៣]

**ឆ៖** សូមជម្រាបដោយត្រង់ថា សំណួររបស់លោកចៅក្រម ខ្ញុំក្ដាប់មិនទាន់បានទេ តែខ្ញុំសូមៗឆ្លើយតាមការយល់ដឹងរបស់ខ្ញុំ ។ ប៉ុន្តែ បើសិនខុសយ៉ាងម៉េច សូមលោកចៅក្រមមេត្តាសួរម្ដងទៀត ។ កាលនោះ ចូលបដិវត្តន៍បក្សកុម្មុយនីស្តកម្ពុជា ខ្ញុំចូលនៅឆ្នាំ១៩៦៦ មិនមែនទេៗ ១៩៦៩ ឆ្នាំ១៩៦៩ ការយល់ដឹងថាបក្សតម្រូវឲ្យអនុវត្តហិង្សានយោបាយ អត់ទាន់ជ្រួតជ្រាបដល់ខ្ញុំទេពេលនោះ ។ មិនទាន់ដឹងថាបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកហិង្សាជាបាយ ជាសម្ល អត់ដឹងទេ ។ ដល់ក្រោយមកដែលដឹងច្បាស់គឺនៅដែលដឹងច្បាស់ គឺនៅពេលដែលគេបង្ខំឲ្យខ្ញុំធ្វើប្រធានមន្ទីរ១៣ នេះ ដែលខ្ញុំដឹង ។

ដូច្នេះ នៅក្នុងជីវិតរបស់ខ្ញុំនិយាយអំពីការជ្រួតជ្រាបទទួលស្គាល់ថា មានរូបភាពហិង្សាខ្លះ ស្រប ច្បាប់ត្រឹមត្រូវ ត្រឹមត្រូវតាមផ្លូវមនុស្សធម៌ក៏ដោយ ។ ខ្ញុំសូមបញ្ជាក់ម្តងទៀត ទោះបីបក្សកុម្មុយនីស្ត កម្ពុជាចាត់ទុកថា ហិង្សាបដិវត្តន៍ វាមានលក្ខណៈត្រឹមត្រូវខ្ពង់ខ្ពស់ឧត្តុង្គឧត្តមយ៉ាងណាក៏ដោយ ក៏ខ្ញុំអត់ ដែលទទួលស្គាល់ដូចនុ៎ងទេ តែត្រូវតែបង្ខំចិត្តធ្វើ ។

សូមបញ្ជាក់ថាអ្នកដែលយល់ដូច្នេះ មិនមែនមានតែខ្ញុំទេច្រើនណាស់ៗ ។ ខ្ញុំសូមជូនឧទាហរណ៍ មួយ ប្រពន្ធខ្ញុំមានបងប្រុសម្នាក់ត្រូវពួកលន់ នល់សម្លាប់ ដោយកប់នៅក្នុងរណ្តៅរួមជាមួយនឹងអ្នកភ្លេង ប្រាំមួយនាក់ផ្សេងទៀត អ្នកភ្លេងការប្រាំមួយនាក់ផ្សេងទៀត ។ ប្រពន្ធខ្ញុំអត់ដែលនិយាយមួយម៉ាត់សោះ អំពីថាបំណុលឈាមត្រូវសងដោយឈាម ។

សូម្បីតែចម្រៀងអាគីងចង្រៃហ្នឹង ក៏ប្រពន្ធខ្ញុំមិនដែលច្រៀង ។ សូមបញ្ជាក់ថា ប្រពន្ធខ្ញុំច្រៀង ពីរោះ នៅជាទូទៅគាត់តែងនិយាយក្រោយពីឆ្នាំ១៩៧៩ គាត់តែងនិយាយថា គាត់តែងនិយាយជាមួយខ្ញុំ ថា គិតសព្វៗទៅ អាណិតម៉ែដែរ ខំបង្កើតកូនមក ចិញ្ចឹមកូន ដល់កូនធំឲ្យគេប្រើ ។ គេប្រើមិនពេញចិត្ត គេវាយចោលភ្លូសៗ ។ ដូច្នេះ ខ្ញុំគិតថាមិនមែនមានតែខ្ញុំពីរនាក់ប្តីប្រពន្ធទេ ដែលមិនយល់ ក៏ប៉ុន្តែទាំង អស់គ្នាត្រូវតែធ្វើ នេះជាមាគ៌ាបក្ស ។ ហើយបក្សកុម្មុយនីស្តកម្ពុជាខ្លួនឯងហ្នឹង ដល់ក្រោយមកលុបអា ពាក្យបំណុលឈាមត្រូវតែសងដោយឈាម គឺលុបនៅឆ្នាំ១៩៨៣ អត់ប៊ានប្រើតទៅទៀតទេ ។

ដូច្នេះ បានន័យថាបក្សកុម្មុយនីស្តកម្ពុជា ក៏ទទួលស្គាល់ថាខ្លួនចាប់បង្ខំឲ្យសមាជិកបក្សរបស់ខ្លួន បង្ខំឲ្យបក្សកុម្មុយនីស្ត-- សមាជិកបក្សរបស់ខ្លួនទទួលស្គាល់ទស្សនៈនេះ មិនមានប្រសិទ្ធភាពទេ ខ្លួនមិន អាចមកចាប់បង្ខំគេបានទាំងស្រុងនោះទេ ។

សរុបមក ខ្ញុំបានក្លួចចូលទៅក្នុងចរន្តមួយដែលប្រើអំពើហិង្សា ដែលគេហៅថា "ឧបករណ៍ បរិសុទ្ធរបស់បក្ស" ក៏ប៉ុន្តែខ្ញុំមិនដែលទទួលស្គាល់ថា ហិង្សាបដិវត្តន៍ស្អីគេនោះ មានលក្ខណៈត្រឹមត្រូវ តាមផ្លូវមនុស្សធម៌ទេ ។ សូមចប់ប៉ុណ្ណេះ ។

[១៦:០៥:៥៣]

**សៈ** លោកបានរៀបរាប់ថា ការប្តេជ្ញារបស់លោកចំពោះបក្សកុម្មុយនីស្តកម្ពុជា គឺនៅក្នុងឆ្នាំ ១៩៦៩ លើកលែងតែលោកកែខ្ញុំ នៅពេលនោះ គឺពេលដែលលោកកំពុងជាប់ឃុំនៅឡើយទេ ឆ្នាំ៦៩ ។ ដូច្នេះហើយ ការប្តេជ្ញារបស់លោកចំពោះបក្សកុម្មុយនីស្តកម្ពុជា ទោះបីជាពេលនោះលោកក៏មិនមែនជា សមាជិកក៏ដោយ តែលោកប្តេជ្ញាចំពោះបក្សកុម្មុយនីស្តនេះតាំងពីមុនពេលហ្នឹងទៀត ។ ដូច្នេះ អ្វីដែលខ្ញុំ

ចង់ដឹងនោះ ថាតើការប្តេជ្ញា ហើយនិង-- ថាតើលោកដឹងអំពីហិង្សាណាមួយ ដែលបក្សកុម្មុយនីស្តកម្ពុជាបានធ្វើឡើងដែរឬទេ? ហើយតើលោកយល់អំពីអំពើហិង្សារបស់បក្សនោះ ថាយ៉ាងម៉េចដែរនៅពេលនុ៎ង?

**ឆ៖** សូមអរគុណលោកចៅក្រម ដែលបាននិយាយអំពីការបរិច្ឆេទរបស់ខ្ញុំ ។ ខ្ញុំចូលបដិវត្តន៍ឆ្នាំ១៩៦៤ ប្រហែលជាខែ១០ ។ នៅក្នុងឆ្នាំ១៩៦៥ ខ្ញុំទៅជាសមាជិកជនបង្គោល ខ្ញុំធ្វើពិធីបញ្ចូលបក្សជាបក្ខជនត្រៀមនៅថ្ងៃ២៥ ធ្នូ ១៩៦៧ ។ នៅថ្ងៃ២០ កក្កដា ១៩៦៨ ខ្ញុំនៅក្នុងគុក សាខានៅក្នុងគុក បំពេញសិទ្ធិបក្សឲ្យខ្ញុំ ។ សូមជម្រាបលោកចៅក្រមថា សំណួរមួយកំណាត់នេះខ្ញុំនឹកឃើញដល់សំណួរមួយកំណាត់ទៀតរបស់លោកចៅក្រមខ្ញុំភ្លេចបាត់ហើយ សូមមេត្តាលោកមានប្រសាសន៍ម្តងទៀត ។

**ស៖** ជាបឋមលោកបានលើកឡើងថា នៅក្នុងឆ្នាំ១៩៦៥ លោក គឺជាជនបង្គោល ហើយសកម្មភាពរបស់លោកដំបូងនោះ គឺផ្តួចផ្តើម និងគិតអំពីទ្រឹស្តីកុម្មុយនីស្ត គឺនៅពេលនោះ គឺទ្រឹស្តីនោះគេនិយាយអំពីការតស៊ូផ្សេងៗ ។ ថាតើលោកចាប់អារម្មណ៍ទៅលើការតស៊ូ ដែលលោកអនុវត្តដែរឬទេ នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា? តើលោកបានចោទសួរអំពីសំណួរនេះដែរឬទេ ចំពោះខ្លួនឯងលើការតស៊ូនោះ? ហើយនៅពេលនុ៎ង ថាតើមានសកម្មភាពណាមួយ ឬក៏អំពើហិង្សាជាក់លាក់ណាមួយដែលបក្សកុម្មុយនីស្តកម្ពុជាបានប្រព្រឹត្តដែរឬទេ នៅក្នុងការសងសឹកឆ្លើយតបទៅនឹងសកម្មភាពនយោបាយប្រឆាំងនឹងខ្លួន?

[១៦:០៩:៣៦]

**ឆ៖** សូមជម្រាបបញ្ជាក់លោកចៅក្រមថា ខ្ញុំបានវិភាគប្រវត្តិបក្សកុម្មុនីស្តកម្ពុជាជាពីរកំណាត់។ មួយកំណាត់ គឺចាប់តាំងពីកំណើតបក្សរហូតមកដល់រដ្ឋប្រហារ១៩៧០ ។ ក្នុងរយៈកាលមួយកំណាត់នេះខាងដើម បក្សកុម្មុយនីស្តកម្ពុជាអនុវត្តមាគ៌ាគោលនយោបាយប្រមូលកម្លាំង អត់ប៉ានប៉ះពាល់ដល់អាយុជីវិតអ្នកណាទេ ។ ចាប់ពីខែធ្នូ ១៩៧០ មក ដែលបក្សកុម្មុយនីស្តកម្ពុជាមានដីរំដោះ ដែលបក្សកុម្មុយនីស្តកម្ពុជាមានសមាជិកបក្សកាន់តែច្រើន ដែលបក្សកុម្មុយនីស្តកម្ពុជាមានកងកម្លាំងប្រដាប់អាវុធនៅពេលហ្នឹងហើយ ដែលបក្សកុម្មុយនីស្តកម្ពុជាអនុវត្តហិង្សាបក្សបដិវត្តន៍ប៉ះពាល់ដល់អាយុជីវិតប្រជាជនជាបណ្តើរៗ ។ សូមនៅខាងចុងបញ្ចប់នេះ ខ្ញុំសូមបញ្ជាក់ថា តាមខ្ញុំចាំកាលបរិច្ឆេទរបស់ខ្ញុំតាំងពីចូលបដិវត្តន៍រហូតដល់ចូលជាបក្ខជនពេញសិទ្ធិ ដែលខ្ញុំរាប់ជាលើកទីពីរនេះ ខ្ញុំជឿថាត្រឹមត្រូវតាមការចងចាំរបស់ខ្ញុំ ។

**ស៖** លោកបាននិយាយជាច្រើនអំពីៗបញ្ហាប្រឈមមុខចំពោះខ្លួនលោក នៅក្នុងការបង្ខំឱ្យទទួលយកនូវអំពើហិង្សា ដែលលោកនិយាយថា លោកបានបដិសេធលោកមិនចង់ធ្វើ ។ ឥឡូវនេះ ក្រៅអំពីហេតុការណ៍នេះ តើហេតុអ្វីក៏គេមិនអនុញ្ញាតឲ្យលោកជ្រើសរើសជម្រើសតាមចិត្តរបស់លោក? តើលោកតែងតែទទួលការបង្ខំឱ្យធ្វើដូច្នោះឬ? ឬតើមានខណៈពេលណាមួយដែលលោកនិយាយខ្លួនឯងថា ខ្ញុំបានប្តេជ្ញា ខ្ញុំបានធ្វើពលីកម្មក្នុងបដិវត្តន៍ ហើយខ្ញុំត្រូវតែទទួលធ្វើ? តើលោកមានទស្សនៈដូចម្តេចចំពោះរឿងរ៉ាវដែលទាក់ទងនឹងបញ្ហានេះ? ដែលយើងបានឮពីអ្នកជំនាញថា ជាបាតុភូតមួយដែលជាហេតុការណ៍ប្រទូសរ៉ាយរវាងការទទួលស្គាល់និងការបដិសេធការពិត ។ ហើយម្យ៉ាងទៀត គឺថាយើងចង់បដិសេធ ប៉ុន្តែម្ខាងទៀតយើងមានការប្តេជ្ញាថានឹងធ្វើនោះ តើលោកអាចនិយាយបានដូចម្តេចពីគំនិតនេះ?

[១៦:១៤:១៧]

**ឆ៖** សូមអរគុណលោកចៅក្រមដែលបានលើកបញ្ហានេះ ។ ខ្ញុំសូមបញ្ជាក់ថា ទិដ្ឋភាពដែលលោកជំនាញលើកឡើង ហើយនិងការសួរដេញដោលនៅក្នុងអង្គសវនាការនេះ ច្រើនតែចាប់អារម្មណ៍ថា ខ្ញុំមិនទទួលស្គាល់ថាអំពើដែលខ្ញុំធ្វើវាយុត្តិធម៌ វាត្រឹមត្រូវ ម៉េចក៏ខ្ញុំធ្វើ? ខ្ញុំ តាមការវិភាគរបស់ខ្ញុំទៅតាមទស្សនវិជ្ជាដែលគេបានបង្រៀនខ្ញុំ ដូចខ្ញុំបានជម្រាបព្រឹកមិញហើយថា អាហ្នឹងគេហៅថា *អ៊ុយនីតេដេកុងត្រាស់* ។ ឧទាហរណ៍ រណសិរ្សរួបរួមជាតិកម្ពុជាវាមានភាគីអ្នករាជានិយម វាមានភាគីបក្សកុម្មុយនីស្តកម្ពុជា ។ ដូច្នេះ អាពីរហ្នឹងវាទំនាស់គ្នា ក៏ប៉ុន្តែវានៅក្នុងអង្គភាពតែមួយ គឺរណសិរ្សរួបរួមជាតិកម្ពុជា ។ ស្អប់ហិង្សាបដិវត្តន៍ ស្អប់ការកាប់សម្លាប់ វាជាផ្នែកមួយ ក៏ប៉ុន្តែមាគ៌ាបក្សគេនិយាយអំពីហិង្សាបដិវត្តន៍ ។ អាពីរហ្នឹងវាផ្ទុយគ្នា ទោះអ្នកឯងប្រឆាំងយ៉ាងម៉េចក៏ដោយអ្នកឯងត្រូវតែធ្វើ បើអ្នកឯងចង់រស់ ។ នេះហើយដែលខ្ញុំបានបញ្ជាក់ហើយបញ្ជាក់ទៀតថា វាជាអំពើខ្មាសអៀនបំផុតក្នុងជីវិតខ្ញុំដែលធ្លាក់ខ្លួនទៅ ។

នេះហើយដែលខ្ញុំបញ្ជាក់ជូនលោកចៅក្រមស៊ើបអង្កេតថា ខ្ញុំជា *"អាក់ទ័រ* និង *អូតា ឌុយវ៉េហ្ស៊ីម អាក់ទ័រ ឌុយគ្រីម អេ អ៊ុតា ឌុយវ៉េហ្ស៊ីម"* (និយាយភាសាបារាំង)។ ខ្ញុំនៅថាគិតថា អានេះវាជាតួនាទីពីរដែលខ្ញុំដើរ ទីមួយខ្ញុំជា *អ៊ុតា ឌុយវ៉េហ្ស៊ីម* ខ្ញុំដើរតួពីរ ទីមួយខ្ញុំជា *អ៊ុតា ឌុយវ៉េហ្ស៊ីម* ។ ទីពីរ ខ្ញុំជា *អាក់ទ័រ ឌុយគ្រីម* ដែលសាស្រ្តាចារ្យ ស៊ីរ៉ូនី គាត់ហៅថា *ឡឺរ៉ូសអាហ្ស៊* ដែលខ្ញុំពន្យល់គាត់ គាត់ទទួលស្គាល់ថា *អាឡឺរ៉ូសអាហ្ស៊* ។ ខ្ញុំសូមបញ្ចប់ការឆ្លើយតបប៉ុណ្ណេះ ។

[១៦:២០:១០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំជឿថាយើងនឹងត្រូវផ្អាកនៅពេលនេះសិន ។ យើងនៅសល់សំណួរមួយចំនួនត្រូវសួរទៅលោកជនជាប់ចោទ ។ ប៉ុន្តែ ឥឡូវនេះដល់ពេលដូចជាជិតម៉ោងសម្រាកហើយលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ដំណើរសវនាការថ្ងៃនេះ ឃើញថាដល់ម៉ោងត្រូវសម្រាកហើយ ហើយអង្គជំនុំជម្រះប្រកាសផ្អាកដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ។ ដំណើរការសវនាការត្រូវលើកបន្តទៅថ្ងៃច័ន្ទទី១៤ ខែកញ្ញា ឆ្នាំ២០០៩ ចាប់ពីវេលាម៉ោងប្រាំបួនព្រឹក ហើយដំណើរការសម្រាប់ថ្ងៃច័ន្ទនោះ គឺស្តាប់សក្ខីកម្មអ្នកជំនាញ សាក្សីដែលជាអ្នកជំនាញ ហ្គូលស្ទូន រីឆាត ពីចម្ងាយ ហើយនិងជាបន្តបន្ទាប់ គឺស្តាប់នូវសក្ខីកម្មសាក្សី ដែលជាអ្នកជំនាញ ។ ហើយពេលវេលាដែលនៅសេសសល់ គឺក្នុងសប្តាហ៍នោះ គឺយើងនឹងបន្តសួរសំណួរពាក់ព័ន្ធជាមួយនឹងអត្តចរិតជនជាប់ចោទ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំជនជាប់ចោទមកកាន់សាលសវនាការនៅព្រឹកថ្ងៃច័ន្ទ ទី១៤ ខែកញ្ញា ឆ្នាំ២០០៩ ឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំណត់៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[អង្គសវនាការផ្អាកនៅម៉ោង ១៦:២១នាទី]*